

# ការឆ្លុះបញ្ចាំងលើ ជីវិតនៃស្មារតី



វិទ្យាស្ថានរូហ៊ី





ភាគ ១

# ការឆ្លុះបញ្ចាំងលើជីវិតនៃស្មារតី

វិទ្យាស្ថានរូហ៊ី

Books in the Series:

Below are the current titles in the series designed by the Ruhi Institute. The books are intended to be used as the main sequence of courses in a systematic effort to enhance the capacity of youth and adults to serve their communities. The Ruhi Institute is also developing a set of courses that branch out from the third book in the series for training Bahá'í children's class teachers, as well as another set from Book 5 for raising up animators of junior youth groups. These, too, are indicated in the list below. It should be noted that the list may undergo change as experience in the field advances, and additional titles will be added as a number of curricular elements under development reach the stage where they can be made widely available.

| | |
|---|---|
| Book 1 | *Reflections on the Life of the Spirit* |
| Book 2 | *Arising to Serve* |
| Book 3 | *Teaching Children's Classes, Grade 1* |
| | *Teaching Children's Classes, Grade 2* (branch course) |
| | *Teaching Children's Classes, Grade 3* (branch course) |
| | *Teaching Children's Classes, Grade 4* (branch course) |
| Book 4 | *The Twin Manifestations* |
| Book 5 | *Releasing the Powers of Junior Youth* |
| | *Initial Impulse: The first branch course of Book 5* |
| | *Widening Circle: The second branch course of Book 5* |
| Book 6 | *Teaching the Cause* |
| Book 7 | *Walking Together on a Path of Service* |
| Book 8 | *The Covenant of Bahá'u'lláh* |
| Book 9 | *Gaining an Historical Perspective* |
| Book 10 | *Building Vibrant Communities* |
| Book 11 | *Material Means* |
| Book 12 | (forthcoming) |
| Book 13 | *Engaging in Social Action* |
| Book 14 | (forthcoming) |

Copyright © 1987, 2012, 2020 by the Ruhi Foundation, Colombia
All rights reserved. Edition 4.1.1.PE published in September 2020
Printed in Cambodia

Originally published in Spanish as *Reflexiones sobre la vida del espíritu*
Copyright © 1987, 1995, 2008, 2020 by the Ruhi Foundation, Colombia
ISBN 978-958-59880-3-3

Permission for a limited printing of this book in Khmer has been granted to National Spiritual Assembly of Cambodia by the Ruhi Institute.

Ruhi Institute
Cali, Colombia
Email: instituto@ruhi.org
Website: www.ruhi.org

# Contents

A Few Thoughts for the Tutor .................. v

Understanding the Bahá'í Writings ............ 9

Prayer ...................................................... 23

Life and Death .......................................... 39

## គំនិតមួយចំនួនសម្រាប់អ្នកសម្របសម្រួល

ចំនួននៃតំបន់ជាច្រើនដែលក្នុងនោះ ការឆ្លុះបញ្ចាំងស្តីពី ជីវិតនៃស្មារតី ដែលជាសៀវភៅដំបូងនៃលំដាប់នៃវគ្គទាំងឡាយដ៏សំខាន់ ដែលបានផ្តល់ដោយវិទ្យាស្ថានរូហុី ដែលត្រូវបានគេសិក្សាទូទាំងពិភពលោកបានកើនឡើងអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នៅក្នុងករណីទាំងឡាយដ៏សំខាន់ភាគច្រើន ឯកសារត្រូវបានគេអាននិងពិភាក្សាដោយក្រុមមួយនៃមិត្តជាច្រើន ដែលអាចបង្កើតការសិក្សាជាក្រុមមួយដែលជួបជុំគ្នាទៀងទាត់ អាចមកជុំគ្នាក្នុងយុទ្ធនាការមួយដែលបានរៀបចំសម្រាប់ការសិក្សាប្រកបដោយប្រពលភាពឬក៏អាចជុំគ្នាក្នុងការបោះជំរំអំឡុងពេលវិសម្សកាលសាលារៀននានា។ នៅពេលណាឱកាសមកដល់ សមាជិកម្នាក់របស់ក្រុមដើរតួជាអ្នកសម្របសម្រួល។ ភាពទំនាក់ទំនងគ្នារវាងអ្នកសម្របសម្រួល និងអ្នកចំណូលរួមផ្សេងៗទៀតគឺមិនមែនប្រភេទនៃទំនាក់ទំនងគ្រូនិងសិស្សទេ ទាំងអស់គ្នាត្រូវបានចូលរួមដោយមនសិការក្នុងដំណើរការមួយដែលក្នុងនោះគ្រប់គ្នាគឺកំពុងស្វែងរកដើម្បីរៀនសូត្រ។ ប៉ុន្តែអ្នកសម្របសម្រួលមិនមែនជាអ្នកសម្របសម្រួលដែលត្រូវផ្តាច់ចេញឬអសកម្មនោះដែរ។ ការបញ្ចប់ចំនួននៃវគ្គទាំងឡាយឱ្យបានគ្រប់គ្រាន់តាមលំដាប់និងបានអនុវត្តសកម្មភាពទាំងឡាយនៃការបម្រើ ដែលវគ្គទាំងនោះជម្រុញគាត់ឬនាងអាចជួយសមាជិកម្នាក់ៗនៃក្រុមក្នុងការសម្រេចគោលបំណងនៃឯកសារដែលត្រូវបានគេសិក្សា។ អ្នកទាំងនោះដែលធ្វើជាអ្នកសម្របសម្រួលនៃសៀវភៅភាគ១ ខ្ញុំអាចគិតថាវាល្អសម្រាប់ការរំលឹកសាឡើងវិញពីគំនិតដែលបានបង្ហាញក្នុងការណែនាំនេះពីពេលមួយទៅពេលមួយ។

អ្នកចំណូលរួមទាំងឡាយលើពិភពលោកមកសិក្សាវគ្គវិទ្យាស្ថានដំបូងដែលមកពីសាវតាផ្សេងៗគ្នា។ អ្នកខ្លះជាសមាជិកទាំងឡាយរបស់សហគមន៍បាហៃ ដែលសង្ឃឹមថានឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ពួកគេដើម្បីបម្រើបុព្វហេតុសាសនារបស់ព្រះដែលពួកគេបានឱបក្រសោបយក។ អ្នកដទៃមើលឃើញវគ្គវិទ្យាស្ថាន ជាការចាប់ផ្តើមនៃការអង្កេតស្រាវជ្រាវនៃជំនឿបាហៃជាសាសនាមួយ។ អ្នកដទៃនៅតែត្រូវបានទាក់ទាញចំពោះឧត្តមគតិនៃជំនឿសាសនា និងមានបំណងធ្វើឱ្យខ្លួនពួកគេយល់ដឹងជាមួយនឹងគោលដៅ និងភាពខិតខំប្រឹងប្រែងនានារបស់សហគមន៍។ ហើយមានការកើនឡើងចំនួននៃយុវជនវ័យក្មេងៗជាពិសេសដែលជាមនុស្សរង់ចាំអភិវឌ្ឍសមត្ថភាពរបស់ពួកគេ ដើម្បីបម្រើសហគមន៍នោះ ដែលជាញឹកញាប់តាមរយៈកម្មវិធីឬកម្មវិធីផ្សេងទៀតដែលបានជម្រុញដោយសហគមន៍បាហៃ ពួកគេទាំងនោះចាប់ផ្តើមវគ្គវិទ្យាស្ថានជាជំហានដំបូងមួយ។

តាំងពីគ្រាដំបូង វាគួរតែច្បាស់ចំពោះគ្រប់អ្នកចូលរួមដែលវគ្គទាំងឡាយនៃវិទ្យាស្ថានដើរតាមមាគ៌ាមួយនៃការបម្រើចំពោះមនុស្សជាតិ ដែលយើងម្នាក់ៗដើរតាមមាគ៌ាផ្ទាល់ខ្លួនរបស់យើង ជួយជ្រោមជ្រែងនិងត្រូវបានជួយដោយអ្នកដទៃ។ ដើរលើមាគ៌ានេះបញ្ជាក់ពីការបន្តស្វែងរកនៃគោលបំណងភ្លោះផ្នែកសីលធម៌៖ ដើម្បីផ្តោតអារម្មណ៍លើការរីកចម្រើនផ្នែកសតិបញ្ញានិងស្មារតីផ្ទាល់ខ្លួនរបស់បុគ្គល ហើយនិងដើម្បីចូលរួមចំណែកចំពោះការផ្លាស់ប្តូរនៃសង្គម។ ភាពរីកចម្រើនលើមាគ៌ាផ្តល់នូវការអភិវឌ្ឍនៃចំនួនមួយនៃសមត្ថភាពទាំងឡាយដែលត្រូវការការយល់ដឹងនិងចំណេះដឹង លក្ខណៈគុណសម្បត្តិផ្នែកស្មារតីនិងអត្តចរិតដែលគួរឱ្យសរសើរព្រមទាំងចំនួនដ៏ច្រើនមួយនៃសមត្ថភាពនិងជំនាញនានា។ ប្រភពនៃចំណេះដឹងដែលសៀវភៅនានានៃវិទ្យាស្ថានទទួលយក គឺមកពីការបង្ហាត់បង្រៀនទាំងឡាយនៃជំនឿបាហៃទី

មួយ  រីឯទីពីគឺមកពីបទពិសោធន៍ដែលកំពុងកើនឡើងនៃសហគមន៍បាហៃទូទាំងពិភពលោក  ក្នុងការបន្តអរិយធម៌ផ្នែកស្មារតីនិងអរិយធម៌សម្ភារ។  វាគឺជាទស្សនៈរបស់ព្រះបាហាអ៊ុលឡាហ៍សម្រាប់បុគ្គលថាយើងអាចក្លាយជាប្រភេទបុគ្គលហើយយើងអាចស្ថាបនាអរិយធម៌អ្វីខ្លះដែលជម្រុញដោយវិទ្យាស្ថាន។  វាត្រូវបានគេសន្មតថាអ្នកចំណូលរួមទាំងអស់មិនថាមកសាវតាណាក៏ដោយ  គឺបើកស្វាគមន៍ដើម្បីទទួលយកទស្សនៈនេះដែលច្បាស់លាស់នៅក្នុងគ្រប់វគ្គនៃសៀវភៅនីមួយៗ។

នៅក្នុងពិភពលោកកន្លែងដែលជំនឿនិងមនោគមន៍វិជ្ជាទាំងឡាយ កំពុងតែមានឆន្ទៈក្នុងការប្រើ មធ្យោបាយណាមួយដែលអាចធ្វើទៅបានដើម្បីទទួលជោគជ័យ  មនុស្សម្នាក់ដែលពុំទាន់បានស្គាល់ជំនឿសាសនាអាចមានសំណួរត្រង់ៗជាច្រើនអំពីគោលបំណងនៃវិទ្យាស្ថានរូហ៊ីដែលគួរឱ្យកត់សម្គាល់បំផុតថា  "តើខ្ញុំកំពុងត្រូវបានគេស្នើសុំដើម្បីប្តូរសាសនារបស់ខ្ញុំឬ?" ឬក៏ "តើខ្ញុំកំពុងត្រូវបានគេស្នើសុំដើម្បីចូលរួមសាសនាមួយឬ?" សំណួរទាំងឡាយបែបនេះផ្តល់ឱ្យអ្នកសម្របសម្រួលនូវឱកាសមួយដើម្បីពន្យល់ពីគោលបំណងនៃលំដាប់នៃវគ្គទាំងឡាយដូចបានរៀបរាប់ខាងលើ។  វាជាធម្មតាដែលសាសនិកបាហៃចង់ឃើញមិត្តទាំងឡាយរបស់ពួកគេចូលរួមសហគមន៍  អ្នកសម្របសម្រួលក្រុមម្នាក់បន្ថែមថាការបង្ហាត់បង្រៀនផ្ទាល់ខ្លួនពួកគាត់ពីការផ្លាស់ប្តូរសាសនាដោយសំពាធនោះទេ  ការដើរតាមមាគ៌ានៃការបម្រើដែលបានផ្តល់ឱកាសដោយវគ្គវិទ្យាស្ថានទាំងឡាយដែលអំពាវនាវការយល់ដឹងកាន់តែស៊ីជម្រៅពីការបង្ហាត់បង្រៀនទាំងឡាយរបស់ព្រះបាហាអ៊ុលឡាហ៍ដែលឯកសារទាំងឡាយប្រឹងប្រែងរៀបចំយ៉ាងច្បាស់លាស់៖  ការទទួលយកនិងជំនឿគឺជារឿងដ៏សំខាន់ដែលត្រូវបានគេគិតពិចារណាយ៉ាងយកចិត្តទុកដាក់ដោយបុគ្គលម្នាក់ៗយ៉ាងសេរីនិងគ្មានសំពាធអ្វីទាំងអស់។

អ៊ីចឹងមិនមានការភ្ញាក់ផ្អើលនោះទេ វាគឺជារឿងមួយនៃការស្វែងយល់ដែលជាចំណុចកណ្តាលនៃលំដាប់សៀវភៅទាំងអស់ ដែលជាការចាប់ផ្តើមនៃសៀវភៅទីមួយនេះ។ ការអានពីព្រះវចនៈពិសិដ្ឋទាំងឡាយគឺមិនដូចគ្នាទៅនឹងការអានជាច្រើនពាន់ទំព័រដែលបុគ្គលម្នាក់ជួបប្រទះក្នុងឆាកជីវិតនោះទេ  ហើយវគ្គថា  "ការស្វែងយល់ពីសំណេរទាំងឡាយរបស់បាហៃ"  ស្វែងរកដើម្បីជម្រុញទម្លាប់នៃការអានអត្ថបទទាំងឡាយដែលដកស្រង់ចេញពីអត្ថបទដ៏ពិសិដ្ឋរបស់ព្រះជារៀងរាល់ថ្ងៃ និងការធ្វើសមាធិពីអត្ថន័យរបស់ពួកវា ទម្លាប់មួយដែលនឹងជួយច្រើនដល់អ្នកចំណូលរួមទាំងឡាយនៅពេលពួកគេចាប់ផ្តើមដើរលើមាគ៌ានៃការបម្រើ។  ដើម្បីណែនាំពួកគេក្នុងការសិក្សារបស់វា  អ្នកសម្របសម្រួលត្រូវតែផ្តល់គំនិតដ៏សំខាន់ចំពោះប្រធានបទនៃការស្វែងយល់នេះ។

សំណេរបាហៃទាំងឡាយមានសច្ចធម៌ផ្នែកស្មារតីដ៏ស៊ីជម្រៅ  ហើយទោះបីជាយើងពុះពារព្យាយាមដើម្បីបង្កើនក្នុងការយល់ដឹងរបស់យើងពីអត្ថន័យដ៏គ្មានដែនរបស់សំណេរទាំងនោះក្តី យើងដឹងថាយើងមិនអាចឈានដល់ចុងបញ្ចប់ដ៏ច្បាស់លាស់នោះទេ។ ជាធម្មតាយើងចាប់ផ្តើមការយល់ដឹងដែលជាគ្រឹះមួយនៃការធ្វើសមាធិលើអត្ថន័យនៃអត្ថបទនៅពេលអានវាសម្រាប់លើកដំបូងនិងមេរៀនទី១នៃវគ្គចាប់យកត្រង់ចំណុចនេះជាចំណុចចាប់ផ្តើម។  ដូច្នេះហើយក្រោយពេលអានព្រះវចនៈ  "ភាពល្អប្រសើរនៃពិភពលោកអាចត្រូវបានគេសម្រេចតាមរយៈអំពើល្អនិងបរិសុទ្ធ  តាមរយៈអាកប្បកិរិយាសមរម្យនិងគួរឱ្យសរសើរ"  អ្នកចូលរួមទាំងឡាយគឺត្រូវបានសួរជាធម្មតាថា  "តើភាពល្អប្រសើរនៃពិភពលោកអាចត្រូវបានគេសម្រេចតាមរបៀបណា?" ការសម្លឹងមើលមួយភ្លែត សំណួរនិងលំហាត់ភាគច្រើននៃប្រភេទនេះលេចឡើងជា

ធម្មតា។ ប៉ុន្តែបទពិសោធន៍ជាច្រើនឆ្នាំ ទំនងហាក់ដូចជាបង្ហាញយ៉ាងត្រឹមត្រូវនូវការសម្រេចរបស់វិទ្យាស្ថានដើម្បីចាប់ផ្តើមមធ្យោបាយនេះ។ យើងទាំងអស់គ្នាត្រូវបានគេក្រើនរំលឹក ក្នុងភាពប្រញាប់ប្រញាល់ដើម្បីស្វែងរកលំដាប់នៃសច្ចធម៌ក្នុងអត្ថបទមួយ ចិត្តគំនិតមិនគួរមើលរំលងអត្ថន័យជាក់ស្តែងរបស់វានោះទេ។ ការយកចិត្តទុកដាក់ចំពោះកម្រិតទីមួយនៃការយល់ដឹងបង្ហាញពីសារសំខាន់ផងដែរចំពោះក្រុមពិភាក្សា វាពង្រឹងសាមគ្គីភាពនៃគំនិត ភាពអាចសម្រេចបានយ៉ាងស្រួលនៅពេលគំនិតទាំងឡាយផ្ទាល់ខ្លួនត្រូវបានគេអនុញ្ញាតឱ្យដែលត្រូវបានបង្ហាញដោយគតិបណ្ឌិតអាទិទេពនោះ។

វាគឺមានសារសំខាន់ដើម្បីកត់ត្រានៅទីនេះថា ការយល់ដឹងពីអត្ថន័យភ្លាមៗនៃអត្ថបទនានាភាគច្រើនមិនផ្តល់ប្រយោជន៍ពីការពិភាក្សាយូរពេកនៃពាក្យទាំងឡាយតែមួយក្រៅពីអត្ថបទ។ នោះបាននិយាយថានៅឱកាសមួយវាអាចមានភាពចាំបាច់សម្រាប់ក្រុមមួយដើម្បីស្វែងរកពាក្យក្នុងវចនានុក្រម។ ទោះបីជាយ៉ាងនោះក្តី អ្វីដែលមានផ្លែផ្កាច្រើន គឺសម្រាប់អ្នកចំណូលរួមទាំងឡាយដើម្បីរៀនសូត្រពីរបៀបដើម្បីសន្និដ្ឋានអត្ថន័យនៃពាក្យទាំងឡាយពីល្បះនិងកថាខណ្ឌទាំងមូល។

ដើម្បីពង្រីកការយល់ក្រៅពីការចាប់អារម្មណ៍អត្ថន័យភ្លាមៗ ឧទាហរណ៍ជាច្រើនដែលបង្ហាញពីរបៀបស្វែងរកគោលគំនិតដ៏ច្បាស់លាស់អាចជួយបាន។ អ្វីទាំងអស់នោះ ដែលត្រូវបានគេអំពាវនាវទាក់ទងទៅនឹងរឿងនេះ គឺជាលំហាត់ត្រង់ៗ។ ឧទាហរណ៍ក្នុងមេរៀនទី២ អ្នកចំណូលរួមត្រូវបានគេស្នើសុំដើម្បីកំណត់អត្ថន័យនៃអត្ថបទមួយដែលពួកគេទើបតែអានរួច តើលក្ខណៈពិសេសទាំងឡាយគឺគួរឱ្យសរសើរឬ។ ក្នុងលំហាត់ស្រដៀងគ្នានេះដែរក្នុងមេរៀនទី៤ ពួកគេអាចត្រូវបានជម្រុញលើកទឹកចិត្តដើម្បីផ្តល់ឈ្មោះគុណធម៌ចំនួនប្រាំ ហើយបន្ទាប់មកសម្រេចថាតើវាគឺមានលទ្ធភាពដើម្បីទទួលយកនៃគំនិតណាមួយដែលគ្មានសច្ចធម៌ដែលបានពណ៌នាក្នុងសំណេរទាំងឡាយរបស់ព្រះថា៖ ជា"គ្រឹះនៃគុណធម៌របស់មនុស្សទាំងពួង" ។

ដើម្បីសម្រេចគោលបំណងរបស់វា វគ្គនេះទាមទារភាពរីកចម្រើនបន្ថែមទៀតមួយក្នុងស្វែងយល់ដោយអ្នកចូលរួមទាំងឡាយដែលខិតខំអស់ពីសមត្ថភាពដើម្បីគិតអំពីការទាក់ទងមួយចំនួននៃអត្ថបទទាំងឡាយដែលបានបង្ហាញ។ ក្នុងមេរៀនទី២ ពួកគេត្រូវបានគេសំណូមពរដើម្បីសម្រេចថាតើសេចក្តីថ្លែងការថា៖ "មានមនុស្សល្អតិចណាស់ក្នុងពិភពលោកដែលសកម្មភាពទាំងឡាយរបស់ពួកគេមិនមានអានុភាពនោះ" គឺពិតឬមិនពិត។ គោលបំណងនៅទីនេះគឺមិនមែនដើម្បីចម្រាញ់គំនិតប៉ុននោះទេ។ អ្នកសម្របសម្រួលត្រូវតែផ្អាកបន្តិចសិន ហើយសួរហេតុផលចំពោះចម្លើយទាំងឡាយរបស់អ្នកចំណូលរួម។ សេចក្តីថ្លែងការនោះចាំត្រូវតែខុសទាំងស្រុង ពីព្រោះវាផ្ទុយទៅនឹងព្រះវចនៈទីមួយក្នុងមេរៀនមុនដែលជាការសន្និដ្ឋានចំពោះក្រុមគួរតែសម្រេចនោះ។ សំណួរដែលថា តើបាហៃអាចសារភាពអំពើបាបទាំងឡាយរបស់ពួកគេដល់អ្នកដទៃបានដែរឬទេ ដែលជាឧទាហរណ៍មួយនៃប្រភេទលំហាត់នេះ។ វាសម្តៅចំពោះការហាមឃាត់នៅក្នុងការបង្ហាត់បង្រៀននានាប្រឆាំងទៅលើការសាភាពដូចជាអត្ថន័យនៃការលាងបាប ដែលមិនបានបរិយាយក្នុងអត្ថបទសិក្សាទាំងឡាយណាមួយឡើយនោះ អាចត្រូវបានគេទាញយកមកប្រើប្រាស់ដោយការរុករកអត្ថន័យនៃកំណាព្យថា "ចូរជម្រះបញ្ជីខ្លួនអ្នកជារៀងរាល់ថ្ងៃមុនពេលអ្នកត្រូវបានគេកោះហៅឱ្យទៅទទួលផល"។

លំហាត់ទាំងឡាយនៅក្នុងវគ្គមិនអាចក្រសោបពីលំដាប់នៃអត្ថន័យដែលត្រឹមត្រូវតាមអត្ថបទ ដែលឋិតក្រោមការយកចិត្តដាក់ខ្ពស់នោះទេ។ សំណួរមួយដែលគ្រប់អ្នកសម្របសម្រួលត្រូវតែគិតពិចារណា ពីកម្រិតនៃការពិភាក្សាគ្នាចំពោះលំហាត់យូរប៉ុនណា។ នៅទីនេះវាគឺមានសារសំខាន់ ដើម្បីចងចាំទុកក្នុងចិត្តថា ការពន្យាពេលការសញ្ជឹងគិតដោយការបង្ហាញពីការទាក់ទងគ្នាច្រើន ប៉ុន្តែគោលគំនិតដែលឃ្លាតឆ្ងាយពីចំណុចកណ្តាលលំអៀងទៅរកការថយចុះប្រសិទ្ធភាពរបស់ឯកសារទៅវិញ។ ក្រុមនីមួយៗត្រូវការបង្កើតនូវចង្វាក់នៃភាពរីកចម្រើនដែលប្រកបដោយហេតុផលមួយ អ្នកចំណូលរួមទាំងឡាយគួរមានអារម្មណ៍យល់ច្បាស់ថាពួកគេកំពុងរីកចម្រើនយ៉ាងខ្លាំងទៅតាមសមត្ថភាពទាំងឡាយផ្ទាល់ខ្លួនរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកសម្របសម្រួលប្រុងប្រយ័ត្នក្រែងលោមេរៀនត្រូវបានហួសលឿនពេក ហើយមិនស៊ីជម្រៅដោយគ្មានការវិភាគយកចិត្តទុកដាក់ខ្ពស់ពីលំហាត់ទាំងឡាយនោះ ក្រុមនានាដែលបានបន្តក្នុងវិធីនេះ គ្រាន់តែបំពេញចម្លើយទាំងឡាយតែប៉ុននោះ ហើយក្រុមនោះមិនបានសម្រេចដល់លទ្ធផលចុងក្រោយនោះ ឡើយ។

ចំណុចចុងក្រោយមួយសមដូចការពោលថា៖ វាអាស្រ័យលើអ្នកសម្របសម្រួលដើម្បីធានាថាសមាជិកគ្រប់រូបនៃក្រុមនៅតែបានឋិតនៅជាប់ក្នុងដំណើរការនានានៃការរៀនសូត្រដែលបានជម្រុញដោយឯកសារនោះ។ ដើម្បីសម្រាំងការចូលរួមដែលគ្មានសំពាធទៅបុគ្គលណាម្នាក់ដើម្បីនិយាយរឿងគឺជាឧបសគ្គ។ អ្វីដែលគួរត្រូវបានគេយល់ពីការចាប់ផ្តើមគឺថាបញ្ហានេះគឺកម្រត្រូវបានជួបដោយការសួរសំណួរនានាបែបនេះថា "តើនេះមានន័យអ្វីខ្លះចំពោះអ្នក?" សំណួរទាំងឡាយប្រភេទនេះនាំឱ្យបាត់បង់ចំណេះដឹងនិងសច្ចធម៌ចំពោះកម្រិតនៃគំនិត។ ដូច្នេះហើយវាបង្ហាញភាពលំបាកដើម្បីបង្កើតបរិយាកាសដែលក្នុងនោះការពិភាក្សាក្នុងចំណោមសមាជិកទាំងឡាយនៃក្រុមតាមពិតទៅចាប់ផ្តើមបង្កើនការយល់ដឹង។

វគ្គទីពីរនៃសៀវភៅនេះគឺត្រូវបានគេយកចិត្តទុកដាក់ដូចវគ្គទី១ ជាមួយនឹងទម្លាប់ដ៏សំខាន់ចំពោះជិវិតផ្នែកស្មារតីពោលគឺការសូត្រធម៌ទៀងទាត់។ វាបង្កើតនូវភាពច្បាស់លាស់ក្នុងការផ្តល់គោលគំនិតមេរៀននៃ "ការដើរតាមមាគ៌ានៃការបម្រើ" ការផ្តល់ជាយោបល់ថា ដើម្បីដើរតាមមាគ៌ានៃការបម្រើនេះ យើងត្រូវបានគេធ្វើឱ្យជ្រួតជ្រាបជាមួយនឹងគោលបំណងភ្លោះមួយ។ អ្នកចំណូលរួមទាំងឡាយពិនិត្យពីចង្កោមព្រះវចនៈទាំងឡាយដំបូងដែលផ្តល់នូវការឈ្វេងយល់ដ៏ជ្រាលជ្រៅចូលទៅក្នុងធម្មជាតិនៃគោលបំណងនេះ ខ្លឹមសារមួយដែលនឹងត្រូវបានគេលម្អិតក្នុងវគ្គទាំងឡាយនាពេលអនាគត។

នៅពីក្រោយនៃខ្លឹមសារវគ្គនេះរាប់បញ្ចូលទាំងការរុករកពីសារសំខាន់នៃធម៌។ វាទទួលនូវវិធីស្រដៀងៗគ្នាចំពោះវិធីមួយដែលពណ៌នាក្នុងកថាខណ្ឌនានាពីមុន។ សំណួរនិងលំហាត់ជាច្រើនត្រូវបានគេបង្កើតឡើងដើម្បីបង្កើនការយល់ទៅនឹងអត្ថន័យនៃអត្ថបទទាំងឡាយដែលដកស្រង់ពីសំណេររបស់ព្រះដែលត្រូវបានសិក្សានោះ។ នៅពេលដែលក្រុមបន្តការសិក្សាតាមវគ្គ អ្នកសម្របសម្រួលអាចត្រូវបានគេតម្រូវដើម្បីបំបាត់ចោលនូវការសង្ស័យ ដោយសញ្ញាណទាំងឡាយនៃការវិភាគដែលបានចាក់ឫសក្នុងការបកប្រែនិងការអនុវត្តកាលពីអតីតកាល។ នៅក្នុងប្រពៃណីមួយចំនួន ទម្លាប់ និង

ទម្រង់គឺបានលុបលើភាពសំខាន់នៃលក្ខណៈខាងក្នុង ហើយមនុស្សជាច្រើនមិនអើពើពីភាពចាំបាច់នៃការសូត្រធម៌នោះទេ ដែលសម្រាប់វិញ្ញាណក្ខន្ធមនុស្សជាតិ ការសូត្រធម៌មានសារសំខាន់ដូចអាហារដែលបំប៉នផ្នែករាងកាយដូច្នោះឯង។

ដូច្នេះនៅលើអ្វីៗទាំងអស់ គឺវគ្គចង់ដាស់តឿនអ្នកចំណូលរួមទាំងឡាយ ដែលមានគោលបំណងដើម្បី"សន្ទនាជាមួយនឹងព្រះ" ហើយខិតទៅជិតទ្រង់នោះ។ ក្នុងចំណោមគំនិតទាំងឡាយដែលបានបង្ហាញគឺជាអ្វីដែលវាចង់និយាយពីការចូលទៅក្នុងលក្ខណៈនៃការសូត្រធម៌ រូបភាពដែលដក់ជាប់ក្នុងបេះដូងនិងចិត្តគំនិតរបស់យើងនៅពេលយើងធ្វើវា ហើយស្ថានភាពទាំងឡាយដែលគួរត្រូវបានគេបង្កើតឡើងនូវអ្វីដែលនៅជុំវិញយើងមិនថាយើងគឺនៅតែម្នាក់ឯងឬនៅក្នុងការជួបជុំមួយនោះទេ។ តាមពិត ក្រោយពេលផ្តល់គំនិតមួយចំនួន ចំពោះកម្លាំងទាំងឡាយដែលបានពង្រឹងតាមរយៈការគោរពបូជារួមគ្នា អ្នកចំណូលរួមទាំងឡាយត្រូវបានគេស្នើសុំដើម្បីពិចារណាធ្វើជាម្ចាស់នៃការជួបជុំគ្នាមួយសម្រាប់ការសូត្រធម៌និងភក្តីភាព។

ការសិក្សាជំពូកទីបីរបស់សៀវភៅ"ជីវិតនិងមរណភាព" វាត្រូវបានគេសង្ឃឹមថានឹងពង្រឹង ការប្តេជ្ញាចិត្តចំពោះការដើរតាមមាគ៌ានៃការបម្រើ ហើយផ្តល់ឱ្យវាជាមួយនឹងអត្ថន័យដ៏ស៊ីជម្រៅខ្លាំងឡើងៗ។ ការបម្រើក្នុងពិភពលោកនេះគឺត្រូវបានគេយល់ដឹងដ៏ប្រសើរបំផុតនៅក្នុងបរិបទដ៏ពេញលេញនៃជិវិត ដែលពង្រីកឡើងហួសពីជីវិតក្នុងលោការបស់យើងនេះ ហើយបន្តជារៀងរហូត ពីព្រោះវិញ្ញាណក្ខន្ធរបស់យើងរីកចម្រើនទូទាំងពិភពទាំងអស់របស់ព្រះ។ ក្នុងដំណើរការនៃការអប់រំ ដែលផ្ទុយពីការហ្វឹកហ្វឺនផ្នែកបច្ចេកទេស អ្នកចូលរួមទាំងឡាយគួរបង្កើនការយល់ដឹងពីអត្ថន័យនិងភាពសំខាន់នៃអ្វីដែលពួកគេកំពុងធ្វើ។បទពិសោធន៍បានបញ្ជាក់ថាមានតែនៅពេលមនសិការរីកចម្រើនតែមួយគត់ដែលពួកគេនឹងមើលឃើញខ្លួនពួកគេជា "ម្ចាស់" ដែលទទួលខុសត្រូវ សកម្មនៃការរៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេ។

មេរៀននីមួយៗនៃជំពូកនេះចាប់ផ្តើមជាមួយនឹងព្រះវចនៈពីរមួយទៅបីព្រះវចនៈ ដែលដកស្រង់ចេញពីសំណេរបាហៃជាច្រើនបន្ទាប់មកមានលំហាត់មួយចំនួន។ ភាសានៃអត្ថបទដែលបានដកស្រង់ក្នុងវគ្គនេះគឺមានការទាមទារច្រើនជាងកាលពីពីរមេរៀនមុន។ តាមពិតមិនបានតម្រូវឱ្យក្រុមផ្តោតលើពាក្យពិបាកនានានោះទេ អ្នកសម្របសម្រួលចង់ធានាថាគ្រប់គ្នាយល់គោលគំនិតដែលបានបង្ហាញក្នុងមេរៀននីមួយៗដែលមានភាពយ៉ាងច្បាស់លាស់ពីអ្វី ដែលលំហាត់ទាំងឡាយព្យាយាមដើម្បីបង្ហាញឱ្យឃើញនោះ។

យោលតាមលក្ខណៈនៃប្រធានបទ លំហាត់ជាច្រើនរាប់បញ្ចូលទាំងឧទាហរណ៍ច្បាស់លាស់គឺពីរឬបីនិងឆ្ងាយពីគ្នា។ លំហាត់ភាគច្រើនលំអៀងទៅរកការប្រតិបត្តិនៅកម្រិតនៃគំនិតមួយ។ សំណួរខ្លះដែលលំហាត់ជាច្រើនផ្តល់ឱ្យគឺមិនអាចឆ្លើយភ្លាមៗបានទេឬមិនអាចឆ្លើយយ៉ាងក្បោះក្បាយនោះបានដែរ។ សំណួរទាំងនោះត្រូវបានគេណែនាំដើម្បីបង្កើនការយល់ដឹងអំពីប្រធានបទ ប្រសិនបើអ្នកចំណូលរួមគ្រាន់តែគិតអំពីសំណួរនានាបែបនេះ គោលបំណងនៃការរៀនសូត្រនឹងបានត្រូវបានគេបំពេញ។

មេរៀនបួនឬប្រាំដំបូងផ្តោតលើការទំនាក់ទំនងរវាងវិញ្ញាណក្ខន្ធនិងរូបរាងកាយ ដែលទាំងអស់នេះរួមគ្នាបង្កើតបានជាមនុស្សជាតិក្នុងជីវិតលោកានេះ។ ចំណុចកណ្តាលនៃគំនិតបានបង្ហាញក្នុងមេរៀនទាំងនេះគឺថា វិញ្ញាណក្ខន្ធមិន

មែនជាអង្គភាពផ្នែកនៃរូបរាងកាយទេ ភាពរួមបញ្ចូលរបស់វាជាមួយនឹងរូបរាងកាយអាចប្រៀបធៀបទៅនឹងពន្លឺដែលលេចឡើងក្នុងកញ្ចក់មួយអ៊ីចឹងដែរ។ ទោះបីជាធូលីគ្របដណ្តប់ផ្ទៃរបស់វាឬការបំផ្លាញជាយថាហេតុដល់កញ្ចក់ក្តីមិនអាចមានឥទ្ធិពលដល់ភាពរុងរឿងនៃពន្លឺរបស់វាបានទេ។ មរណភាពគ្រាន់តែជាការផ្លាស់ប្តូរនៃស្ថានភាពមួយ នៅពេលទំនាក់ទំនងរវាងរូបរាងកាយនិងវិញ្ញាណក្ខន្ធគឺត្រូវបានបែកចេញពីគ្នានោះ បន្ទាប់មកវិញ្ញាណក្ខន្ធរីកចម្រើនជាអមតៈឆ្ពោះទៅកាន់ព្រះដែលជាមាបនកម្មរបស់វា។

វគ្គនេះងាកទៅរកសំណួរពីគោលបំណងនៃជីវិតគឺដើម្បីស្គាល់ព្រះ ហើយនិងដើម្បីឈានដល់ព្រះវត្តមានរបស់ទ្រង់។ ការពិភាក្សានៅទីនេះឋិតនៅជុំវិញគោលគំនិតទូលំទូលាយពីរ។ ទីមួយគឺគោលបំណងនៃជីវិតរបស់យើងក្នុងលោកីយ៍នេះ ហើយទីពីរការធ្វើដំណើរនៃវិញ្ញាណក្ខន្ធក្រោយពេលមរណភាព។ វិញ្ញាណក្ខន្ធជាសញ្ញាមួយរបស់ព្រះហើយអាចឆ្លុះបញ្ចាំងពីព្រះនាមនិងកេតនភ័ណ្ឌទាំងអស់របស់ទ្រង់បាន។ ម្យ៉ាងទៀត សក្តានុពលដែលនៅក្នុងមនុស្សជាតិគឺជាធម្មជាតិនៅជាមួយនឹងមនុស្ស វាអាចត្រូវបានគេអភិវឌ្ឍដោយការជួយជ្រោមជ្រែងពីព្រះបរមសាស្តាទាំងឡាយរបស់ព្រះដែលព្រះបរមសាស្តាដ៏សន្តទាំងនោះដែលយាងមកពីយុគសម័យមួយទៅយុគសម័យមួយដើម្បីណែនាំមនុស្សជាតិ។ តាមរយៈការអប់រំផ្នែកស្មារតីព្រះបរមសាស្តាទាំងឡាយផ្តល់នូវរតនសម្បត្តិដែលកប់នៅក្នុងខ្លួនយើងនោះអាចត្រូវបានគេបង្ហាញឱ្យឃើញឡើងមក។

រីឯការទាក់ទងទៅនឹងការធ្វើដំណើរនៃវិញ្ញាណក្ខន្ធក្រោយពីមរណភាព លំដាប់នៃគំនិតជាច្រើនត្រូវបានបង្ហាញសម្រាប់អ្នកចំណូលរួមនានាដើម្បីគិតពិចារណាថាអ្នកទាំងនោះដែលមានភាពស្មោះត្រង់ជឿជាក់ចំពោះព្រះនឹងសម្រេចបាននូវសុភមង្គលពិត ដែលគ្មាននរណាម្នាក់ក្នុងចំណោមពួកយើងអាចធ្លាប់ដឹងពីភាពចុងបញ្ចប់ផ្ទាល់ខ្លួនរបស់យើងនោះទេ ដូច្នេះយើងគួរអភ័យទោសរវាងគ្នានឹងគ្នា ហើយមិនគួរមានអារម្មណ៍ថាយើងខ្ពង់ខ្ពស់ជាងអ្នកដទៃនោះឡើយ ព្រោះនៅក្នុងបរលោកដូចក្នុងពិភពនេះ វិញ្ញាណ្ខន្ធនឹងបន្តរីកចម្រើនជានិច្ច ហើយលក្ខណៈគុណសម្បត្តិផ្នែកស្មារតីដែលយើងបានអភិវឌ្ឍនៅទីនេះនឹងផ្តល់ជំនួយនិងជួយយើងនៅទីនោះ គឺថាយើងនឹងស្គាល់អ្នកជាទីស្រឡាញ់របស់យើងទាំងអស់ក្នុងអាណាចក្ររបស់ព្រះ យើងនឹងចងចាំជីវិតរបស់យើងក្នុងលោកិយនេះ ហើយយើងនឹងរីករាយសប្បាយចិត្តជាមួយនឹងមិត្តភក្តិប្រកបដោយសន្តភាពនិងប្រកបដោយវិញ្ញាណក្ខន្ធដ៏ពិសិដ្ឋថ្លៃថ្លា។

វគ្គនេះបញ្ចប់ជាមួយនឹងអត្ថបទដែលដកស្រង់ចេញពីព្រះរាជសំណេររបស់ព្រះបាហាអ៊ុលឡាហ៍ ដែលក្នុងនោះយើងត្រូវបានគេធានាពីផលប្រយោជន៍នៃបរលោក ហើយមិនអនុញ្ញាតការប្រែប្រួលនិងឱកាសទាំងឡាយនៃជីវិតនេះនាំយើងនូវភាពឈឺចាប់នោះទេ។ អ៊ីចឹងហើយអ្នកចំណូលរួមទាំងឡាយត្រូវបានគេស្នើសុំដើម្បីឆ្លុះបញ្ចាំងទៅភាពជាប់ជំពាក់ទាំងឡាយនៃអ្វីដែលពួកគេបានសិក្សាសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។



# ការស្វែងយល់ពីសំណោរបាហៃ

## គោលបំណង

ដើម្បីពង្រឹងទម្លាប់នៃការអានអត្ថបទទាំងឡាយដកស្រង់ពីសំណេរនានាដ៏ពិសិដ្ឋរៀងរាល់ថ្ងៃ និងឆ្លុះបញ្ចាំងលើអត្ថន័យរបស់ពួកវា។

**មេរៀនទី ១**

គោលបំណងនៃវគ្គនេះគឺដើម្បីជួយអ្នកក្នុងការអភិវឌ្ឍ និងពង្រឹងទម្លាប់នៃការអានអត្ថបទនានា ដែលដកស្រង់ចេញពីសំណេរទាំងពួងដ៏ពិសិដ្ឋរបស់ព្រះរៀងរាល់ថ្ងៃ និងឆ្លុះបញ្ចាំងពីអត្ថន័យរបស់ពួកវា។វគ្គនេះចាប់ផ្តើមជាមួយនឹងលំហាត់សាមញ្ញមួយ ដែលសុំឱ្យអ្នកអានសេចក្តីថ្លែងការមួយល្បះដែលដកស្រង់ចេញពីសំណេររបស់ព្រះជាច្រើនហើយឆ្លើយតបទៅនឹងសំណួរមួយដែលចម្លើយចំពោះសំណួរនេះគឺសេចក្តីថ្លែងការរបស់វានោះឯង។ ទោះបីជាវាគឺងាយស្រួលអនុវត្តលំហាត់នេះ នឹងជួយឲ្យអ្នកឆ្លុះបញ្ចាំងទៅលើអត្ថន័យនៃសេចក្តីថ្លែងការនានា ហើយទន្ទេញពួកវាឱ្យចាំមាត់ ។

" ភាពល្អប្រសើរនៃពិភពលោកអាចត្រូវបានគេបំពេញតាមរយៈអំពើល្អនិងបរិសុទ្ធ ហើយតាមរយៈចរិយាមារយាទសមរម្យនិងគួរឲ្យសរសើរ[១] " ។

១. តើភាពល្អប្រសើរនៃពិភពលោកអាចត្រូវបានគេបំពេញតាមរបៀបណា ? ______________

______________________________________________

______________________________________________

" ឱមនុស្សទាំងឡាយនៃភាពរុងរឿងអើយ! ចូរប្រុងប្រយ័ត្ន ចូរអ្នកកុំដើរតាមមាគ៌ាទាំងឡាយរបស់មនុស្សណាដែលពាក្យសម្តីទាំងពួងរបស់ពួកគេខុសពីអំពើនានារបស់ពួកគេ[២]"។

២. តើមាគ៌ាទាំងឡាយរបស់មនុស្សប្រភេទណាដែលយើងមិនត្រូវដើរតាម ? ______________

______________________________________________

______________________________________________

" ឱម្នាលបុត្រនៃមនុស្សលោកអើយ ! ចូរជម្រះបញ្ជីខ្លួនរបស់អ្នកឱ្យបានជារៀងរាល់ថ្ងៃ មុនពេលដែលអ្នកត្រូវបានកោះហៅអោយចូលខ្លួនទៅទទួលផល...[៣] " ។

៣. តើយើងគួរធ្វើអ្វីខ្លះមុនពេលគេកោះហៅឱ្យចូលខ្លួនទៅទទួលផល ? ______________

______________________________________________

______________________________________________

" ចូរនិយាយថា៖ ឱបងប្អូនអើយ! ចូរយកអំពើទាំងឡាយធ្វើជាគ្រឿងតុបតែងលម្អពិតរបស់អ្នក មិនមែនយកពាក្យសម្តី ធ្វើជាគ្រឿងតុបតែងលម្អពិតរបស់អ្នកឡើយ[៤]"។

៤. តើអ្វីខ្លះគួរជាគ្រឿងតុបតែងលម្អពិតរបស់យើង ? ______________________

______________________________________________

______________________________________________

**" ពាក្យពិសិដ្ឋទាំងឡាយ អំពើល្អនិងឯបរិសុទ្ធនានាអាចនាំយើងឱ្យឡើងដល់ឋានសួគ៌នៃភាព រុងរឿងទិ ៣៥"។**

៥. តើពាក្យពិសិដ្ឋ បរិសុទ្ធភាព និងអំពើល្អទាំងឡាយ អាចធ្វើអ្វីខ្លះ ? ____________________

____________________________________________________________

____________________________________________________________

## មេរៀនទី ២

ខាងក្រោមនេះមានលំហាត់មួយចំនួនទាក់ទងទៅនឹងព្រះវចនៈដែលអ្នកទើបតែបានអានចប់។ពួកវាបានមានបំណងដើម្បីជួយអ្នកឆ្លុះបញ្ចាំងបន្ថែមទៀតពីសារសំខាន់នៃអត្ថបទទាំងឡាយនៅក្នុងក្រុមរបស់អ្នកហើយមិនគួរត្រូវបានគេអនុវត្តលម្អិតពេកទេ។នេះមិនមែនមានន័យថារាល់លំហាត់ត្រូវការការពិភាក្សាគ្នាយូរនោះឡើយ។ទោះបីយ៉ាងណាក៏ដោយនៅពេលដែលលំហាត់ស្មុគស្មាញនោះអ្នកសម្របសម្រួលនៃក្រុមរបស់អ្នកនឹងជួយអ្នកក្នុងការស្វែងរកអត្ថន័យយ៉ាងហ្មត់ចត់។

១. នៅពេលអ្វីមួយគឺ "គួរឱ្យសរសើរ" វាគឺសមនឹងទទួលបានការសរសើរ។
តើខាងក្រោមនេះទង្វើណាខ្លះដែលគួរឱ្យសរសើរ ?

ក. ក្លាយជាបុគ្គលិកល្អម្នាក់ ? _______

ខ. គោរពអ្នកដទៃ ? _______

គ. ក្លាយជាអ្នកឧស្សាហ៍រៀនសូត្រ ? _______

ឃ. ក្លាយជាមនុស្សកុហក ? _______

ង. ក្លាយជាមនុស្សខ្ជិលច្រអូស ? _______

ច. បម្រើអ្នកដទៃ ? _______

២. តើឃ្លាថា " មុនពេលអ្នកត្រូវបានគេកោះហៅឱ្យចូលខ្លួនទៅទទួលផល " មានន័យដូចម្តេច ?

____________________________________________________________

៣. តើសេចក្តីថ្លែងការខាងក្រោមនេះមួយណាគឺពិត? ៖

_____មានមនុស្សល្អតិចណាស់ក្នុងពិភពលោក ដែលសកម្មភាពទាំងឡាយរបស់ពួកគេមិនមាន អានុភាព ។

_____ អ្វីមួយគឺត្រឹមត្រូវ នៅពេលដែលវាគឺឋិតក្នុងការយល់ស្របគ្នាជាមួយនឹងគំនិតរបស់អ្នកដទៃនោះ។

_____ អ្វីមួយគឺត្រឹមត្រូវ នៅពេលដែលវាឋិតនៅក្នុងការយល់ស្របគ្នាជាមួយនឹងការបង្ហាត់បង្រៀនទាំងឡាយរបស់ព្រះ ។

៤. តើមួយណាខាងក្រោមគឺជាអំពើល្អនិងបរិសុទ្ធ?

_____ថែរក្សានិងបង្ហាត់បង្រៀនក្មេងៗ

_____លួចគេ

_____បួងសួងសម្រាប់ភាពរីកចម្រើនរបស់អ្នកដទៃ

_____និយាយកុហកបន្តិចបន្តួច ដើម្បីឱ្យរួចខ្លួនពីបញ្ហា

_____ជួយអ្នកដទៃហើយរំពឹងថានឹងបានទទួលរង្វាន់

៥. តើស្ថានភាពភាពទាំងឡាយដូចខាងក្រោមមួយណា ដែលពាក្យសម្តីជាច្រើនរបស់មនុស្សម្នាក់ខុសពីទង្វើនានារបស់គាត់ឬនាងនោះ?

_____មនុស្សម្នាក់នៅតែបន្តនិយាយដដែលថា យើងទាំងអស់គ្នាគួរតែត្រូវរួបរួមសាមគ្គីគ្នា ប៉ុន្តែម្នាក់នេះប្រព្រឹត្តក្នុងវិធីមួយដែលបង្កើតជម្លោះទៅវិញ។

_____មនុស្សម្នាក់សរសើរពីតម្លៃនៃជីវិតស្អាតស្អំ ប៉ុន្តែម្នាក់នេះមានទំនាក់ទំនងផ្លូវភេទក្រៅពីជីវិតអាពាហ៍ពិពាហ៍

_____មនុស្សម្នាក់ប្រើប្រាស់គ្រឿងស្រវឹងយូរៗម្តង ខណៈពេលដែលគាត់ប្រកាសថាគាត់ប្រតិបត្តិតាមជំនឿសាសនាដែលហាមឃាត់ការសេពគ្រឿងស្រវឹង។

_____មនុស្សម្នាក់និយាយគាំទ្រពីភាពស្មើគ្នានៃបុរសនិងស្ត្រីប៉ុន្តែខ្លួនក្លាយជានិយោជិក ផ្តល់ប្រាក់ឱ្យស្ត្រីតិចជាងបុរសចំពោះការងារដែលដូចគ្នាទៅវិញ។

៦. តើបាបម្នាក់អាចសារភាពកំហុសចំពោះមនុស្សម្នាក់ទៀតដែរឬទេ ?

______________________________________________

៧. តើយើងគួរធ្វើយ៉ាងដូចម្តេចជំនួសនៃការសារភាព ?______________________

______________________________________________

៨. តើឃ្លាថា " ឋានសួគ៌នៃភាពរុងរឿងទិព្វ " មានន័យដូចម្តេច ? __________________

______________________________________________

៩. តើទង្វើអាក្រក់ទាំងឡាយមានឥទ្ធិពលអ្វីខ្លះលើពិភពលោក ? __________________

______________________________________________

១០. តើទង្វើអាក្រក់ទាំងឡាយមានឥទ្ធិពលអ្វីខ្លះលើអ្នកដែលបានប្រព្រឹត្តពួកវា ?________________

______________________________________________________________

**មេរៀនទី ៣**

ឥឡូវចូរអាននិងឆ្លុះបញ្ចាំងពីព្រះវចនៈទាំងឡាយខាងក្រោមដែលដកស្រង់ចេញពីសំណេរទាំងឡាយរបស់ព្រះ។ បន្ទាប់មកចូរព្យាយាមទន្ទេញព្រះវចនៈទាំងនោះ។

**" សច្ចធម៌គឺជាគ្រឹះនៃគ្រប់គុណធម៌របស់មនុស្សទាំងពួង[៦]" ។**

១. តើគ្រឹះនៃគ្រប់គុណធមិរបស់មនុស្សគឺជាអ្វី ?________________________________

______________________________________________________________

**" នៅក្នុងគ្រប់ពិភពរបស់ព្រះ បើគ្មានសច្ចធម៌ទេ ភាពរីកចម្រើននិងជោគជ័យគឺមិនអាចកើតឡើងដល់វិញ្ញាណក្ខន្ធណាម្នាក់ឡើយ[៧]" ។**

២. តើអ្វីមិនអាចកើតឡើងបាន បើគ្មានសច្ចធមិ ?________________________________

______________________________________________________________

**" ឱមនុស្សលោកអើយ! ចូរលម្អអណ្តាតរបស់អ្នកជាមួយនឹងសច្ចធម៌ ហើយតុបតែងវិញ្ញាណក្ខន្ធរបស់អ្នកជាមួយនឹងគ្រឿងតុបតែងលម្អនៃសុចរិត[៨]" ។**

៣. តើយើងគួរលម្អអណ្តាតរបស់យើងជាមួយនឹងអ្វី ?________________________________

៤. តើយើងគួរតុបតែងលម្អវិញ្ញាណក្ខន្ធរបស់យើងជាមួយអ្វី ?__________________________

**" ចូរធ្វើឱ្យភ្នែករបស់អ្នកស្អាតស្អំ ដៃរបស់អ្នកស្មោះត្រង់ អណ្តាតរបស់អ្នកសច្ចៈ និងដួងចិត្តរបស់អ្នកស្រស់ស្រាយភ្លឺថ្លា[៩]"។**

៥. តើយើងគួរធ្វើឱ្យភ្នែករបស់យើងដូចម្តេច?________________ដៃរបស់យើង?__________

អណ្តាតរបស់យើង?____________________ដួងចិត្តរបស់យើង? ___________________

**" ពួកគេដែលរស់នៅក្នុងរាជាណាចក្ររបស់ព្រះ ហើយត្រូវបានអង្គុយលើអាសនៈនៃភាពរុងរឿងគ្មានទីបញ្ចប់ទោះបីជាពួកគេឃ្លានជិតដាច់ពោះស្លាប់ក៏ដោយក៏ពួកគេនឹងមិនព្រមលូកដៃរបស់គេហើយចាប់យកទ្រព្យសម្បត្តិរបស់អ្នកជិតខាងរបស់គេដោយគ្មានការអនុញ្ញាតឡើយ បើទោះបីជាគាត់ជាមនុស្សគ្មានតម្លៃហើយអប្រិយក៏ដោយក៏គាត់មិនត្រូវយកដែរ[១០]"។**

៦. តើបាហៃមិនព្រមធ្វើអ្វីបើទោះបីជាគាត់កំពុងស្រេកឃ្លានជិតដាច់ពោះស្លាប់ហើយក៏ដោយនោះ ?______

**មេរៀនទី ៤**

អ្នកប្រហែលជាបានកត់សម្គាល់រួចហើយនៅក្នុងមេរៀនទី២ លំហាត់ខ្លះនៅក្នុងវគ្គគឺតម្រូវឲ្យមានចម្លើយហ្មត់ចត់។ក្នុងករណីបែបនេះប្រសិនបើមានមន្ទិលអំពីចម្លើយនោះ អ្នកសម្របសម្រួលក្រុមរបស់អ្នកប្រាកដជាអាចជួយឱ្យអ្នកនិងអ្នកចូលរួមទាំងឡាយដែលជាមិត្តស្និទ្ធស្នាលរបស់អ្នកឈានទៅរកសាមគ្គីភាពនៃគំនិត។ចំពោះលំហាត់ផ្សេងៗទៀតវាគឺជាការពិភាក្សាតែម្តង ដែលគឺមានតម្លៃហើយគ្មានចម្លើយជាក់លាក់ណាមួយត្រូវបានគេសង្ឃឹមទុកជាមុននោះទេ។នៅខាងក្រោមដូចតទៅនេះសំណួរលេខ៣ គឺជាប្រភេទទី១ រីឯលំហាត់លេខ៦ គឺជាប្រភេទ ទី២ ។

១. សច្ចធម៌គឺជាគ្រឹះនៃគ្រប់គុណធម៌ទាំងឡាយរបស់មនុស្ស។ ចូររកគុណធម៌ឲ្យបានប្រាំ ___
______
______

២. តើយើងអាចទទួលយកគុណធម៌ទាំងនេះដោយគ្មានសច្ចធម៌បានដែរឬទេ ?______
______

៣. តើសេចក្តីថ្លែងការណ៍ទាំងឡាយខាងក្រោមមួយណាគឺពិត ?

_____ មនុស្សម្នាក់អាចជាមនុស្សយុត្តិធម៌បាន បើទោះបីជាគាត់និយាយកុហកក៏ដោយ។
_____ មនុស្សម្នាក់ដែលលួចទ្រព្យសម្បត្តិគេ គឺជាមនុស្សដែលមានដៃស្មោះត្រង់ ។
_____ ដៃស្មោះត្រង់មួយគឺជាដៃដែលមិនប៉ះពាល់អ្វីដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ។
_____ ការអានសៀវភៅនិងទស្សនាវដ្តីអាសអាភាសគឺជាទង្វើផ្ទុយទៅនឹងឱវាទរបស់ព្រះបាហាអ៊ុលឡាហ៍ដែលមានបន្ទូលថាត្រូវមានភ្នែកស្អាតស្អំនោះ ។
_____ សច្ចធម៌មានន័យថាមិនមែនជាការនិយាយកុហក ។
_____ សុចរិតគឺជាគ្រឿងលម្អរបស់វិញ្ញាណក្ខន្ធ ។
_____ មនុស្សម្នាក់ដែលមិនមានសច្ចធម៌អាចរីកចម្រើនផ្នែកស្មារតី។
_____ វាមិនជាអ្វីទេដែលត្រូវនិយាយកុហកយូរៗម្តងនោះ ។
_____ ការលួចទ្រព្យគេគឺអាចទទួលយកបាននៅចំពោះព្រះភក្ត្ររបស់ព្រះ បើអ្នកនោះកំពុងតែស្រេកឃ្លាន ។
_____ ការយករបស់អ្វីមួយដោយគ្មានការអនុញ្ញាតពីម្ចាស់គេ ព្រោះតែគិតថាយើងនឹងប្រគល់ឱ្យ

ម្ចាស់របស់វាវិញនៅពេលក្រោយ នេះមិនមែនជាការលួចឡើយ។

_____ ពេលណាយើងប្រព្រឹត្តប្រកបដោយសុចរិតត្រឹមត្រូវ ហើយនៅពេលយើងមានភាពត្រឹមត្រូវ និងសច្ចភាពនោះបេះដូងរបស់យើងត្រូវបានគេធ្វើឱ្យស្រស់ស្រាយឡើង ។

_____ វាគឺមិនអាចទៅរួចទេសម្រាប់ភាពជោគជ័យនៃជំនួញមួយដោយគ្មានការបោកប្រាស់នោះ។

៤. តើវាអាចទៅរួចទេក្នុងការនិយាយកុហកចំពោះខ្លួនឯង ?

_______________________________________________

_______________________________________________

៥. តើយើងបាត់បង់អ្វីខ្លះនៅពេលណាដែលយើងនិយាយកុហក ?

_______________________________________________

_______________________________________________

៦. តើពិភពលោកនេះនឹងទៅជាយ៉ាងណា បើយើងទាំងអស់គ្នាសុទ្ធតែមានសច្ចធម៌និងសុចរិតនោះ?

_______________________________________________

_______________________________________________

## មេរៀនទី ៥

ចូរសិក្សានូវព្រះវចនៈដូចតទៅហើយព្យាយាមរៀនពួកវាដោយទន្ទេញឱ្យចាំមាត់។ ការទន្ទេញឲ្យចាំមាត់នូវព្រះវចនៈដែលដកស្រង់ពីសំណេរទាំងឡាយរបស់ព្រះគឺឧត្តមថ្លៃថ្លាណាស់ហើយ អ្នកក៏ត្រូវតែខំប្រឹងប្រែងធ្វើដូច្នេះឡើង។ ពិតប្រាកដណាស់មិនមែនគ្រប់គ្នា គឺអាចទន្ទេញអត្ថបទទាំងឡាយបានយ៉ាងងាយនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការខិតខំប្រឹងប្រែងជួយយើង ដើម្បីផ្ចិតឱ្យជាប់នូវគំនិតនានាក្នុងដួងចិត្តនិងគំនិតរបស់យើង ហើយបញ្ចេញពួកវាជាពាក្យជាច្រើន ដែលខិតជិតទៅរកអត្ថបទដើមបើអាចធ្វើបាននោះ។

> **"អណ្ដាតសប្បុរសធម៌ គឺជាមេដែកនៃដួងចិត្តរបស់មនុស្ស។ វាគឺជាអាហារនៃស្មារតី វាបានបិទបាំងពាក្យសម្ដីជាច្រើនប្រកបដោយអត្ថន័យ វាគឺជាប្រភពពន្លឺនៃគតិបណ្ឌិតនិងការយល់ដឹង[១១]" ។**

១. តើអណ្ដាតសប្បុរសធម៌អាចត្រូវបានគេពិពណ៌នាយ៉ាងដូចម្ដេច ?_______________

_______________________________________________

២. តើអានុភាពអ្វីខ្លះដែលអណ្ដាតសប្បុរសធម៌មានទៅលើពាក្យសម្ដីទាំងឡាយ ?__________

**" ឱអ្នកដែលជាទីស្រឡាញ់របស់ព្រះអើយ! នៅក្នុងយុគសម័យដ៏ពិសិដ្ឋរបស់ព្រះនេះ ជម្លោះនិងការមិនស្រុះស្រួលគ្នា មិនត្រូវបានអនុញ្ញាតឡើយ ។ គ្រប់អ្នកឈ្លានពានបង្អត់ខ្លួនរបស់ពួកគេ ពីកិត្តិគុណរបស់ព្រះ[១២]" ។**

៣. យោងទៅតាមព្រះវចនៈនេះ តើអ្វីដែលមិនត្រូវបានគេអនុញ្ញាតនៅក្នុងយុគសម័យដ៏ពិសិដ្ឋរបស់

ព្រះ? ______________________________

______________________________

៤. តើអ្នកដែលឈ្លានពានគេនឹងបានធ្វើអ្វីចំពោះខ្លួនគាត់នោះ ? ______________________________

______________________________

**" ក្នុងយុគសម័យរបស់ព្រះនេះគ្មានអ្វីអាចធ្វើឱ្យប៉ះពាល់ដ៏ខ្លាំងបំផុតចំពោះបុព្វហេតុសាសនាជាងការបែកបាក់គ្នានិង ចងកំហឹងដាក់គ្នា ការវិវាទគ្នា ការឃ្លាតឆ្ងាយពីគ្នា ព្រមទាំងការព្រងើយកន្តើយដាក់គ្នាក្នុងចំណោមអ្នកជាទីស្រឡាញ់របស់ព្រះនោះទេ[១៣]"។**

៥. តើស្ថានភាពទាំងឡាយអ្វីខ្លះដែលអាចធ្វើឱ្យប៉ះពាល់ដ៏ខ្លាំងបំផុតចំពោះបុព្វហេតុសាសនារបស់ព្រះនោះ?______________________________

______________________________

______________________________

**" ចូរកុំសប្បាយចិត្តជាមួយនឹងការស្តែងចេញនូវមិត្តភាពត្រឹមតែពាក្យសម្ដី ចូរធ្វើឱ្យបេះដូងរបស់អ្នកឆាបឆេះដោយមេត្តាធម៌ដល់មនុស្សគ្រប់គ្នាដែលឆ្លងកាត់តាមមាគ៌ារបស់អ្នក[១៤]"។**

៦. តើមិត្តភាពប្រភេទអ្វីមិនគួរផ្គាប់ចិត្តយើងនោះ ? ______________________________

៧. តើអ្វីគួរឆាបឆេះយ៉ាងត្រចះត្រចង់ក្នុងដួងចិត្តរបស់យើង ?______________________________

______________________________

**" នៅពេលណាមានគំនិតសង្គ្រាមកើតឡើងនោះ ចូរតបទៅវាវិញដោយគំនិតសន្តិភាពដ៏រឹងមាំ។គំនិតនៃភាពសម្អប់ត្រូវតែត្រូវបានគេបំផ្លាញដោយគំនិតនៃក្ដីស្រឡាញ់ដ៏ខ្លាំងក្លា[១៥]"។**

៨. គំនិតនៃសង្គ្រាមមួយ គួត្រូវបានគេតបទៅវិញជាមួយនឹងអ្វី ?______________________________

______________________________

៩. គំនិតនៃភាពសម្អប់មួយ គួត្រូវបានគេបំផ្លាញជាមួយនឹងអ្វី ?______________________________

______________________________________________

## មេរៀនទី ៦

ដោយចងចាំព្រះវចនៈទាំងឡាយខាងលើ ចូរអនុវត្តនូវលំហាត់ទាំងឡាយដូចខាងក្រោម ៖

១. ជុំមេដែកគឺជាពាក្យមួយទៀតសម្រាប់មេដែក។ តើនៅក្នុងមធ្យោបាយណាដែលអណ្ដាតសប្បុរសធម៌ស្ដែងចេញឱ្យដូចជាជុំមេដែកមួយ?______________________________

______________________________________________

២. តើសេចក្ដីថ្លែការខាងក្រោមណាដែលបណ្ដាលមកពីអណ្ដាតសប្បុរសធម៌នោះ?

______ " កុំខ្វល់ខ្ញុំ! "

______ " ហេតុអ្វីអ្នកមិនយល់អំពីរឿងនេះ? "

______ " តើអ្នកពេញចិត្តនឹងរង់ចាំបានទេលោក? "

______ " ក្មេងៗអីក៏យ៉ាប់ម្ល៉េះ! "

______ " អរគុណ អ្នកមានចិត្តល្អណាស់។ "

______ " ខ្ញុំមិនមានពេលទំនេរទេសម្រាប់អ្នកឥឡូវនេះ ។ ខ្ញុំរវល់។ "

៣. តើស្ថានភាពទាំងឡាយខាងក្រោមណាគឺបង្ហាញឱ្យឃើញពីការប៉ះទង្គិចនិងជម្លោះនោះ?

______មនុស្សពីរនាក់បញ្ចេញនូវគំនិតខុសគ្នាលើប្រធានបទមួយចំនួនក្នុងពេលពិភាក្សាគ្នា។

______ មនុស្សពីរនាក់ប្រែក្លាយជាខឹងនិងចោទប្រកាន់គ្នាទៅវិញទៅមកអំឡុងពេលពិភាក្សាគ្នា។

______ មនុស្សពីរនាក់ឈប់ចូលរួមការជួបជុំសូត្រធម៌ប្រចាំសប្ដាហ៍ពីព្រោះតែពួកគេមិននិយាយរកគ្នាទៅវិញទៅមក។

______សមាជិកជាច្រើននៃក្រុមសហការលើកគម្រោងការមួយ ត្អូញត្អែរ ម្នាក់ៗនិយាយថាអ្នកដទៃមិនអនុវត្តផ្នែករបស់ពួកគេនោះទេ។

៤. តើស្ថានភាពទាំងឡាយខាងក្រោមមួយណាបង្ហាញសញ្ញាទាំងឡាយនៃការឃ្លាតឆ្ងាយ?

______ មិត្តពីរនាក់ដើរកាត់ពីមុខគ្នានៅតាមផ្លូវតែមិនអើពើនឹងគ្នាទៅវិញទៅមក។

______ មនុស្សម្នាក់មកដល់កន្លែងការជួបជុំគ្នាស្ងួតត្រង់ធម៌ ហើយម្នាក់ៗស្វាគមន៍នាងយ៉ាងកក់ក្តៅ។
______ ទោះបីជាពួកគេសម្តែងការគួរសមពីម្នាក់ទៅម្នាក់សមាជិកពីរនាក់នៃក្រុមមួយនោះ គឺស្ទាក់ស្ទើរដើម្បីចូលរួមក្នុងគម្រោងការមួយជាមួយគ្នា។

៥. ចូរសម្រេចចិត្តថាសេចក្តីថ្លែងខាងក្រោមដូចតទៅនេះពិតឬមិនពិត ៖

______ មនុស្សម្នាក់គួរតែនិយាយឱ្យចំៗនូវអ្វីដែលគាត់គិតពីអ្នកដទៃ វាមិនមែនជាបញ្ហានោះទេបើចិត្តរបស់ពួកគេត្រូវបានគេធ្វើឱ្យអាក់អន់ចិត្តក៏ដោយ។
______ វាមិនជាអ្វីទេក្នុងការនិយាយកុហកដើម្បីបញ្ចៀសនូវជម្លោះនោះ។
______ ជម្លោះអាចត្រូវបានគេបញ្ចៀសបាន ដោយសេចក្តីស្រលាញ់និងចិត្តសប្បុរសធម៌។
______ ពាក្យសម្តីមានប្រសិទ្ធភាពច្រើននៅពេលណាដែលពួកវាត្រូវបាននិយាយប្រកបដោយក្តីស្រឡាញ់នោះ។
______ វាមិនមែនជាបញ្ហាទេក្នុងការវាយតបជាមួយនឹងនរណាម្នាក់ប្រសិនបើគាត់ចាប់ផ្តើមវាមុននោះ។
______ មនុស្សម្នាក់មានសិទ្ធិនិយាយចំៗ នៅពេលអ្នកដទៃមានជម្ងឺឬទុក្ខព្រួយនោះ។
______ វាមិនសមរម្យទេក្នុងការសើចចំអកដាក់អ្នកដទៃ នៅពេលណាដែលពួកគេធ្វើអ្វីមួយខុសឆ្គងនោះ។
______ នៅពេលណាមានអារម្មណ៍មិនស្រួលកើតមានឡើងរវាងមិត្តទាំងឡាយភាគីនីមួយៗគួរតែខំប្រឹងប្រែងដ៏ពិសេសមួយដើម្បីឱ្យពួកគេមានភាពស្និទ្ធស្នាលគ្នាឡើងវិញ។
______ នៅពេលណាមានអារម្មណ៍មិនស្រួលកើតមានឡើងរវាងមិត្តទាំងឡាយ ភាគីនីមួយៗគួរតែរង់ចាំរហូតទាល់តែភាគីម្ខាងទៀតព្យាយាមស្និទ្ធស្នាលគ្នាឡើងវិញ។

## មេរៀនទី ៧

ចូរអានព្រះវចនៈខាងក្រោមនេះហើយទន្ទេញពួកវាឲ្យចាំមាត់។

**“...ការនិយាយដើមគ្នាពន្លត់ពន្លឺនៃបេះដូង និងពន្លត់ជីវិតនៃវិញ្ញាណក្ខន្ធ[១៦]”។**

**“ ចូរកុំនិយាយអំពីបាបរបស់អ្នកដទៃ ដរាបណាខ្លួនអ្នកក៏ជាអ្នកប្រព្រឹត្តអំពើបាបដែរនោះ[១៧] ”។**

**“ ចូរកុំនិយាយរឿងអាក្រក់ដែលអ្នកផ្ទាល់មិនចង់ឮវាត្រូវបានគេនិយាយចំពោះអ្នកវិញនោះ ហើយចូរកុំពន្លើសកំហុសអ្នកដទៃដើម្បីកុំឱ្យកំហុសរបស់អ្នករីកធំឡើងៗ....[១៨]”។**

**“ឱម្នាលបុត្រនៃមនុស្សលោកអើយ!តើអ្នកអាចបំភ្លេចកំហុសផ្ទាល់ខ្លួនរបស់អ្នក ហើយរវល់ខ្លួនអ្នកទៅនឹង**

**កំហុសអ្នកដទៃយ៉ាងដូចម្ដេច?[១៩]”។**

១.	តើការនិយាយដើមគ្នាមានផលប៉ះពាល់អ្វីខ្លះដល់អ្នកដែលនិយាយដើមគេនោះ?______________

________________________________________________________________

២.	តើយើងគួរគិតពីអ្វីខ្លះ មុនពេលនិយាយពីកំហុសរបស់អ្នកដទៃនោះ?

________________________________________________________________

________________________________________________________________

៣.	តើនឹងមានអ្វីកើតឡើងចំពោះយើង ប្រសិនបើយើងនិយាយពន្លើសពីកំហុសរបស់អ្នកដទៃ ?

________________________________________________________________

៤.	តើយើងគួរចងចាំអ្វីខ្លះ នៅពេលដែលយើងគិតពីកំហុសទាំងឡាយរបស់អ្នកដទៃ ?

________________________________________________________________

## មេរៀនទី ៨

ជាមួយនឹងព្រះវចនៈទាំងឡាយខាងលើដែលដក់ក្នុងចិត្ត ចូរអនុវត្តនូវលំហាត់ទាំងឡាយដូចខាងក្រោម៖

១.	តើនឹងមានអ្វីកើតឡើងចំពោះការរីកចម្រើនផ្នែកខាងវិញ្ញាណក្ខន្ធរបស់មនុស្សម្នាក់នៅពេលដែលគាត់គិតតែពីកំហុសជាច្រើនរបស់អ្នកដទៃ?

________________________________________________________________

________________________________________________________________

២.	តើការនិយាយដើមគ្នាមានផលប៉ះពាល់អ្វីខ្លះដល់សហគមន៍?_____________________________

________________________________________________________________

៣.	តើអ្នកត្រូវធ្វើដូចម្ដេច នៅពេលមានមិត្តម្នាក់ចាប់ផ្ដើមនិយាយអំពីកំហុសរបស់មនុស្សម្នាក់ទៀតនោះ?__________________________________________________________

_____________________________________________________________

៤.	ចូរសម្រេចចិត្តថា តើសេចក្ដីថ្លែងការណ៍ទាំងឡាយខាងក្រោមមួយណាគឺពិត ៖

_____ នៅពេលយើងនិយាយអំពីកំហុសពិតរបស់នរណាម្នាក់នោះយើងគឺមិនមែនកំពុងនិយាយដើមគេទេ។

______ នៅពេលយើងនិយាយពីគុណសម្បត្តិគួរឱ្យសរសើររបស់មនុស្សម្នាក់និងកំហុសរបស់គាត់នៅពេលតែមួយនោះ យើងមិនមែនកំពុងនិយាយដើមគាត់នោះទេ ។

______ ការនិយាយដើមគ្នាបានក្លាយទៅជាការអនុវត្តធម្មតាក្នុងសង្គមរបស់យើង ហើយយើងគួរតែអភិវឌ្ឍន៍វិន័យដើម្បីបញ្ចៀសវា ។

______ ប្រសិនបើអ្នកស្តាប់សន្យាថានឹងមិននិយាយឡើងវិញនូវអ្វីដែលយើងនិយាយអំពីមនុស្សម្នាក់ផ្សេងទៀតនោះការនិយាយដើមមិនមានគ្រោះថ្នាក់អ្វីឡើយ ។

______ ការនិយាយដើមគ្នាគឺជាសត្រូវមួយដ៏ធំបំផុតនៃសាមគ្គីភាព ។

______ ប្រសិនបើយើងទទួលយកទម្លាប់និយាយអំពីរឿងអ្នកផ្សេងគ្រប់ពេលវេលាយើងអាចធ្លាក់ចូលទៅក្នុងការនិយាយដើមគ្នាយ៉ាងងាយ ។

______នៅពេលដែលសមត្ថភាពជាច្រើនរបស់មនុស្សផ្សេងៗគ្នាត្រូវបានគេពិភាក្សាគ្នាក្នុងកិច្ចប្រជុំរបស់ធម្មសភាចិត្តកម្មូលដ្ឋាន ដើម្បីនិយាយពីឈ្មោះសមាជិកទាំងឡាយរបស់សហគមន៍នេះគឺជាការនិយាយដើមគ្នា ។

______ នៅពេលណាយើងមានអារម្មណ៍ចង់និយាយដើមគេនោះ យើងគួរតែគិតអំពីកំហុសផ្ទាល់ខ្លួនរបស់យើងវិញ ។

______ នៅពេលណាយើងដឹងថាមាននរណាម្នាក់កំពុងតែធ្វើអ្វីមួយដែលមានគ្រោះថ្នាក់ដល់ជំនឿសាសនា យើងគួរតែពិភាក្សាគ្នាជាមួយនឹងសមាជិកទាំងឡាយរបស់សហគមន៍។

______ នៅពេលណាយើងដឹងថាមាននរណាម្នាក់កំពុងតែធ្វើអ្វីមួយដែលមានគ្រោះថ្នាក់ដល់ជំនឿសាសនាយើងគួរជម្រាបដល់ធម្មសភាចិត្តកម្មូលដ្ឋាន។

______វាមិនមែនជារឿងខុសអ្វីទេចំពោះគូស្វាមីភរិយាដែលបានរៀបការហើយនិយាយអំពីកំហុសរបស់អ្នកដទៃនោះ ពីព្រោះពួកគេមិនគួរមានអាថ៌កំបាំងចំពោះគ្នាទៅវិញទៅមកឡើយ។

## មេរៀនទី៩

គោលបំណងនៃវគ្គនេះដូចដែលបានពោលពីខាងដើមរួចមកហើយ គឺដើម្បីជួយអ្នកចំណូលរួមទាំងឡាយ ចំពោះភាពខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីអភិវឌ្ឍ និងពង្រឹងទម្លាប់នៃការអានអត្ថបទទាំងឡាយដែលដកស្រង់ចេញពីសំណេរទាំងពួងដ៏ពិសិដ្ឋរបស់ព្រះជារៀងរាល់ថ្ងៃ ហើយឆ្លុះបញ្ចាំងពីអត្ថន័យរបស់វា។ ដើម្បីអានកំណាព្យទាំងឡាយរបស់ព្រះរាល់ព្រឹកនិងល្ងាចនោះគឺជាការបង្ហាត់បង្រៀនមួយរបស់ព្រះបាហាអ៊ុលឡាហ៍ដែលជួយអភិវឌ្ឍស្មារតីរបស់យើង។អត្ថបទខាងក្រោមរំលឹកយើងពីពរសព្វសាធុការជាច្រើនដែលយើងបានទទួលពីការបំពេញកាតព្វកិច្ចនេះ ហើយអ្នកក៏ត្រូវបានគេជម្រុញដើម្បីប្តេជ្ញាចងចាំវាដែរ៖

**"ចូរជ្រមុជខ្លួនរបស់អ្នកចូលទៅក្នុងមហាសមុទ្រនៃគតិពេចន៍ទាំងឡាយរបស់តថាគត ដើម្បីអ្នកអាចស្វែងរកអាថ៌កំបាំងទាំងឡាយរបស់វា ព្រមទាំងស្វែងរកគ្រាប់គុជទាំងអស់នៃគតិបណ្ឌិតដែលបានលាក់បំបាំងក្នុងបាតរបស់វា"[២០] ។**

បញ្ចប់វគ្គនេះ អ្នកមានបំណងចង់បានសៀវភៅនៃព្រះរាជសំណេររបស់ព្រះបាហាអ៊ុលឡាហ៍មួយក្បាលហើយអានសៀវភៅនោះជារៀងរាល់ថ្ងៃ។ ព្រះធម៌អាថ៌កំបាំងជាជម្រើសដ៏ល្អដំបូងគេ។

## REFERENCES


1. Bahá'u'lláh, cited by Shoghi Effendi, *The Advent of Divine Justice* (Wilmette: Bahá'í Publishing Trust, 2006, 2018 printing), par. 39, pp. 36–37.

2. *Gleanings from the Writings of Bahá'u'lláh* (Wilmette: Bahá'í Publishing Trust, 1983, 2017 printing), CXXXIX, par. 8, p. 345.

3. Bahá'u'lláh, *The Hidden Words* (Wilmette: Bahá'í Publishing Trust, 2003, 2012 printing), Arabic no. 31, p. 11.

4. Ibid., Persian no. 5, p. 24.

5. Ibid., Persian no. 69, p. 46.

6. 'Abdu'l-Bahá, cited by Shoghi Effendi, *The Advent of Divine Justice*, par. 40, p. 39.

7. Ibid.

8. *Gleanings from the Writings of Bahá'u'lláh*, CXXXVI, par. 6, p. 336.

9. *Tablets of Bahá'u'lláh Revealed after the Kitáb-i-Aqdas* (Wilmette: Bahá'í Publishing Trust, 1988, 2005 printing), no. 9.5, p. 138.

10. *Gleanings from the Writings of Bahá'u'lláh*, CXXXVII, par. 3, p. 338.

11. Ibid., CXXXII, par. 5, p. 327.

12. *Will and Testament of 'Abdu'l-Bahá* (Wilmette: Bahá'í Publishing Trust, 1944, 2013 printing), p. 26.

13. *Gleanings from the Writings of Bahá'u'lláh*, V, par. 5, p. 8.

14. From a talk given on 16 and 17 October 1911, published in *Paris Talks: Addresses Given by 'Abdu'l-Bahá in 1911* (Wilmette: Bahá'í Publishing, 2006, 2016 printing), no. 1.7, p. 6.

15. From a talk given by 'Abdu'l-Bahá on 21 October 1911, ibid., no. 6.7, p. 22.

16. *Gleanings from the Writings of Bahá'u'lláh*, CXXV, par. 3, p. 300.

17. *The Hidden Words*, Arabic no. 27, p. 10.

18. Ibid., Persian no. 44, p. 37.

19. Ibid., Arabic no. 26, p. 10.

20. *Gleanings from the Writings of Bahá'u'lláh*, LXX, par. 2, p. 154.



# ធម៌

## គោលបំណង

ដើម្បីឆ្លុះបញ្ចាំងពីសារសំខាន់នៃធម៌ និង ដើម្បីពង្រឹងទម្លាប់នៃការសូត្រធម៌ទៀងទាត់។

## មេរៀនទី ១

វគ្គទាំងឡាយនៃវិទ្យាស្ថានរូហ៊ីបានមានបំណង ដើម្បីជួយអ្នកចំណូលរួមទាំងឡាយដើរតាមមាគ៌ានៃការបម្រើ។ យើងដើរតាមមាគ៌ានេះបានជម្រុញដោយសតិហេតុផលនៃគោលបំណងភ្លោះពីរដើម្បីរីកចម្រើនផ្នែកស្មារតី និងសតិបញ្ញានិងដើម្បីចូលរួមចំណែកដល់ការផ្លាស់ប្តូរសង្គមឱ្យល្អប្រសើរ។ ទស្សនវិស័យនៃគោលបំណងរបស់យើងទាំងពីរនេះ គឺមិនអាចបំបែកចេញពីគ្នាបានទេ។ ព្រះបាហាអ៊ុលឡាហ៍ក្រើនរំលឹកដាស់តឿនយើងក្នុងអត្ថបទមួយថាៈ

**"ចូរកុំអំពល់ប្រាណរបស់អ្នកចំពោះភាពខ្វល់ខ្វាយផ្ទាល់ខ្លួនរបស់អ្នកទាំងឡាយចូរធ្វើឱ្យគំនិតរបស់អ្នកត្រូវបានគេចងភ្ជាប់ទៅនឹងអ្វីដែលធ្វើឱ្យជោគវាសនាទាំងឡាយ នៃមនុស្សជាតិល្អប្រសើរឡើងវិញ ហើយធ្វើឱ្យដួងចិត្តនិងវិញ្ញាណក្ខន្ធទាំងឡាយរបស់មនុស្សជាតិពិសិដ្ឋសន្តឡើង។[១] "**

ក្នុងអត្ថបទមួយផ្សេងទៀត ទ្រង់ធ្វើឱ្យច្បាស់ថាៈ

**"...គោលបំណងនៃការបង្កើតមនុស្សពីភាពគ្មានអ្វីទាំងអស់ គឺដើម្បីពួកគេនឹងធ្វើកិច្ចការសម្រាប់ភាពល្អប្រសើរនៃពិភពលោកនិងរស់នៅជាមួយគ្នាក្នុងភាពស្រុះស្រួលគ្នានិងសុខុដុមរមនានឹងគ្នា។[២]"**

ទាក់ទងទៅនឹងលក្ខខណ្ឌខាងក្នុងរបស់យើង ទ្រង់ប្រកាសថាៈ

**"បេះដូងបរិសុទ្ធគឺដូចជាកញ្ចក់មួយ ចូរសម្អាតវាជាមួយនឹងការដុសខាត់នៃក្តីស្រឡាញ់ និងការកាត់ផ្តាច់ចេញពីអ្វីៗទាំងអស់ក្រៅពីព្រះ ដើម្បីព្រះអាទិត្យពិតប្រាកដអាចបញ្ចេញពន្លឺនៅទីនោះ ហើយអរុណ្ណោទ័យអមតៈអាចបញ្ចេញពន្លឺនៅទីនោះដែរ ។[៣] "**

ហើយអង្គពិសិដ្ឋអាប់ឌុលបាហា មានព្រះបន្ទូលប្រាប់យើងថាៈ

**"បេះដូងរបស់អ្នកទាំងអស់គ្នាត្រូវតែបរិសុទ្ធហើយបំណងរបស់អ្នកទាំងឡាយត្រូវតែមានភាពស្មោះត្រង់ដើម្បីអ្នកអាចក្លាយជាអ្នកទទួលយកនូវការប្រទានឱ្យដ៏ពិសិដ្ឋទាំងឡាយ[៤] "។**

១. តើការគិតនិងការខ្វល់ខ្វាយទាំងឡាយរបស់យើងគួរទៅលើអ្វី?

________________________________________

________________________________________

២. សម្រាប់គោលបំណងអ្វីដែលយើងបានចេញពីភាពគ្មានអ្វីទាំងអស់ចូលទៅក្នុងពិភពមានជីវិត?

________________________________________

________________________________________

________________________________________________________________

៣. តើយើងគួរសម្អាតកញ្ចក់នៃបេះដូងរបស់យើងជាមួយនឹងអ្វី?________________________

________________________________________________________________

៤. តើលក្ខខណ្ឌអ្វីខ្លះដែលស្រូបយកការប្រទានទាំងឡាយដ៏ពិសិដ្ឋ?________________________

________________________________________________________________

៥. តើខាងក្រោមមួយណាគឺពិត?

- ដំបូងអ្នកគួរតែថែរក្សាខ្លួនរបស់អ្នក ហើយបន្ទាប់មកអ្នកអាចថែរក្សាអ្នកដទៃ។
- ប្រសិនបើអ្នកតែងតែជួយអ្នកដទៃ អ្នកនឹងបាត់បង់ចក្ខុវិស័យនៃគោលដៅផ្ទាល់ខ្លួនរបស់អ្នក។
- អ្នកគឺជាមិត្តជិតស្និទ្ធបំផុតរបស់អ្នក។
- អ្វីដែលសំខាន់បំផុតគឺការស្វែងរកនូវអ្វីដែលធ្វើឱ្យអ្នកសប្បាយចិត្ត។
- ចូរធ្វើតាមសុបិន្តទាំងឡាយរបស់អ្នក ហើយពួកវានឹងនាំអ្នកទៅរកសុភមង្គល។
- ដរាបអ្នកមិនធ្វើឱ្យអ្នកដទៃឈឺចាប់អ្វីដែលអ្នកធ្វើគឺមិនបញ្ហាទេ។
- វាគឺត្រឹមត្រូវសម្រាប់គោលបំណងអាត្មានិយមរបស់អ្នកដរាបណាអ្នកធ្វើអំពើល្អមួយចំនួនក្តី។

## មេរៀនទី ២

ជំនឿស៊ុបមួយដែលជាចំណុចកណ្តាលនៃគោលបំណងភ្លោះរបស់យើងគឺថាយើងទាំងអស់គ្នាត្រូវបានគេបង្កើតឡើងយ៉ាងឧត្តម។ ព្រះបាហាអ៊ុលឡាហ៍មានព្រះរាជបន្ទូលថា៖

**"ឱម្នាលបុត្រនៃស្មារតីអើយ!តថាគតបានបង្កើតអ្នកឡើងមកយ៉ាងសម្បូរបំផុតហេតុដូចម្តេចក៏អ្នកនាំប្រាណឱ្យធ្លាក់ចូលក្នុងភាពក្រក្រី? តថាគតបានតុបតែងរូបអ្នកឡើងមកយ៉ាងឧត្តមម្តេចក៏អ្នកបន្ថោកខ្លួនអ្នកទៅវិញ? តថាគតបានផ្តល់ជីវិតរបស់អ្នកមកពីចំណេះដឹងដ៏ពិសិដ្ឋ ហេតុដូចម្តេចក៏អ្នកទៅស្វែងរកវិជ្ជាពីអ្នកដទៃទៅវិញអ៊ីចឹង? យើងបានសូន្យរូបអ្នកមកពីមត្តិការនៃក្តីស្រឡាញ់ តើអ្នកអំពល់ប្រាណជាមួយនឹងអ្នកដទៃបានដោយរបៀបណាទៅវិញ?ចូរបែចក្ខុរបស់អ្នកមកកាន់រូបអ្នកនោះអ្នកនឹងបានឃើញតថាគតឋិតនៅជាមួយនឹងរូបអ្នកដោយតេជះស្គាំនិងគង់នៅជានិច្ចដោយបារមីនៃអង្គឯង[៥]"។**

ការបំពេញចន្លោះខាងក្រោមនឹងជួយអ្នកឆ្លុះបញ្ចាំងពីអត្ថបទនេះ។

**"ឱម្នាលបុត្រនៃស្មារតីអើយ!តថាគតបានបង្កើតអ្នកឡើងមកយ៉ាង____________ហេតុដូចម្តេចក៏អ្នកនាំប្រាណឱ្យ___________ក្នុង______________? ____________បាន__________រូបអ្នក_____ _________________ម្តេចក៏អ្នក______________ទៅវិញ? តថាគតបានផ្តល់ជីវិតរបស់អ្នកមកពី____________ដ៏ពិសិដ្ឋ ហេតុដូចម្តេចក៏អ្នកទៅស្វែង_____________ពីអ្នកដទៃទៅវិញអ៊ីចឹង? យើង____________មកពីមត្តិការនៃ__________ តើអ្នក________________ជាមួយនឹង________ _________បានដោយរបៀបណាទៅវិញ?ចូរបែ______របស់អ្នកមកកាន់__________________**

នោះអ្នកនឹងបានឃើញគ________បិតនៅជាមួយ____________ ដោយ___________និងគង់នៅជានិច្ច _____________នៃអង្គឯង។

ដើម្បីមានភាពស្មោះត្រង់ចំពោះសេចក្តីថ្លៃថ្នូរដល់វិញ្ញាណក្ខន្ធរបស់យើង យើងត្រូវតែងាកទៅរកព្រះដែលជាប្រភពនៃការបង្កើតរបស់យើង ហើយស្វែងរកការពន្យល់ពីទ្រង់ ។ មធ្យោបាយដែលគួរឱ្យទុកចិត្តបំផុតក្នុងចំណោមមធ្យោបាយទាំងឡាយដែលគួរឱ្យទុកចិត្តបំផុតនោះគឺដើម្បីសម្រេចរឿងនេះគឺតាមរយៈការសូត្រធម៌។លោកស៊ូហ្គីអែហ្វិនឌី ជាអ្នកគាំពារនៃជំនឿសាសនាបាហៃប្រាប់យើងថា គោលបំណងចម្បងរបស់វាគឺ " ការអភិវឌ្ឍនៃបុគ្គលនិងសង្គមជាតិ តាមរយៈការទទួលយកគុណធម៌ទាំងឡាយ និងអានុភាពនានាផ្នែកស្មារតី។ វាគឺជាវិញ្ញាណក្ខន្ធរបស់មនុស្សដែលត្រូវតែត្រូវបានគេផ្គត់ផ្គង់ជាដំបូង។ ហើយការសូត្រធម៌ដែលជាអាហារផ្នែកស្មារតីនេះអាចជាគ្រឿងផ្គត់ផ្គង់ដ៏ប្រសើរបំផុតផងដែរ[៦]"។

**មេរៀនទី ៣**

ព្រះគឺទ្រង់ញាណគ្រប់យ៉ាងហើយគឺប្រកបដោយបញ្ញាញាណគ្រប់យ៉ាង។ ទ្រង់បានបង្កើតយើងហើយទ្រង់ឈ្វេងយល់អ្វីៗក្នុងបេះដូងរបស់យើងនិងអ្វីដែលល្អបំផុតសម្រាប់យើង។ ទ្រង់មិនត្រូវការការសូត្រធម៌ទាំងឡាយរបស់យើងនោះទេ។ចុះហេតុអ្វីយើងសូត្រធម៌?

អង្គពិសិដ្ឋអាប់ឌុលបាហាថ្លែងថា៖
"នៅក្នុងការសូត្រធម៌ដ៏ខ្ពង់ខ្ពស់បំផុត មនុស្សសូត្រធម៌សម្រាប់តែក្តីស្រលាញ់នៃព្រះប៉ុណ្ណោះ មិនមែនព្រោះតែពួកគេភ័យខ្លាចទ្រង់ឬធ្លាក់ទៅនរកឬប្រាថ្នាចង់បានរង្វាន់ឬទៅឋានសួគ៌នោះទេ...នៅពេលមនុស្សម្នាក់ធ្លាក់ក្នុងក្តីស្រលាញ់ជាមួយមនុស្សម្នាក់ផ្សេងទៀត វាមិនអាចទៅរួចសម្រាប់គាត់ ដែលមិនឲ្យគាត់និយាយពីឈ្មោះនៃអ្នកជាទី ស្រលាញ់របស់គាត់ឡើយ។ តើវាលំបាកច្រើនជាងនេះប៉ុនណាដែលគាត់មិននិយាយពីព្រះនាមរបស់ព្រះនៅពេលដែលគាត់ស្រលាញ់ទ្រង់ហើយនោះ... ។ មនុស្សដែលប្រកបដោយស្មារតីមិនស្វែងរកការសប្បាយរីករាយណាក្រៅពីការរំលឹកពីព្រះនោះទេ[៧] " ។

ហើយក្នុងការឆ្លើយតបទៅនឹងសំណួរមួយ ទ្រង់ពន្យល់ថា៖
"បើមិត្តណាម្នាក់ស្រឡាញ់មិត្តម្នាក់ផ្សេងទៀតតើវាមិនមែនជារឿងធម្មតាទេឬនៅពេលគាត់ចង់និយាយថាគាត់ស្រឡាញ់អ្នកនោះ? ទោះបីជាគាត់ដឹងថាមិត្តម្នាក់នោះដឹងពីសេចក្តីស្រលាញ់របស់គាត់ក៏ដោយ តើគាត់នៅតែមិនចង់ប្រាប់ពីសេចក្តីស្រលាញ់ទេឬ?...។ វាគឺជាការពិតណាស់ ដែលព្រះឈ្វេងយល់នូវសេចក្តីប្រាថ្នានៃគ្រប់ដួងចិត្តទាំងអស់ ប៉ុន្តែសន្ទុះនៅក្នុងការសូត្រធម៌ គឺជារឿងធម្មតាមួយ ដែលផុសចេញពីសេចក្តីស្រលាញ់របស់មនុស្សទៅកាន់ព្រះ[៨]" ។

១. ចូរបំពេញប្រយោគដូចតទៅនេះ ៖

ក. នៅក្នុងការសូត្រធម៌________________មនុស្ស____________សម្រាប់តែ___________

នៃព្រះប៉ុណ្ណោះមិនមែនព្រោះតែពួកគេភ័យខ្លាចទ្រង់ឬ______________ប្រាថ្នាចង់____________ ឬ____________________________។

ខ. នៅពេលមនុស្សម្នាក់ធ្លាក់__________________ ជាមួយមនុស្សម្នាក់ផ្សេងទៀត វាមិន_________ សម្រាប់គាត់ដែលមិនឲ្យគាត់________________ នៃអ្នក________________________ ឡើយ។តើវា______________ច្រើនជាងនេះប៉ុនណាដែលគាត់មិននិយាយពីព្រះនាមរបស់_____ នៅពេលដែលគាត់_________________ទ្រង់ហើយនោះ។

គ. មនុស្សដែលប្រកបដោយស្មារតីមិនស្វែងរក__________________________ណាក្រៅពីការ _____________ពីព្រះនោះទេ។

២. ហេតុអ្វីយើងសូត្រធម៌?______________________________________________________________

______________________________________________________________

៣. តើឃ្លាថា "ការរំលឹកដល់ព្រះ" មានន័យដូចម្ដេច? ___________________________________________

______________________________________________________________

៤. តើអ្វីគឺជាបំណងប្រាថ្នាប្រកបដោយចិត្តក្លៀវក្លាបំផុតរបស់មនុស្សម្នាក់ដែលស្រឡាញ់មនុស្សម្នាក់ទៀត? _____

______________________________________________________________

៥. តើសន្ទុះនៃការសូត្រធម៌ចេញមកពីអ្វី? ___________________________________________

**មេរៀនទី ៤**

នៅក្នុងធម៌ដែលត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍ ចូរយើងអានដូចតទៅះ

**"ទូលបង្គំទទួចដល់ព្រះអង្គ...សូមឲ្យការសូត្រធម៌របស់ទូលបង្គំក្លាយជារងើកភ្លើងដែលដុតបំផ្លាញរនាំងដែលបានបាំងទូលបង្គំពីសោភ័ណភាពរបស់ព្រះអង្គ ហើយធ្វើឱ្យការសូត្រធម៌របស់ទូលព្រះបង្គំក្លាយជាពន្លឺដែលដឹកនាំទូលបង្គំទៅដល់សាគរនៃវត្តមានរបស់ព្រះអង្គ[៩]" ។**

យើងសូមសុំព្រះនូវធម៌ដូចគ្នាថាះ
**"ឱព្រះរបស់ទូលបង្គំអើយ!សូមព្រះអង្គធ្វើឲ្យការសូត្រធម៌របស់ទូលបង្គំក្លាយទៅជាប្រភពទឹកនៃជីវិតដែលទូលបង្គំអាចរស់នៅក្នុងអធិបតេយ្យភាពរបស់ព្រះអង្គបានឋិតថេរជាដរាបហើយសូមឲ្យទូលបង្គំអាចនិយាយពីព្រះអង្គនៅគ្រប់ពិភពនៃពិភពរបស់ព្រះអង្គ[១០]"។**

១. តើក្នុងន័យអ្វីដែរការសូត្រធម៌អាចដូចជាភ្លើង?តើវាដុតបំផ្លាញអ្វី? ______________________________

២.	ចូរនិយាយពីរបាំងមួយចំនួនដែលបិទបាំងយើងពីព្រះ?

៣.	តើការសុត្រធម៌អាចដូចជាពន្លឺមួយដែរឬទេ? តើវានាំយើងទៅកន្លែងណា?

៤.	តើការសុត្រធម៌អាចដូចជាប្រភពទឹកមិនចេះរីងស្ងួតដែរឬទេ?
តើវាអាចផ្តល់អ្វីខ្លះមកលើវិញ្ញាណក្ខន្ធរបស់យើង?

**មេរៀនទី ៥**

ចូរអាននិងឆ្លុះបញ្ចាំងនូវព្រះបន្ទូលរបស់អង្គពិសិដ្ឋអាប់ឌុលបាហាខាងក្រោមនេះ ៖

**"នៅក្នុងពិភពលោកីយ៍នេះគ្មានអ្វីផ្អែមជាងការសូត្រធម៌ឡើយ។ មនុស្សត្រូវតែរស់នៅក្នុងភាវៈនៃការសូត្រធម៌។ ស្ថានភាពដ៏ពិសិដ្ឋបំផុតគឺស្ថានភាពនៃការសូត្រធម៌និងការអង្វរករ។ ការសូត្រធម៌គឺជាការសន្ទនាជាមួយនឹងព្រះ។ សមិទ្ធិកម្មដ៏ធំបំផុតឬភាវៈដ៏ផ្អែមបំផុតគឺគ្មានអ្វីក្រៅពីការសន្ទនាជាមួយនឹងព្រះទេ។ វាបង្កើតស្មារតីបង្កើតការយកចិត្តទុកដាក់និងអារម្មណ៍ទិព្វហើយវាបង្កើតការចាប់អារម្មណ៍ថ្មីនៃអាណាចក្ររបស់ព្រះព្រមទាំងបង្កើតបញ្ញាខ្ពង់ខ្ពស់ឡើង[១១] "។**

១.	តើអ្វីជាភាវៈដ៏ផ្អែមបំផុតនៅក្នុងពិភពលោកីយ៍នេះ?

២.	តើឃ្លាថា " ភាវៈនៃការសូត្រធម៌ " មានន័យដូចម្តេច ?

៣.	ចូររៀបរាប់ពីទម្លាប់ខ្លះៗ ដែលបានបង្កើតឡើងដោយការសូត្រធម៌ ។

៤.	ចូររំលឹកព្រះវចនៈទាំងឡាយដែលអ្នកបានសិក្សាពីរឬបីមេរៀនរួចមកហើយ និងចូរសរសេរប្រាំឃ្លាស្តីពីលក្ខណៈនៃធម៌។

- ការសូត្រធម៌គឺជា
- ការសូត្រធម៌គឺជា
- ការសូត្រធម៌គឺជា

- កាសូត្រធម៌គឺជា______________________________________________

- ការសូត្រធម៌គឺជា______________________________________________

## មេរៀនទី ៦

ចូរអានបន្ទូលរបស់ព្រះបាហាអ៊ុលឡាហ៍ខាងក្រោមនេះ ហើយពិចារណាលើពួកវាៈ

"ឱអ្នកបម្រើរបស់តថាគតអើយ!ចូរសូត្រជាពាក្យកាព្យនូវកំណាព្យរបស់ព្រះដែលអ្នកបានទទួលរួច ហើយដូចដែលបានសូត្រដោយអ្នកទាំងឡាយ ដែលបានខិតជិតទៅរកព្រះអង្គ ដើម្បីធ្វើឱ្យសូរសៀងមានភាពពីរោះរណ្ដំនៃទំនុករបស់អ្នកអាចដុតបំភ្លឺវិញ្ញាណក្ខន្ធផ្ទាល់ខ្លួនរបស់អ្នកហើយទាក់ទាញបេះដូងនៃមនុស្សគ្រប់រូប។នរណាដែលសូត្រកំណាព្យ ដែលបាននិពន្ធដោយព្រះនៅកន្លែងដាច់ដោយឡែករបស់គាត់ទេវតាដែលនៅគ្រប់ទិសនៃព្រះដ៏មានអានុភាព នឹងសាយភាយនូវក្លិនក្រអូបនៃពាក្យពេចន៍ ដែលបានបញ្ចេញសម្លេងពីមាត់របស់គាត់ ហើយនឹងបណ្ដាលឲ្យបេះដូងនៃមនុស្សស្មោះត្រង់មានភាពញាប់ញ័រ។ នៅមុនដំបូងទោះបីជាគាត់នៅមិនដឹងពីប្រសិទ្ធភាពរបស់វា ប៉ុន្តែគុណធម៌នៃសេចក្ដីសមរម្យបានរក្សាទុកសម្រាប់គាត់ ដែលចាំបាច់មិនយូរមិនឆាប់ត្រូវបញ្ចេញអានុភាពរបស់វាទៅលើវិញ្ញាក្ខន្ធរបស់គាត់។ ដោយសារនេះហើយអាថ៌កំបាំងនៃការត្រាស់ដឹងរបស់ព្រះបានចេញក្រិតដោយគុណធម៌នៃព្រះរាជធន្ទះរបស់ទ្រង់ដែលជាប្រភពនៃ អំណាចនិងគតិបណ្ឌិត [១២] " ។

១. តើពាក្យថា " ការសូត្រមាន" មានន័យដូចម្ដេច ? ______________________________________________

______________________________________________

២. តើយើងគួរសូត្រនូវកំណាព្យរបស់ព្រះដោយរបៀបណា ? ______________________________________________

______________________________________________

៣. តើពាក្យថា " សូត្រ " មានន័យដូចម្ដេច ? ______________________________________________

______________________________________________

៤. តើពាក្យថា " ពង្រាយ " មានន័យដូចម្ដេច ? ______________________________________________

______________________________________________

៥. តើភាពពីរោះរណ្ដំនៃបទចម្រៀងរបស់យើងមានឥទ្ធិពលអ្វីខ្លះមកលើវិញ្ញាណក្ខន្ធផ្ទាល់ខ្លួនយើង? __________

______________________________________________

៦. តើភាពពីរោះនៃបទចម្រៀងរបស់យើងមានឥទ្ធិពលអ្វីខ្លះមកលើបេះដូងអ្នកដទៃ? ______________________

______________________________________________

## មេរៀនទី ៧

ប្រហែលជាអ្នកចង់ទន្ទេញអត្ថបទពីរខាងក្រោមដែលដកស្រង់ចេញពីធម៌មួយដែលបានត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍ថាៈ

" ឱព្រះជាព្រះរបស់ទូលបង្គំអើយ! សូមព្រះអង្គកុំទុតនូវអ្វីដែលជាសេចក្តីសង្ឃឹមរបស់ទូលបង្គំ ហើយនិងទង្វើរបស់ទូលបង្គំឡើយហើយសូមព្រះអង្គទតតែអ្វីដែលជាឆន្ទៈរបស់ព្រះអង្គដែលបានហ៊ុំព័ទ្ធឋានសួគ៌ និងលោកានេះ។ ឱព្រះជាម្ចាស់នៃគ្រប់សញ្ញាតិអើយ! តាមរយៈព្រះនាមដ៏អស្ចារ្យបំផុតរបស់ព្រះអង្គ ទូលបង្គំបានប្រាថ្នាចង់បានតែអ្វីដែលព្រះអង្គពេញព្រះទ័យ ហើយស្រលាញ់តែអ្វីដែលព្រះអង្គពេញព្រះទ័យ[១៣] " ។

"ព្រះអង្គគឺជាព្រះដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់ការសសើររបស់ទាំងនោះដែលបាននៅជិតព្រះអង្គដើម្បីធ្វើឱ្យពួកគេឡើងទៅកាន់ឋានសួគ៌នៃការនៅជិតព្រះអង្គ ឬសម្រាប់បក្សីនៃដួងចិត្តរបស់ពួកគេ ដែលបានឧទ្ទិសចំពោះព្រះអង្គ ដើម្បីបានទៅដល់មាត់ទ្វារនៃខ្លោងទ្វាររបស់ព្រះអង្គ។ ទូលបង្គំសូមធ្វើជាសាក្សីភាពថា ព្រះអង្គគឺមានភាពសន្តលើគ្រប់កេតនភ័ណ្ឌទាំងអស់ហើយមានភាពស័ក្តិសិទ្ធអស់លើព្រះនាមទាំងឡាយ។គ្មានព្រះណាក្រៅព្រះអង្គឡើយព្រះអង្គគឺជាព្រះដែលគួរឲ្យសរសើរបំផុតហើយនិងជាព្រះដែលប្រកបដោយភាពរុងរឿងគ្រប់យ៉ាង[១៤]" ។

**មេរៀនទី ៨**

អង្គពិសិដ្ឋអាប់ឌុលបាហាថ្លែងថា៖

"វាចាំបាច់ដែលអ្នកបម្រើដើម្បីសូត្រធម៌ទៅកាន់ព្រះនិងស្វែងរកជំនួយពីព្រះអង្គហើយដើម្បីអង្វរករព្រមទាំងអង្វរសុំជំនួយរបស់ទ្រង់ ។ ការធ្វើដូច្នេះ ក្លាយជាជួរនៃសេវគតិភាព ហើយព្រះអាទិទេពនឹងសម្រេចនូវអ្វីក៏ដោយដែលទ្រង់មានព្រះរាជបំណងប្រទានឱ្យ ដែលស្របតាមគតិបណ្ឌិតដ៏ឥតខ្ចោះរបស់ព្រះអង្គ[១៥]" ។

ហើយទ្រង់ពន្យល់ថា៖
ស្មារតីមានអានុភាពធម៌មានឥទ្ធិពលផ្នែកស្មារតី ។ ដោយសារនេះហើយយើងសូត្រធម៌ថា៖ " ឱព្រះ អង្គអើយ! សូមព្រះអង្គព្យាលបាលអ្នកជំងឺម្នាក់នេះ!"ជូនកាលព្រះនឹងឆ្លើយ។ តើវាសំខាន់សម្រាប់នរណាជាអ្នកសូត្រដែរឬទេ?ព្រះនឹងឆ្លើយទៅនឹងការសូត្រធម៌ពីអ្នកបម្រើគ្រប់គ្នាប្រសិនបើការបួងសួងនោះជាបន្ទាន់។ សេចក្តីមេត្តារបស់ទ្រង់គឺធំធេងណាស់ហើយគ្មានដែនកំណត់នោះឡើយ។ ទ្រង់ឆ្លើយគ្រប់ការបួងសួងនៃអ្នកបម្រើទាំងអស់របស់ទ្រង់។ទ្រង់ឆ្លើយតបទៅនឹងការបួងសួងនៃរុក្ខជាតិនេះ។រុក្ខជាតិបួងសួងដ៏មានសក្តានុពលថា "ឱ ព្រះអង្គអើយ!សូមទ្រង់ប្រទានទឹកភ្លៀងដល់ពួកយើងផង!" ព្រះឆ្លើយតបនូវការបួងសួងដូច្នេះរុក្ខជាតិក៏រីកលូតលាស់ស្រស់បំព្រង។ ព្រះនឹងឆ្លើយតបដល់ជនណាមួយ[១៦] " ។

វាជារឿងធម្មតាក្នុងការសូត្រធម៌ទាំងឡាយរបស់យើង យើងគួរតែស្នើសុំព្រះ ដើម្បីបំពេញសេចក្តីត្រូវការនានារបស់យើង។អ៊ីចឹងយើងសូត្រធម៌សម្រាប់សុខភាពរបស់យើងហើយនិងសុខភាពសម្រាប់អ្នកជាទីស្រឡាញ់របស់យើង យើងសូត្រធម៌សម្រាប់ភាពរីកចម្រើនផ្នែកសម្ភារ និងស្មារតីនៃក្រុមគ្រួសាររបស់យើង ហើយយើងសូត្រធម៌សម្រាប់ការណែនាំ។ យើងស្នើសុំសម្រាប់ភាពរឹងមាំ សម្រាប់ភាពជឿជាក់ និងសម្រាប់អំណះអំណាងក្នុងការដើរតាមមាគ៌ានៃការបម្រើ។ ក្នុងការសូត្រធម៌ដល់ព្រះ តាមពិតយើងគួរតែចងចាំគោលដៅរបស់យើងក្នុងជីវិត គឺថាជីវិតរបស់យើងត្រូវតែ

បញ្ចូលឆន្ទៈរបស់យើងជាមួយនឹងព្រះរាជឆន្ទៈរបស់ព្រះ។ អ៊ីចឹងហើយ យើងត្រូវតែសូត្រធម៌សម្រាប់ព្រះរាជឆន្ទៈរបស់ទ្រង់ឱ្យបានសម្រេច និងឱ្យបានរួចរាល់ដើម្បីទទួលយកវា។ ប្រសិនបើអ្នកប្តេជ្ញាចិត្តប្រតិបត្តិតាមបន្ទូលទាំងឡាយរបស់អង្គពិសិដ្ឋអាប់ឌុលបាហាឱ្យចាំនោះ បន្ទូលទាំងឡាយនឹងក្លាយជាប្រភពមួយនៃភាពរីករាយពិតហើយនិងធានាចំពោះអ្នកគ្រប់ពេលវេលាទាំងអស់ថា៖

"ឱអ្នកដែលកំពុងងាកមុខរបស់អ្នកឆ្ពោះទៅរកព្រះអើយ! ចូរបិទភ្នែករបស់អ្នកចំពោះវត្ថុទាំងអស់ ហើយបើកភ្នែកទាំងគូរឆ្ពោះទៅអាណាចក្ររបស់ទ្រង់ ដែលជាព្រះប្រកបដោយភាពរុងរឿងគ្រប់យ៉ាង។ ចូរសុំអ្វីក៏ដោយដែលអ្នកចង់បានពីទ្រង់តែមួយព្រះអង្គគត់ ចូរស្វែងរកអ្វីក៏ដោយដែលអ្នកស្វែងរកពីទ្រង់តែមួយអង្គគត់។គ្រាន់តែទ្រង់ទតតែមួយភ្នែតទ្រង់បានប្រទានឱ្យក្តីសង្ឃឹមរាប់ពាន់ម៉ឺន គ្រាន់តែសម្លឹងមួយភ្នែតទ្រង់បានព្យាបាលអ្នកឈឺរុំារ៉ៃរាប់ពាន់ម៉ឺនសែននាក់ឯណោះ គ្រាន់តែទ្រង់ងក់ព្រះកេសម្តង ទ្រង់បានធ្វើឱ្យធូរស្បើយគ្រប់អ្នករងរបួសស្នាមដែលឈឺចុកចាប់ក្នុងចិត្ត គ្រាន់តែទ្រង់ទតមើលត្រួសៗសោះ ទ្រង់បានដោះលែងបេះដូងទាំងឡាយពីច្រវ៉ាក់នៃភាពឈឺចាប់។ទ្រង់បានធ្វើអ្វីដូចដែលទ្រង់បានធ្វើដូចសព្វដងហើយតើយើងមានសំណាងអ្វីខ្លះ? ទ្រង់អនុវត្តព្រះរាជឆន្ទៈរបស់ទ្រង់ ទ្រង់បានសម្រេចនូវអ្វីដែលទ្រង់បានពេញព្រះទ័យ។ អ៊ីចឹងនោះភាពល្អប្រសើរសម្រាប់អ្នកដើម្បីបង្អោនកាយរបស់អ្នកក្នុងការទទួលយក ហើយដាក់ការទុកចិត្តលើព្រះដែលជាព្រះប្រកបដោយមេត្តាករុណាគ្រប់យ៉ាង[១៧]"។

## មេរៀនទី ៩

ពីអ្វីៗគ្រប់យ៉ាងដែលបានសិក្សារហូតមកដល់ពេលនេះ វាគឺច្បាស់ហើយថាការងាកមុខទៅរកព្រះក្នុងការសូត្រធម៌គឺជាសេចក្តីត្រូវការដ៏សំខាន់នៃជីវិតស្មារតីមួយ។តើវាផ្តេមពីពោះពិសេសយ៉ាងណា គឺការសូត្រធម៌ចំពោះព្រះភ្លាមៗក្រោយពេលភ្ញាក់ពីដំណេកនិងពេលយប់មុនពេលសម្រាកសម្រាន្តនោះ។ ពេលវេលាដែលយើងបានចំណាយសូត្រធម៌មួយថ្ងៃៗនិងចំនួននៃធម៌ដែលយើងបានសូត្រនោះ អាស្រ័យលើសេចក្តីត្រូវការរបស់យើង និងតម្រេកនៃស្មារតីរបស់យើង។នៅគ្រប់ឱកាស យើងអាចជ្រើសរើសពីធម៌ជាច្រើនដែលបានត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍ ព្រះបប និងអង្គពិសិដ្ឋអាប់ឌុលបាហា។ទោះបីជាយ៉ាងណាក៏ដោយ ព្រះបាហាអ៊ុលឡាហ៍បានត្រាស់បញ្ចេញនូវធម៌កាតព្វកិច្ចបីផងដែរ។ លោកស៊ូហ្គីអែហ្វិនឌី ថ្លែងថា៖

" ធម៌កាតព្វកិច្ចប្រចាំថ្ងៃមានចំនួនបី ។ ធម៌កាតព្វកិច្ចបទខ្លីមានតែមួយឃ្លាដែលត្រូវសូត្រតែម្តងក្នុងរយៈពេល ២៤ម៉ោងនៅពាក់កណ្តាលថ្ងៃ។ ធម៌កាតព្វកិច្ចបទមធ្យមដែលចាប់ផ្តើមជាមួយនឹងពាក្យថា 'ព្រះអាទិទេពគឺជាសក្ខីភាពដែលមិនមាននរណាផ្សេងទៀតក្រៅពីព្រះអង្គឡើយ' ត្រូវសូត្រ៣ដងក្នុងមួយថ្ងៃគឺនៅពេល ព្រឹក ថ្ងៃត្រង់ និង ពេលល្ងាច ។ ធម៌នេះត្រូវបានគេអមជាមួយនឹងសកម្មភាពរាងកាយនិងកាយវិការ។ ធម៌កាតព្វកិច្ចបទវែងគឺជាធម៌មួយ ដែលបរិយាយយ៉ាងល្អិតល្អន់បំផុតក្នុងចំណោមធម៌ទាំងបីនេះ ដែលត្រូវសូត្ររៀងរាល់ ២៤ម៉ោងម្តង ហើយនៅពេលណាក៏បានស្រេចតែអ្នកចង់សូត្រ ។

"  អ្នកជំនឿមានសិទ្ធិដោយសេរីក្នុងការជ្រើសរើសធម៌ណាមួយក្នុងចំណោមធម៌ទាំងបីនេះ  ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមកាតព្វកិច្ចនៃការសូត្រធម៌ណាមួយក្នុងចំណោមធម៌កាតព្វកិច្ចទាំងនោះ  ហើយព្រមទាំងអនុលោមទៅតាមការណែនាំជាក់លាក់ណាមួយ ដែលអាចអនុវត្តជាមួយនឹងការសូត្រធម៌នេះ[១៨]" ។

ហើយលោកបន្តទៀតថាៈ

"  ធម៌កាតព្វកិច្ចប្រចាំថ្ងៃទាំងនេះ  រួមជាមួយនឹងធម៌ជាក់លាក់មួយចំនួនផ្សេងទៀតមានដូចជា  ធម៌សុខភាពកថាខណ្ឌអាម៉ាត់  ដែលត្រូវបានប្រគល់ឲ្យដោយព្រះបាហាអ៊ុលឡាហ៍  ប្រកបដោយសក្តានុពលពិសេស និងមានសារៈសំខាន់ ហើយដូច្នេះធម៌ទាំងនេះត្រូវបានគេទទួលយកដូចគ្នា ហើយព្រមទាំងសូត្រដោយអ្នកជំនឿដែលជឿជាក់ឥតសង្ស័យនិងសេចក្តីទុកចិត្តតាមរយៈការសូត្រធម៌ទាំងនេះពួកគេអាចជួបជុំយ៉ាងជិតស្និទ្ធិជាមួយនឹងព្រះ ហើយអនុវត្តខ្លួនពួកគេដ៏ពេញលេញជាមួយនឹងធម្មសាស្ត្រនិងឱវាទរបស់ព្រះអង្គ[១៩]"។

ធម៌កាតព្វកិច្ចបី ដែលបានត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍ត្រូវសូត្រជាបុគ្គល។  ប្រភេទនៃធម៌ដែលសូត្រជុំគ្នាដែលជាធម៌កាតព្វកិច្ចប្រចាំថ្ងៃមួយត្រូវបានគេសូត្រជាក្រុមអាស្រ័យតាមទំនៀមទម្លាប់ដ៏ពិតប្រាកដមួយ ប៉ុន្តែមិនមានក្នុងសាសនាបាហៃនោះទេ។ ធម៌សម្រាប់មរណភាពគឺជាធម៌សូត្រជាក្រុមថា  ដដែលដោយបុគ្គលម្នាក់តែមួយគត់ដែលបានបញ្ជាក់ក្នុងច្បាប់បាហៃ។ធម៌នេះត្រូវបានគេសូត្រមុនការបញ្ចុះសាកសពដោយមនុស្សម្នាក់ក្នុងចំណោមអ្នកដែលមានវត្តមាននៅទីនោះ ចំណែកឯអ្នកដទៃទៀតឈរដោយស្ងៀមស្ងាត់ ។

១.	តើពាក្យថា "កាតព្វកិច្ច" មានន័យដូចម្តេច? ____________________

________________________________________

២.	តើធម៌កាតព្វកិច្ចប្រចាំថ្ងៃដែលព្រះបាហាអ៊ុលឡាហ៍បានត្រាស់បញ្ចេញមានប៉ុន្មាន? ____________

________________________________________

៣.	តើយើងគួរសូត្រធម៌ទាំងបីនេះជារៀងរាល់ថ្ងៃឬ? ____________________

________________________________________

៤.	ប្រសិនបើយើងជ្រើសរើសដើម្បីសូត្រធម៌កាតព្វកិច្ចបទវែង តើយើងគួរសូត្រប៉ុន្មានដងក្នុងមួយថ្ងៃ? ________

________________________________________

៥.	តើសូត្រប៉ុន្មានដង ប្រសិនបើយើងជ្រើសរើសធម៌កាតព្វកិច្ចបទមធ្យម? ____________________

________________________________________

៦.	តើសូត្រប៉ុន្មានដង ប្រសិនបើយើងជ្រើសរើសធម៌កាតព្វកិច្ចបទខ្លី? ____________________

________________________________________

៧.	ចូរនិយាយធម៌មួយចំនួនដែលមានអានុភាពដ៏ពិសេសៈ____________________

________________________________________

________________________________________

៨.	ចូរទន្ទេញធម៌កាតព្វកិច្ចបទខ្លី ប្រសិនបើអ្នកមិនទាន់ចងចាំនោះៈ

"បពិត្រព្រះជាម្ចាស់ទូលព្រះបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គបានបង្កើតទូលព្រះបង្គំមកដើម្បីឱ្យទូលព្រះបង្គំបានស្គាល់និងបូជាសក្ការៈចំពោះព្រះអង្គ។ ក្នុងខណៈនេះទូលព្រះបង្គំបានជ្រាបហើយនូវភាពទន់ខ្សោយរបស់ទូលព្រះបង្គំទៅនឹងបារមីដ៏បវររបស់ព្រះអង្គ ហើយនិងភាពក្រខ្សត់របស់ទូលព្រះបង្គំទៅនឹងទ្រព្យសម្បត្តិដ៏ធំធេងរបស់ព្រះអង្គ។"

"ពុំមានព្រះជាម្ចាស់ណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គជួយរំដោះទុក្ខភ័យនៃសត្វលោក ព្រះអង្គគង់នៅជានិច្ចដោយបារមីនៃព្រះអង្គឯង[២០]"។

៩. តើយើងបញ្ជាក់អ្វីខ្លះនៅក្នុងធម៌នេះ? ______________________________

______________________________

______________________________

______________________________

## មេរៀនទី១០

យើងគួរចងចាំថា ក្នុងការបន្ថែមទៅនឹងពរសព្ទសាធុការដែលយើងបានទទួលពីការគោរពតាមធម៌កាតព្វកិច្ចនិងនិងការទ្រទ្រង់ដែលយើងទទួលបានពីការសូត្រធម៌ផ្សេងៗទៀតជាលក្ខណៈបុគ្គលនោះ វិញ្ញាណក្ខន្ធរបស់យើងត្រូវបានលើកតម្កើងនៅពេលដែលយើងឮធម៌ទាំងឡាយ ដែលត្រូវបានគេកំពុងសូត្រនាពេលការជួបជុំគ្នា ទោះបីជាក្រុមតូចឬក្រុមធំក្តី។

ព្រះបាហាអ៊ុលឡាហ៍មានព្រះបន្ទូលប្រាប់យើងថា៖

"ចូរជួបជុំគ្នាប្រកបដោយភាពរីករាយបំផុតនិងប្រកបដោយមិត្តភាព ហើយសូត្រកំណាព្យទាំងឡាយដែលបានត្រាស់បញ្ចេញដោយព្រះបាហាអ៊ុលឡាហ៍ដែលជាព្រះប្រកបដោយក្តីករុណាបំផុត។ ដោយការធ្វើបែបនេះទ្វារទាំងឡាយនៃចំណេះដឹងពិតនឹងប្រាកដជាបើកចំហរចំពោះជីវិតខាងក្នុងរបស់អ្នក ហើយបន្ទាប់មកអ្នកនឹងដឹងថាវិញ្ញាក្ខន្ធរបស់អ្នកបានផ្តល់នូវភាពរឹងមាំឥតងាករេ រីឯបេះដូងរបស់អ្នកវិញត្រូវបានគេបំពេញជាមួយនឹងភាពរីករាយដ៏ត្រចះត្រចង់[២១] "។

យើងទាំងអស់គ្នាទទួលយកភាពរីករាយដ៏អស្ចារ្យពីចំណេះដឹងដែលនៅជុំវិញពិភពលោក ការជួបជុំគ្នាសូត្រធម៌ទាំងឡាយដែលក្នុងនោះមិត្តជាច្រើន និងអ្នកជិតខាងនានាមកជួបជុំគ្នា ដើម្បីទំនាក់ទំនងជាមួយនឹងព្រះកំពុងបង្កើនទ្វេឡើងដោយរាប់ពាន់ឯណោះ។ ធម្មសភាយុត្តិធម៌សកលសរសេរថា៖

**"ការជួបជុំគ្នាសូត្រធម៌គឺជាឱកាសទាំងឡាយដែលមនុស្សមួយចំនួនអាចជួបជុំគ្នា ស្រូបយកក្លិនក្រអូបឋានសួគ៌ ដឹងពីភាពផ្អែមពីរោះនៃធម៌ធ្វើសមាធិទៅលើបន្ទូលប្រកបដោយប្រឌិតញាណ ហើយហោះហើរតាមរយៈស្លាបទាំងពីរនៃស្មារតី ហើយនិងទំនាក់ទំនងជាមួយនឹងព្រះមួយព្រះអង្គ ដែលជាព្រះជាទីគោរពស្រឡាញ់បំផុត។ អារម្មណ៍នៃមិត្តភាពនិងបុព្វហេតុទូទៅត្រូវបានគេបង្កើតឡើងជាពិសេសក្នុងការសន្ទនាដ៏ខ្ពង់ខ្ពស់ប្រកបដោយស្មារតីដែលកើតឡើងជាធម្មតានៅពេលនោះ ហើយតាមរយៈការបួងសួងនេះ 'ទីក្រុងនៃបេះដូងរបស់មនុស្ស' អាចត្រូវបានគេបើក[២២]"។**

នៅពេលយើងមានអារម្មណ៍ចង់សូត្រធម៌ យើងគួរតែរង់ចាំមួយភ្លែតមុនពេលចាប់ផ្ដើមសូត្រ ដើម្បីព្យាយាមសម្អាតចិត្តរបស់យើងពីវត្ថុនានានៃលោកិយ៍នេះ។ ខណៈពេលសូត្រធម៌ យើងរក្សាគំនិតរបស់យើងផ្ដោតទៅលើព្រះ។ ក្រោយពីយើងបានសូត្រធម៌ចប់ យើងរក្សាភាពស្ងៀមស្ងាត់មួយរយៈសិនហើយក៏មិនប្ដូរទៅសកម្មភាពផ្សេងទៀតយ៉ាងរហ័សនោះដែរ។ គឺពិតដូចគ្នានោះដែរ នៅពេលយើងស្ដាប់ទៅនឹងការសូត្រធម៌របស់អ្នកដទៃក្នុងការជួបជុំគ្នា ។ នៅឱកាសទាំងឡាយបែបនេះ យើងរក្សានូវអាកប្បកិរិយាគោរពដ៏ជ្រាលជ្រៅ ហើយយកចិត្តទុកដាក់តាមពាក្យពេចន៍ទាំងឡាយយ៉ាងប្រត្យក្ស ដូចដែលយើងជាអ្នកដែលកំពុងសូត្រធម៌ទាំងនោះអ៊ីចឹងដែរ។

១. ជាមួយនឹងស្មារតីអ្វីខ្លះដែលយើងគួរជួបជុំជាមួយគ្នា នៅពេលសូត្រកំណាព្យទាំងឡាយរបស់ព្រះ?_______

_______________________________________________

២. តើនឹងមានប្រសិទ្ធភាពអ្វីខ្លះនៃការជួបជុំគ្នារបស់យើងដើម្បីសូត្រកំណាព្យទាំងឡាយរបស់ព្រះ? _________

_______________________________________________

៣. ការជួបជុំគ្នាសូត្រធម៌ទាំងឡាយគឺជាឱកាសជាច្រើនដែលមនុស្សមួយចំនួនអាច

- ________________________________
- ________________________________,
- ________________________________,
- ________________________________,
- ________________________________,ហើយ
- ________________________________,

៤. តើអារម្មណ៍ទាំងឡាយអ្វីខ្លះត្រូវបានបង្កើតឡើងនៅឯការជួបជុំគ្នាសូត្រធម៌នោះ?____________________

_______________________________________________

៥. តើប្រសិទ្ធភាពនៃការសន្ទនាដ៏ខ្ពង់ខ្ពស់ប្រកបដោយស្មារតីដែលជាធម្មតាកើតមានឡើងនៅឯការជួបជុំគ្នាសូត្រធម៌គឺជាអ្វី?_______________________________________________

_______________________________________________

៦. ចូរសរសេរពាក្យមួយចំនួនអំពីអាកប្បកិរិយាគួរឱ្យគោរពដែលយើងគួរបង្ហាញពេលសូត្រធម៌ ទោះជាសូត្រតែម្នាក់ឯង ឬក្នុងការជួបជុំគ្នាក្ដី។

_______________________________________________

## មេរៀនទី១១

វគ្គដំបូងនៃសៀវភៅនេះបានផ្តោតអារម្មណ៍លើទម្លាប់នៃការអានកំណាព្យដែលដកស្រង់ចេញពីព្រះរាជសំណេរទាំងឡាយជារៀងរាល់ថ្ងៃនិងសញ្ជឹងគិតពីអត្ថន័យទាំងនោះ។អ្នកបានផ្លុះបញ្ចាំងនៅទីនេះពីសារសំខាន់នៃធម៌ ហើយជាលទ្ធផលបានពង្រឹងទម្លាប់នៃការសូត្រធម៌ប្រចាំថ្ងៃ។ មេរៀនមុនបាននាំមកនូវការយកចិត្តទុកដាក់របស់អ្នកពីសារសំខាន់នៃការគោរពបូជារួមគ្នា។ទាំងអស់នោះហើយដែលអ្នកបានសិក្សារួចមក ហើយបានរៀបចំអ្នកដើម្បីអនុវត្តប្រសិនបើអ្នកចង់ សកម្មភាពដំបូងមួយលើមាគ៌ានៃការបម្រើគឺ ការរៀបចំជាម្ចាស់នៃការសូត្រធម៌ជុំគ្នាមួយ។

ជាជំហានដំបូង អ្នកអាចទន្ទេញធម៌បួនឬប្រាំ ហើយស្វែងរកឱកាសដើម្បីចែករំលែកធម៌ទាំងនោះជាមួយមិត្តពីរឬបីនាក់។ ដូចគ្នានេះដែរអ្នកអាចប្រាកដថាអ្នកចូលរួមជួបជុំគ្នាសូត្រធម៌យ៉ាងហោចណាស់មួយក្នុងសហគមន៍របស់អ្នក ហើយត្រូវបានគេរាប់ថាជាអ្នកគាំទ្រដ៏រីករាយសាទររបស់វា។ អ៊ីចឹងទីបំផុតនោះអ្នកអាចសម្រេចចិត្តដើម្បីរៀបចំការសូត្រធម៌ខ្លួនអ្នកផ្ទាល់អញ្ជើញមិត្តភក្តិរបស់អ្នក សមាជិកទាំងឡាយនៃគ្រួសារ និងអ្នកជិតខាងដើម្បីជួបជុំគ្នាទៀងទាត់សម្រាប់ការសូត្រធម៌និងមិត្តភាព។វាគឺមិនមែនជារឿងធម្មតាទេ សម្រាប់អ្នកចូលរួមពីរឬបីនាក់នៃវគ្គនេះ ដើម្បីចាប់ផ្តើមដូចជាការជួបជុំគ្នាសូត្រធម៌រួមគ្នានោះ។

ដូចដែលអ្នកអាចដឹងហើយថា មិនមានទម្រង់ទាំងឡាយណាបង្ហាញពីរបៀបការជួបជុំគ្នាសូត្រធម៌ត្រូវបានគេរៀបចំយ៉ាងណានោះទេ។ ប៉ុន្តែវាគឺច្បាស់ណាស់ថា ការជួបជុំរបស់មិត្តទាំងឡាយដែលក្នុងនោះ ការសូត្រធម៌ត្រូវបានគេផ្តល់ឱ្យកំណាព្យទាំងឡាយដកស្រង់ពីព្រះរាជសំណេររបស់ព្រះត្រូវបានគេអាន និងការលើកតម្កើងការសន្ទនាកើតមានឡើងដែលទាំងអស់ឋិតនៅក្នុងបរិយាកាសផ្នែកស្មារតី ដែលគួរឱ្យកត់សម្គាល់។ តើអ្នកអាចនិយាយពាក្យពេចន៍មួយចំនួនអំពីគំនិតនីមួយៗក្នុងចំណោមគំនិតទាំងឡាយខាងក្រោម ក្នុងបរិបទនៃការរៀបចំការជួបជុំគ្នាសូត្រធម៌មួយ?

ការស្វាគមន៍ដ៏កក់ក្តៅនិងការអញ្ជើញប្រកបដោយក្តីស្រឡាញ់______________

បង្កើតបរិយាកាសស្វាគមន៍មួយ______________

ការរក្សាបរិយាកាសនៃការគោរពដ៏ជ្រាលជ្រៅមួយ ______________

លើកស្ទួយមិត្តភាពប្រកបដោយភាពរីករាយ____________________________________

ជម្រុញការបង្កើនការសន្ទនាប្រកបដោយស្មារតី____________________________________

# REFERENCES


1. *Gleanings from the Writings of Bahá'u'lláh* (Wilmette: Bahá'í Publishing Trust, 1983, 2017 printing), XLIII, par. 4, p. 105.

2. Bahá'u'lláh, in *Trustworthiness: A Compilation of Extracts from the Bahá'í Writings*, compiled by the Research Department of the Universal House of Justice (London: Bahá'í Publishing Trust, 1987), no. 21, p. 5.

3. *The Call of the Divine Beloved: Selected Mystical Works of Bahá'u'lláh* (Haifa: Bahá'í World Centre, 2018), no. 2.43, p. 31.

4. From a talk given on 5 May 1912, published in *The Promulgation of Universal Peace: Talks Delivered by 'Abdu'l-Bahá during His Visit to the United States and Canada in 1912* (Wilmette: Bahá'í Publishing, 2012), p. 127.

5. Bahá'u'lláh, *The Hidden Words* (Wilmette: Bahá'í Publishing Trust, 2003, 2012 printing), Arabic no. 13, pp. 6–7.

6. From a letter dated 8 December 1935 written on behalf of Shoghi Effendi, published in *Prayer and Devotional Life: A Compilation of Extracts from the Writings of Bahá'u'lláh, the Báb, and 'Abdu'l-Bahá and the Letters of Shoghi Effendi and the Universal House of Justice*, compiled by the Research Department of the Universal House of Justice (Wilmette: Bahá'í Publishing, 2019), no. 71, p. 31.

7. Words of 'Abdu'l-Bahá, cited by J. E. Esslemont, *Bahá'u'lláh and the New Era: An Introduction to the Bahá'í Faith* (Wilmette: Bahá'í Publishing, 2006, 2017 printing), p. 106.

8. Ibid.

9. Bahá'u'lláh, in *Bahá'í Prayers: A Selection of Prayers Revealed by Bahá'u'lláh, the Báb, and 'Abdu'l-Bahá* (Wilmette: Bahá'í Publishing Trust, 2002, 2017 printing), pp. 7–8.

10. Ibid., p. 9.

11. Words of 'Abdu'l-Bahá, cited in *Star of the West*, vol. 8, no. 4 (17 May 1917), p. 41.

12. *Gleanings from the Writings of Bahá'u'lláh*, CXXXVI, par. 2, p. 334; also in *Bahá'í Prayers*, p. iii.

13. Bahá'u'lláh, in *Bahá'í Prayers*, pp. 8–9.

14. Ibid., p. 12.

15. 'Abdu'l-Bahá, in *Prayer and Devotional Life*, no. 24, p. 7.

16. From a talk given by 'Abdu'l-Bahá on 5 August 1912, published in *The Promulgation of Universal Peace*, p. 345.

17. *Selections from the Writings of ‘Abdu’l-Bahá* (Wilmette: Bahá’í Publishing, 2010, 2015 printing), no. 22.1, pp. 75–76.

18. From a letter dated 10 January 1936 written on behalf of Shoghi Effendi, published in *Prayer and Devotional Life*, no. 61, p. 25.

19. From a letter dated 10 January 1936 written on behalf of Shoghi Effendi, quoted in *Bahá’í Prayers*, p. 301.

20. Bahá’u’lláh, in *Bahá’í Prayers*, p. 4.

21. Bahá’u’lláh, in *Prayer and Devotional Life*, no. 68, p. 29.

22. From a message dated 29 December 2015, published in *Framework for Action: Selected Messages of the Universal House of Justice and Supplementary Material, 2006–2016* (West Palm Beach: Palabra Publications, 2017), no. 35.49, p. 232.



# ជីវិតនិងមរណភាព

## គោលបំណង

ដើម្បីយល់ថាជីវិតមិនមែនគ្រាន់តែផ្សំគ្នានូវការផ្លាស់ប្តូរនិងឱកាសទាំងឡាយនៃពិភពលោកនេះទេ ប៉ុន្តែជីវិតស្វែងរកសារសំខាន់ពិតប្រាកដរបស់វាក្នុងការអភិវឌ្ឍនៃវិញ្ញាណក្ខន្ធ។

## មេរៀនទី ១

វិញ្ញាណក្ខន្ធរបស់មនុស្សត្រូវបានគេលើកតម្កើងយ៉ាងខ្ពស់ជាងពិភពរូបរាងកាយនិងពិភពសម្ភារ។ អង្គពិសិដ្ឋ អាប់ឌុលបាហា ពន្យល់នៅក្នុងសុន្ទរកថាមួយក្នុងចំណោមសុន្ទរកថាទាំងឡាយរបស់ទ្រង់ថាៈ

**"រូបរាងកាយទាំងឡាយផ្នែកសម្ភារទាំងនេះត្រូវបានរួមផ្សំឡើងពីអាតូមជាច្រើននៅពេលអាតូមទាំងឡាយចាប់ផ្ដើមបែកចេញពុកផុយរូបរាងខាងក្នុងនោះ អ៊ីចឹងហើយដែលយើងហៅថា មរណភាព...**

**"ជាមួយនឹងវិញ្ញាណក្ខន្ធ វាគឺខុសគ្នា។ វិញ្ញាណក្ខន្ធមិនមែនជាការួមផ្សំផ្គុំគ្នាឡើងនៃជាតុទាំងឡាយនោះទេ វាគឺមិនត្រូវបានរួមផ្សំឡើង ពីអាតូមជាច្រើននោះឡើយ វាជាផ្នែកមួយនៃសារជាតុ ដែលមិនអាចបំបែកចេញពីគ្នាបាន ហើយអ៊ីចឹងវានៅឋិតឋេរជាអមតៈ។ វាមិនឋិតនៅខាងក្រោមលំដាប់នៃការបង្កើតផ្នែករូបរាងកាយនោះទេ ហើយវាគឺគ្មានសេចក្ដីស្លាប់នោះដែរ[១]"។**

១ តើ " ការរួមផ្សំផ្គុំគ្នាឡើង " មានន័យដូចម្ដេច?______________________________

______________________________

២. តើវិញ្ញាណក្ខន្ធរបស់មនុស្ស ត្រូវបានរួមផ្សំផ្គុំគ្នាឡើងពីធាតុផ្សេងៗទៀត ដូចជាការរួមផ្សំនៃរូបរាងកាយទាំងឡាយផ្នែកសម្ភារឬ?

______________________________

៣. តើវិញ្ញាណក្ខន្ធមនុស្សជារូបផ្នែករាងកាយឬ?______________________________

## មេរៀនទី ២

លិខិតមួយដែលបាននិពន្ធឡើងក្នុងនាមអ្នកគាំពារ ថ្លែងថា "វិញ្ញាណក្ខន្ធរបស់មនុស្សមានជីវិតឡើងនៅពេលចាប់បដិសន្ធិ[២]"។ ការឆ្លើយតបចំពោះសំណួរមួយអំពីអត្ថន័យនៃ "ការចាប់បដិសន្ធិ" នោះ ធម្មសភាយុត្តិធម៌សលកត់សម្គាល់ថាៈ

"មិនដែលមានឃើញក្នុងសំណេរបាហៃ ដែលកំណត់យ៉ាងប្រត្យក្សរយៈពេលនៃជីវសាស្ត្រ និងធម្មជាតិនៃលទ្ធផលដែលបរិយាយថា'ការចាប់បដិសន្ធិ' ។ ការប្រើប្រាស់នៃពាក្យក្នុងបរិបទវេជ្ជសាស្ត្រ បង្ហាញចំពោះភាពមិនច្បាស់លាស់ដូចនេះដែរ។ តាមពិតការស្វែងយល់មួយនៃការចាប់បដិសន្ធិ គឺថាវាកើតឡើងស្របពេលជាមួយការបង្កកំណើតម្យ៉ាងទៀតគឺថាវាកើតឡើងតាមការបង្កកំណើតនិងការរួមបញ្ចូលគ្នាពេល គឺការចាប់ផ្ដើមមានផ្ទៃពោះនោះឯង។ អ៊ីចឹងនោះវាមិនអាចទៅរួចដើម្បីដឹងថាពេលណាការរួមបញ្ចូលគ្នានៃវិញ្ញាណក្ខន្ធជាមួយនឹងទ្រង់ទ្រាយផ្នែកសម្ភារកើតឡើងនោះឡើយ ហើយសំណួរបែបនេះអាចមិននឹកឃើញដោយការគិតនៃគំនិតទេ ឬការស៊ើបអង្កេតពីព្រោះពួកវាទាក់ទងចំពោះអាថ៌កំបាំង នៃពិភពផ្នែកស្មារតីហើយនិងធម្មជាតិនៃវិញ្ញាណក្ខន្ធ

ខ្លួនវា[៣]។

១. តើវិញ្ញាណក្ខន្ធរបស់មនុស្សមានជីវិតឡើងនៅពេលណា?______________________________________

______________________________________

២. តើពាក្យ "ការចាប់បដិសន្ធិ" បរិយាយពេលវេលានៃជីវសាស្ត្រច្បាស់លាស់ឬទេ?

______________________________________

**មេរៀនទី ៣**

ទំនាក់ទំនងរវាងវិញ្ញាណក្ខន្ធនិងរូបរាងកាយ គឺមិនមែនជាផ្នែកសម្ភារទេវិញ្ញាណក្ខន្ធមិនបានចូល ឬចាកចេញពីរាងកាយហើយក៏មិនកាន់កាប់លំហរូបរាងកាយណាមួយឡើយ។ ការទំនាក់ទំនងរបស់វាជាមួយរូបរាង គឺស្រដៀងគ្នាទៅនឹងពន្លឺជាមួយកញ្ចក់ដែលឆ្លុះបញ្ចាំងវា។ពន្លឺដែលឃើញនៅក្នុងកញ្ចក់ គឺមិនមែននៅក្នុងកញ្ចក់នោះទេ។ដូចគ្នាដែរ វិញ្ញាណក្ខន្ធគឺមិននៅក្នុងរូបរាងកាយនោះឡើយ។ ដូចដែលអង្គពិសិដ្ឋអាប់ឌុលបាហាចង្អុលបង្ហាញថា៖

**" វិញ្ញាណក្ខន្ធប្រកបដោយវិចារណញាណ ឬស្មារតីមនុស្ស មិនមែនរស់នៅតាមរយៈរូបរាងកាយនោះដោយការជាប់ជាមួយនោះទេ មានន័យថា វាមិនមែនចូលទៅក្នុងរូបរាកាយនោះឡើយ ពីព្រោះការចាប់កំណើត និងការចូលគឺជាលក្ខណៈទាំងឡាយនៃរូបរាងកាយ រីឯវិញ្ញាណក្ខន្ធប្រកបដោយវិចារណញាណគឺត្រូវបានគេធ្វើឱ្យសន្តឡើងហួសពីនេះទៅទៀតឯណោះ។ ជាការចាប់ផ្តើមវាមិន ដែលចូលទៅក្នុងរូបរាងកាយនោះទេដែលវាគួរត្រូវការនៅពេលដែលវាចាកចេញទៅទីស្នាក់អាស្រ័យផ្សេងទៀត។ មិនមែនទេទំនាក់ទំនងនៃស្មារតីជាមួយនឹងរូបរាងកាយ គឺដូចជាទំនាក់ទំនងនៃចង្កៀងនេះជាមួយនឹងកញ្ចក់។ ប្រសិនបើកញ្ចក់ត្រូវបានគេដុសខាត់ហើយភ្លឺថ្លាបំផុតនោះ ពន្លឺនៃចង្កៀងលេចច្បាស់ឡើងៗក្នុងទីនោះ ហើយប្រសិនបើកញ្ចក់ប្រេះបែក ឬបានគ្របទៅដោយធូលី ពន្លឺនៅតែបិទបាំងមើលមិនឃើញដូច្នោះដែរ[៤]"។**

១. ចូរបំពេញចន្លោះក្នុងឃ្លេះខាងក្រោមនេះ៖

ក. វិញ្ញាណក្ខន្ធប្រកបដោយវិចារណញាណឬ______________ មិនមែនរស់នៅតាមរយៈរូបរាងកាយនោះដោយការជាប់ជាមួយនោះទេ មានន័យថា វាមិនមែន______________________________។

ខ. ________________________ឬស្មារតីមនុស្ស មិនមែនរស់នៅតាមរយៈរូបរាងកាយនោះដោយការជាប់ជាមួយនោះទេមានន័យថា វាមិនមែនចូលទៅក្នុងរូបរាកាយនោះឡើយ។ ពីព្រោះការចាប់កំណើតនិងការចូលគឺ__________________________ រីឯវិញ្ញាណក្ខន្ធប្រកបដោយវិចារណញាណគឺ_____ ______________________________________________________។

គ. វិញ្ញាណក្ខន្ធមិនដែលចូល_________________________________ដែលវាគួរត្រូវការការនៅពេលដែលវាចាកចេញទៅ________________________________។

ឃ. ទំនាក់ទំនងនៃស្មារតីជាមួយនឹងរូបរាងកាយ គឺដូចជាទំនាក់ទំនង________________________________។

ង. ប្រសិនបើកញ្ចក់ត្រូវបានគេដុសខាត់ហើយភ្លឺថ្លាបំផុតនោះ ______________________________________។
ច. ហើយប្រសិនបើកញ្ចក់ប្រេះបែក ឬបានគ្របទៅដោយធូលី ____________________________________។

២. នៅលើមូលដ្ឋាននូវអ្វីដែលយើងបានសិក្សារហូតដល់ពេលនេះ ចូរសម្រេចចិត្តថាតើខាងក្រោមនេះគឺពិតឬមិនពិត៖

______ វិញ្ញាណក្ខន្ធមិនមែនជាកម្មសិទ្ធិចំពោះពិភពរូបរាងកាយនោះទេ។
______ វិញ្ញាណក្ខន្ធឋិតនៅក្នុងរូបរាងកាយ។
______ រូបរាងកាយជាម្ចាស់នៃវិញ្ញាណក្ខន្ធ។
______ វិញ្ញាណក្ខន្ធឋិតនៅជាអមតៈ។
______ បុគ្គលម្នាក់មានការចាប់ផ្ដើមរបស់គាត់ ឬនាងនៅពេលវិញ្ញាណក្ខន្ធរួមបញ្ចូលខ្លួនវាជាមួយនឹងទារកក្នុងស្បូន។
______ ជីវិតចាប់ផ្ដើមនៅពេលបុគ្គលម្នាក់គឺត្រូវបានប្រសូត្រក្នុងពិភពនេះ។
______ ជីវិតផ្នែកសម្ភាររបស់បុគ្គលបន្តរហូតក្រោយពេលមរណភាព។
______ ជីវិតគឺអ្វីៗដែលកើតឡើងចំពោះយើងរៀងរាល់ថ្ងៃ។

៣. ចូរប្រើរូបភាពនៃពន្លឺនិងកញ្ចក់មួយ ដើម្បីរៀបរាប់ពីភាពទំនាក់ទំនងរវាងវិញ្ញាណក្ខន្ធនិងរូបរាងកាយ៖

________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________

## មេរៀនទី ៤

វាមានទំនាក់ទំនងដ៏ពិសេស រវាងវិញ្ញាណក្ខន្ធនិងរូបរាងកាយ ដែលពួកវារួមផ្សំគ្នាឡើងបង្កើតបានជាមនុស្សលោក។ ទំនាក់ទំនងនេះមានរយៈពេលត្រឹមតែមួយជីវិតមនុស្សប៉ុណ្ណោះ។ នៅពេលទំនាក់ទំនងនេះឈប់ទាក់ទងគ្នា ធាតុនីមួយៗត្រលប់ទៅប្រភពដើមរបស់វាវិញ រូបរាងកាយទៅកាន់ពិភពនៃធូលីហើយវិញ្ញាណក្ខន្ធទៅកាន់ប្រភពចិត្តវិញ្ញាណរបស់ព្រះវិញ ដែលជាទីកន្លែងដែលវាបន្តរីកចម្រើនជារហូត។ អង្គពិសិដ្ឋអាប់ឌុលបាហាថ្លែងថា៖

**"ស្មារតីមនុស្សជាតិមានការចាប់ផ្ដើមតែគ្មានទីបញ្ចប់ឡើយ៖ វាឋិតនៅជារៀងរហូត[៥]"។**

ទ្រង់បញ្ជាក់ក្នុងសុន្ទរកថាមួយក្នុងចំណោមសុន្ទរកថាទាំងឡាយរបស់ទ្រង់ថា៖

**"ស្មារតីមិនមែនត្រូវការរូបរាងកាយទេ ប៉ុន្តែរូបរាងកាយត្រូវការស្មារតី ឬវាមិនអាចរស់នៅបានឡើយ។ វិញ្ញាណក្ខន្ធអាចរស់នៅដោយគ្មានរូបរាងកាយ ផ្ទុយទៅវិញរូបរាងកាយគ្មានវិញ្ញាណក្ខន្ធគឺស្លាប់[៦]"។**

ហើយអ្នកគាំពារពន្យល់ថា៖

**"ទាក់ទងទៅនឹងវិញ្ញាណក្ខន្ធរបស់មនុស្ស៖ យោលទៅតាមការបង្ហាត់បង្រៀនបាហៃវិញ្ញាណក្ខន្ធចាប់ផ្តើមជាមួយការបង្កើតនៃទារកក្នុងស្បូនមនុស្ស ហើយបន្តអភិវឌ្ឍ និងកាត់តាមដំណាក់កាលគ្មានទីបញ្ចប់នៃជីវិតបន្ទាប់ពីការបំបែកចេញរបស់វាពីរូបរាងកាយ។ ភាពរីកចម្រើនរបស់វាគឺគ្មានទីបញ្ចប់ឡើយ[៧]"។**

១. ជាមួយនឹងព្រះវចនខាងលើដែលដក់ក្នុងចិត្តរបស់អ្នក ចូរឆ្លើយសំណួរដូចខាងក្រោម៖

ក. តើរូបរាងកាយត្រូវការវិញ្ញាណក្ខន្ធឬ? ______________________________

ខ. តើវិញ្ញាណក្ខន្ធត្រូវការរូបរាងកាយឬ? ______________________________

គ. តើមានអ្វីកើតឡើងចំពោះភាពទំនាក់ទំនងគ្នារវាងរូបរាងកាយនិងវិញ្ញាណក្ខន្ធ នៅពេលយើងស្លាប់?______

______________________________

ឃ. តើមានអ្វីកើតឡើងចំពោះវិញ្ញាណក្ខន្ធក្រោយពេលមរណភាព? ______________________________

______________________________

ង. តើភាពរីកចម្រើននៃវិញ្ញាណក្ខន្ធអស់រយៈពេលយូរប៉ុន្មាន?______________________________

______________________________

ច. តើនៅពេលណាជីវិតត្រូវបញ្ចប់? ______________________________

២. ចូរសម្រេចថាតើឃ្លាខាងក្រោមមួយណាខ្លះ ដែលស្របជាមួយនឹងអ្វីដែលយើងបានសិក្សាក្នុងមេរៀនទាំងនេះ៖

______ ការស្លាប់គឺជាទណ្ឌកម្មមួយ។

______ ទំនាក់ទំនងរវាងរូបរាងកាយនិងវិញ្ញាណក្ខន្ធ នៅបានតែមួយរយៈពេលនៃជីវិតមនុស្សប៉ុណ្ណោះ។

______ រូបរាងកាយអាចមានសមត្ថភាពរីកចម្រើនជាអមតៈ ។

______ មរណភាពគឺជាចុងបញ្ចប់នៃជីវិត ។

______ មានថ្ងៃមួយនៃការវិនិច្ឆ័យដែលនៅពេលនោះរូបរាងកាយយើងនឹងក្រោកឡើងវិញ។

______ នៅពេលស្លាប់វិញ្ញាណក្ខន្ធរបស់យើងមានសេរីភាពជាង ដែលវាមានពីមុន។

______ ជីវិតបញ្ចប់ជាមួយនឹងសេចក្តីស្លាប់ ។

______ យើងគួរតែខ្លាចសេចក្តីស្លាប់ ។

______ អាហារ សម្លៀកបំពាក់ ការសម្រាក និងការកម្សាន្តមានការចាំបាច់សម្រាប់វិញ្ញាណក្ខន្ធ។

______ វិញ្ញាណក្ខន្ធគឺមានភាពហត់នឿយនៅពេលរូបរាងកាយប្រើប្រាស់កម្លាំងរបស់ខ្លួន។

______ វិញ្ញាណក្ខន្ធគឺមិនត្រូវបានធ្វើឱ្យប៉ះពាល់ដោយជម្ងឺឬភាពទន់ខ្សោយនៃរូបរាងកាយនោះទេ។

______ មនុស្សជាតិនឹងនៅតែមានសេចក្តីត្រូវការផ្នែករូបរាងកាយក្រោយមរណភាព។

## មេរៀនទី ៥

យើងបានយល់ហើយថា វិញ្ញាណក្ខន្ធមិនមែនឋិតនៅលំហនៃរាងកាយនិងអនុវត្តទៅតាមច្បាប់ធម្មជាតិ ធ្វើទៅ

តាមអង្គភាពកាយវប្បកម្មនោះឡើយ។ វិញ្ញាណក្ខន្ធប្រើប្រាស់ឥទ្ធិពលនៅក្នុងពិភពរាងកាយ តាមរយៈសរីរាង្គនៃរូបរាងកាយ ប៉ុន្តែនេះមិនមែនគ្រាន់តែមានន័យ ថាតាមរយៈវិញ្ញាណក្ខន្ធប្រើអានុភាពរបស់វានោះទេ ។ ព្រះបាហាអ៊ុលឡាហ៍ប្រកាសថា៖

**"ពិតប្រាកដណាស់តថាគតមានបន្ទូលថាវិញ្ញាណក្ខន្ធមនុស្សជាតិត្រូវបានគេលើកតម្កើងខ្ពស់ជាងអ្វីៗទាំងអស់នៅខាងក្នុងនិងខាងក្រៅ។ វាគឺបិតបេរប៉ុន្តែវាហោះហើរ វាមានចលនាប៉ុន្តែវាបិតបេរ[៨]"។**

អង្គពិសិដ្ឋអាប់ឌុបាហាមានបន្ទូលប្រាប់យើងថា៖

**"ចូរដឹងថាអានុភាព និងការស្វែងយល់នៃស្មារតីនៃមនុស្សជាតិ គឺមានពីរប្រភេទ នោះគឺថាស្មារតីមនុស្សជាតិមានពីរលំនាំនៃប្រតិបត្តិការនិងការស្វែងយល់។ លំនាំមួយតាមរយៈសន្ទានកម្មនៃឧបករណ៍និងផ្នែកសរីរាង្គទាំងឡាយនៃរូបរាងកាយ។ អ៊ីចឹង វាឃើញដោយភ្នែក ស្តាប់ឮដោយត្រចៀក និយាយដោយអណ្តាត...**

**"លំនាំដទៃផ្សេងទៀតនៃអានុភាពនិងសកម្មភាពផ្សេងទៀតរបស់ស្មារតីគឺគ្មានផ្នែកឧបករណ៍និងសរីរាង្គនានានៃរូបរាងកាយនោះទេ[៩]"។**

១. ចូរបំពេញចន្លោះក្នុងល្បះទាំងឡាយខាងក្រោម៖
ក. វិញ្ញាណក្ខន្ធមនុស្សជាតិត្រូវបានគេលើកតម្កើងខ្ពស់ជាងអ្វីៗទាំងអស់នៅ____________និង____________។
ខ. វាគឺ____________ ហើយប៉ុន្តែវា________________។
គ. វា______________ហើយប៉ុន្តែវា______________។

២. ចូរបរិយាយវិធីពីរដែលតាមរយៈនោះវិញ្ញាណក្ខន្ធយល់និងផ្តល់ឱ្យអានុភាពក្នុងពិភពលោកនេះ៖

________________________________________________

________________________________________________

________________________________________________

៣. តើអ្នកអាចផ្តល់ឧទាហរណ៍មួយចំនួននៃអានុភាព និងសកម្មភាពរបស់វិញ្ញាណក្ខន្ធដែលគ្មានឧបករណ៍ផ្នែករូបរាងកាយ?

________________________________________________

________________________________________________

________________________________________________

## មេរៀនទី៦

យោលទៅតាមការពិភាក្សាក្នុងមេរៀនជាច្រើនកាលពីលើកមុនចូរអានវគ្គខាងក្រោម ដែលដកស្រង់ចេញពីព្រះរាជសំណេរទាំងឡាយរបស់ព្រះបាហាអ៊ុលឡាហ៍ថា៖

**"ចូរអ្នកដឹងថាវិញ្ញាណក្ខន្ធរបស់មនុស្សត្រូវបានគេលើកតម្កើងយ៉ាងខ្ពស់ ហើយវាមិនជាប់ទាក់ទងទៅនឹងភាពទន់**

ខ្សោយទាំងអស់នៃរូបរាងកាយ ឬចិត្តគំនិតនោះទេ។ អ្នកជម្ងឺម្នាក់បានបង្ហាញសញ្ញាជាច្រើននៃភាពទន់ខ្សោយ គឺដោយហេតុថា បង្អាក់ការបញ្ចូលខ្លួនពួកគេរវាងវិញ្ញាណក្ខន្ធរបស់គាត់ និងរូបរាងកាយរបស់គាត់ពីព្រោះវិញ្ញាណក្ខន្ធខ្លួនវាបានឋិតនៅមិនផ្លាស់ប្តូរដោយជម្ងឺណាមួយនៃរាងកាយនោះឡើយ។ ចូរគិតពិចារណាពន្លឺនៃចង្កៀង។ ទោះបីជាយ៉ាងណាក៏ដោយវត្ថុខាងក្រៅអាចបង្អាក់ជាមួយនឹងភាពភ្លឺត្រចះត្រចង់របស់វា ពន្លឺខ្លួនវាបានបន្តដើម្បីបញ្ចេញពន្លឺជាមួយនឹងអនុភាពមិនចុះថយ។ ស្រដៀងនេះដែរ គ្រប់ជម្ងឺធ្វើឱ្យឈឺចាប់រាងកាយរបស់មនុស្សគឺជាឧបសគ្គដែលបានរារាំងវិញ្ញាណក្ខន្ធពីការបង្ហាញនូវឫទ្ធានុភាព និងអានុភាពដ៏សំខាន់របស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលវាបានចេញពីរូបរាងកាយនោះ វានឹងបង្ហាញឱ្យឃើញច្បាស់នូវភាពឧត្តមបំផុត និងបង្ហាញឥទ្ធិពលដែលគ្មានកម្លាំងពីផែនដីអាចប្រៀបស្មើបាននោះទេ។ គ្រប់វិញ្ញាណក្ខន្ធបរិសុទ្ធ គ្រប់វិញ្ញាណក្ខន្ធស្រស់ថ្លា និងសន្តនឹងប្រាកដជាត្រូវបានគេផ្តល់ឱ្យជាមួយនឹងអានុភាពដ៏អស្ចារ្យបំផុត ព្រមទាំងនឹងធ្វើឱ្យសប្បាយរីករាយជាមួយនឹងភាពរីករាយយ៉ាងក្រៃលែង[១០]”។

១. ចូរពន្យល់ជាពាក្យសម្តីផ្ទាល់ខ្លួនរបស់អ្នកពីរបៀប ដែលវិញ្ញាណក្ខន្ធនៅតែមិនប៉ះពាល់ដោយភាពទន់ខ្សោយនៃរូបរាងកាយឬចិត្តនិងអ្វីដែលនឹងត្រូវបានគេបង្ហាញភស្តុតាងពេលបែកចេញពីរូបរាងកាយ។

______________________________________________________________
______________________________________________________________
______________________________________________________________
______________________________________________________________
______________________________________________________________

២. តើយើងនឹងនៅតែរក្សាបុគ្គលិកលក្ខណៈរបស់យើងបន្ទាប់ពីការស្លាប់នៃរូបរាងកាយរបស់យើងឬ?__________
______________________________________________________________

**មេរៀនទី ៧**

ព្រះបាហាអ៊ុលឡាហ៍មានបន្ទូលថាៈ

“ហើយឥឡូវនេះទាក់ទិនទៅនឹងសំណួររបស់អ្នក ចំពោះវិញ្ញាណក្ខន្ធរបស់មនុស្ស ហើយនិងការរស់របស់វាក្រោយពីមរណភាព។ ចូរអ្នកដឹងភាពពិតមួយថាក្រោយពីការបែកគ្នារបស់វាចេញពីរាងកាយនោះវានឹងត្រូវបន្តការរីកចម្រើនរហូតទាល់តែវាបានដល់ព្រះវត្តមានរបស់ព្រះទោះនៅក្នុងសភាវនិងលក្ខណៈដែលមិនថាមានផ្លាស់ប្តូរនៃសម័យកាលឬសតវត្សនិងការផ្លាស់ប្តូរនៃពិភពលោកនេះក៏ដោយក៏មិនអាចប្រែប្រួលដែរ។

វានឹងឋិតថេរជាដរាបអាណាចក្ររបស់ព្រះអធិបតេយ្យភាពរបស់ទ្រង់វិជិតរាជ្យរបស់ទ្រង់នឹងអំណាចរបស់ទ្រង់នៅឋិតថេរជានិច្ច។វានឹងបញ្ចេញឲ្យឃើញនូវសញ្ញារបស់ព្រះនិងកេតនភ័ណ្ឌរបស់ទ្រង់និងបង្ហាញឲ្យឃើញនូវ ចិត្តមេត្តាធម៌ និងសព្វសាធុការពររបស់ទ្រង់[១១]”។

១. តើវិញ្ញាណក្ខន្ធនឹងបន្តរីកចម្រើនយូរប៉ុន្មានក្រោយពេលការស្លាប់ផ្នែករូបរាងកាយ?__________________

______________________________________________________________

២. នៅក្នុងលក្ខណៈអ្វីដែលវិញ្ញាណក្ខន្ធបន្តធ្វើដំណើរជាអមតៈរបស់វាឆ្ពោះទៅព្រះវត្តមានរបស់ព្រះ?__________

______________________________________________________________

______________________________________________________________

៣. តើកេតនភ័ណ្ឌនិងសញ្ញាខ្លះ ដែលវិញ្ញាណក្ខន្ធនឹងបង្ហាញឱ្យឃើញក្នុងស្ថានភាពនោះ?

______________________________________________________________

៤. យោលទៅតាមអ្វីដែលយើងបានសិក្សារួចមកហើយនោះ ចូរសម្រេចថាខាងក្រោមណាមួយគឺពិតឬមិនពិត?

______ អាណាចក្ររបស់ព្រះនឹងឋិតនៅជារៀងរហូត។

______ វិញ្ញាណក្ខន្ធរបស់មនុស្សមានសមត្ថភាពបង្ហាញឱ្យឃើញនូវកេតនភ័ណ្ឌទាំងឡាយរបស់ព្រះ។

______ ធម៌ដែលយើងសូត្រសម្រាប់មរណភាពមិនមានអានុភាពដល់ការរីកចម្រើននៃវិញ្ញាណក្ខន្ធរបស់ពួកគេទេ។

______ វិញ្ញាណក្ខន្ធមិនដែលឈប់ការរស់នៅរបស់វាឡើយ។

## មេរៀនទី ៨

ព្រះបាហាអ៊ុលឡាហ៍ប្រកាសថា៖

"ចូរអ្នកដឹងថាគ្រប់ត្រចៀកដែលបានស្តាប់ឮគ្រប់ពេលនិងគ្រប់ទីកន្លែងចូរស្តាប់សម្លេងដែលបន្លឺឡើងនូវពាក្យពាក្យពិសិដ្ឋទាំងនេះពិតប្រាកដណាស់យើងក៏ជារបស់ព្រះហើយយើងនឹងត្រលប់ទៅកាន់ទ្រង់វិញ។

"អាថ៌កំបាំងនៃការស្លាប់ផ្នែករាងកាយរបស់មនុស្សនិងការត្រលប់មកវិញមិនត្រូវបានបកស្រាយឡើយហើយនៅតែអាថ៌កំបាំងដដែល ។ ហើយនៅតែមិនទាន់បានអានថែមទៀត...។

" សេចក្តីស្លាប់ផ្តល់ជូនទៅដល់អ្នកជំនឿដែលជឿជាក់គ្រប់ៗគ្នា នូវពែងដែលជាជីវិតពិត ។ វាបន្សល់ទុកនូវសេចក្តីរីករាយ ហើយជាអ្នករែកនៃភាពសប្បាយ ។ វាផ្តល់អំណោយនៃជីវិតអមតៈ[១២]"។

" ចំណែកឯអ្នកទាំងឡាយណាដែលបានភ្លក់សេជាតិនៃផ្លែឈើដែលជាជីវិតលោកិយ៍របស់មនុស្ស ដែលជាការទទួលស្គាល់របស់ព្រះពិតតែមួយគត់ដែលជាភាពរុងរឿងដ៏ខ្ពង់ខ្ពស់ ជិវិតរបស់ពួកគេបន្ទាប់ជីវិតក្នុងលោកានេះគឺតថាគតមិនអាចពណ៌នាបានឡើយ។ ចំណេះដឹងដែលពិពណ៌នាជីវិតនោះ ឋិតនៅជាមួយព្រះមួយអង្គគត់ដែលជាព្រះនៃគ្រប់ពិភពទាំងអស់"។

"ឱម្នាលបុត្រដ៏ឧត្តមអើយ! យើងបានបង្កើតសេចក្តីស្លាប់ក្លាយ ជាអ្នកនាំសារនៃសេចក្តីសប្បាយសម្រាប់អ្នក ម្តេចក៏អ្នកទុក្ខសោកទៅវិញ ? យើងបានតាក់តែងភាពរុងរឿងឡើងមកដើម្បីស្រោចស្រប់ដល់រូបអ្នក ម្តេចក៏អ្នកបិទបាំងប្រាណពីវាទៅវិញអ៊ីចឹង?[១៣]"

១.	តើសេចក្តីថ្លែងការខាងក្រោមមួយណាគឺពិត?

______ វិញ្ញាណក្ខន្ធរបស់មនុស្សកើតមកពីព្រះ ហើយនិងត្រូវវិលត្រឡប់ទៅកាន់ទ្រង់វិញ។
______ គ្រប់ចំណេះដឹងនៃជីវិតក្រោយពីមរណភាពគឺនៅជាមួយនឹងព្រះ ។
______ សម្រាប់អ្នកជំនឿពិត មរណភាពគឺជាជីវិត ។
______ មរណភាពគឺជាអ្នកនាំមកនូវសេចក្តីសប្បាយរីករាយ ។
______ អាថ៌កំបាំងទាំងឡាយនៃមរណភាពត្រូវបានដឹងដោយយើងគ្រប់ៗគ្នា ។
______ យើងគួរផ្តល់តម្លៃទៅនឹងសព្វសាធុការពរនៃជីវិតមិនគួរភ័យខ្លាចនៃមរណភាពនោះទេពីព្រោះវាជាអ្នកនាំសារនៃភាពរីករាយពិតមួយ។
______ វាគឺមិនសំខាន់សម្រាប់យើងដឹងអំពីជីវិតក្រោយពីមរណភាពនោះទេ ។

២.	ឥឡូវចូរចងចាំទុកក្នុងចិត្តពីអ្វី ដែលយើងបានសិក្សាក្នុងមេរៀនទាំងនេះ ចូរសរសេរកថាខណ្ឌខ្លីមួយអំពីជីវិត មរណភាព រូបរាងកាយនិង វិញ្ញាណក្ខន្ធ។

______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________
______________________________

**មេរៀនទី ៩**

អង្គពិសិដ្ឋអាប់ឌុលបាហាមានបន្ទូលថាៈ

**"ក្នុងការបណ្តើមជីវិតជាមនុស្សដំបូងរបស់គាត់គឺជាទារកនៅក្នុងពិភពនៃផ្ទៃម្តាយ។ដែលនៅទីនោះគាត់ទទួលបានសមត្ថភាពនិងភាពសក្តិសមដើម្បីអភិវឌ្ឍនៅក្នុងលោកានេះ។កម្លាំងនិងថាមពលគឺចាំបាច់ណាស់សម្រាប់**

ពិភពលោកនេះគឺគាត់បានទទួលយកនៅពិភពនោះជាទារក។ គាត់បានត្រូវការភ្នែកមួយគូរនៅក្នុងលោកានេះ គាត់ក៏បានទទួលពួកវាប្រកបដោយសក្តានុពលនៅក្នុងពិភពនៃផ្ទៃម្តាយ។គាត់បានត្រូវការត្រចៀកពីរ ហើយក៏បានទទួលពួកវានៅពិភពនោះដែរ។ថាមពលទាំងអស់ដែលជាតម្រូវការ សម្រាប់ពិភពនេះត្រូវបានប្រគល់ឱ្យគាត់កាលដែលគាត់នៅក្នុងពិភពនៃផ្ទៃម្តាយ។ នៅពិភពនោះគាត់បានរៀបចំខ្លួនសម្រាប់លោកានេះ ហើយនៅនៅពេលគាត់ចូលមកក្នុងលោកានេះ គាត់បានឃើញថាគាត់មានអំណាចដែលជាតម្រូវការ ហើយគាត់បានក៏ទទួលយកនូវពិភពនោះគ្រប់ផ្នែកនៃរូបរាងកាយទាំងអស់ដែលចាំបាច់សម្រាប់ជីវិតនេះ។ដូចនេះនៅក្នុងលោកានេះដែរ គាត់ត្រូវរៀបចំខ្លួនគាត់សម្រាប់បរលោក។ អ្វីដែលគាត់ធ្វើការនៅក្នុងពិភពនៃអាណាចក្ររបស់ព្រះ គាត់គួរតែទទួលយកវាហើយរៀបចំពួកវានៅទីក្នុងលោកានេះ។ ដូចដែលគាត់ទទួលយកអំណាចទាំងឡាយដ៏ចាំបាច់សម្រាប់លោកានេះក្នុងពិភពនៃផ្ទៃម្តាយ។ដូចគ្នានេះដែរ គាត់គួរតែទទួលយកនូវក្នុងលោកានេះអ្វីដែលគាត់នឹងធ្វើការនៅក្នុងពិភពនៃអាណាចក្ររបស់ព្រះ ដូចអំណាចឋានសួគ៌ាទាំងអស់[១៤]”។

១. ចូរសម្រេចចិត្តថាក្រោមគឺពិតឬមិនពិតៈ

______ គ្រប់កម្លាំងនិងថាមពលដែលចាំបាច់សម្រាប់លោកានេះគឺត្រូវបានគេទទួលនៅក្នុងពិភពនៃផ្ទៃម្តាយ។
______ វាមិនចាំបាច់រៀបចំខ្លួនសម្រាប់ជីវិតបន្ទាប់ទៀតឡើយ ។
______ អ្វីដែលយើងត្រូវការនៅក្នុងពិភពនៃអាណាចក្ររបស់ព្រះគួរតែទទួលយកបាននៅទីនោះ ។
______ គោលបំណងនៃជីវិតនេះគឺដើម្បីទទួលយកអំណាចចាំបាច់ទាំងឡាយសម្រាប់ជីវិតបរលោក។
______ ជីវិតពិតចាប់ផ្តើមឡើងនៅពេលមនុស្សម្នាក់ស្លាប់ ហើយធ្វើដំណើរទៅកាន់អាណាចក្រអាទិទេព ។
______ ជីវិតពិតចាប់ផ្តើមឡើងនៅក្នុងពិភពនេះ ហើយបន្តទៀតក្រោយពេលមរណភាពផ្នែករូបរាងកាយ ។

២. តើសមត្ថភាពអ្វីខ្លះក្នុងចំណោមសមត្ថភាពទាំងឡាយមនុស្សជាតិចាប់ផ្តើមទទួលយកក្នុងពិភពនៃផ្ទៃម្តាយ?

______________________________

______________________________

៣. តើលក្ខណៈធម្មជាតិមួយចំនួនអ្វីខ្លះដែលយើងគួរទទួលយកនៅទីនេះសម្រាប់ជីវិតក្រោយមរណភាព?

______________________________

______________________________

## មេរៀនទី ១០

ព្រះបាហាអ៊ុលឡាហ៍ប្រកាសថាៈ

“ករណីយកិច្ចទាំងស្រុងរបស់មនុស្សនៅក្នុងយុគសម័យរបស់ព្រះនេះគឺដើម្បីទទួលនូវចំណែកនៃភាពជន់ជោរនៃភាពអនុគ្រោះ ដែលព្រះបានប្រទានមកដល់គាត់ ។ ដូច្នេះចូរកុំឱ្យគិតពិចារណាពីភាពធំ ឬតូចនៃប្រដាប់សម្រាប់ដាក់នោះឡើយ។ចំណែករបស់អ្នកខ្លះអាចដាក់បាននៅក្នុងប្រអប់បាតដៃរបស់គាត់ ចំណែករបស់អ្នកដទៃទៀតអាចបំពេញពែងមួយ ហើយអ្នកដទៃផ្សេងទៀតអាចបំពេញមួយហ្គាល្លុនឯណោះ[១៥]”។

១.　តាមការស្វែងយល់ព្រះវចនៈខាងលើ ចូរឆ្លើយសំណួរដូចតទៅនេះ៖

ក.　តើអ្វីខ្លះជាកាតព្វកិច្ចនៃបុគ្គលម្នាក់ៗក្នុងយុគសម័យព្រះនេះ? ។ ____________________

____________________________________________________________

____________________________________________________________

ខ.　តើសព្វសាធុការពរអ្វីខ្លះក្នុងចំណោមសព្វសាធុការពរទាំងឡាយដែលអ្នកបានទទួលពីព្រះ?

____________________________________________________________

____________________________________________________________

គ.　តើពាក្យ "ប្រដាប់សម្រាប់ដាក់ " សម្តៅចំពោះអ្វីក្នុងព្រះវចនៈខាងលើ ?

____________________________________________________________

____________________________________________________________

ឃ.　ហេតុអ្វីយើងមិនគួរគិតពិចារណា "ភាពធំឬភាពតូច" នៃសមត្ថភាពជាមួយនឹងអ្វីដែលត្រូវបានគេផ្តល់ឱ្យ?

____________________________________________________________

____________________________________________________________

ង.　តើរឿងអ្វីខ្លះក្នុងចំណោមរឿងទាំងឡាយដែលរារាំងយើងពីការទទួលយកចំណែករបស់យើងពីកិត្តិគុណរបស់ព្រះ?__________________________________________________

២.　តើខាងក្រោមមួយណាគឺពិត?

______ "ភាពធំឬភាពតូច" នៃសមត្ថភាពរបស់យើងសម្តៅទៅលើភាពឆ្លាតវាងវៃដែលយើងមាន។

______ ដើម្បីបម្រើព្រះ យើងត្រូវតែបំភ្លេចចោលភាពទន់ខ្សោយទាំងឡាយរបស់យើងហើយដាក់ការទុកចិត្តរបស់យើងទាំងស្រុងចំពោះទ្រង់។

______ បើក្នុងពិភពលោកនេះ យើងមិនអភិវឌ្ឍសមត្ថភាពទាំងឡាយដែលព្រះបានប្រទានដល់យើងទេនោះ វិញ្ញាណក្ខន្ធរបស់យើងនឹងប្រាកដជាខ្សោយនៅពេលយើងមកដល់ពិភពបរលោក។

## មេរៀនទី ១១

ព្រះបាហាអ៊ុលឡាហ៍ថ្លែងថា៖

**"អ្នកបានសួរដល់តថាគតអំពីធម្មជាតិរបស់វិញ្ញាណក្ខន្ធ ។ ពិតណាស់ចូរអ្នកដឹងថាវិញ្ញាណក្ខន្ធគឺជាសញ្ញាមួយរបស់**

ព្រះហើយក៏ជាត្បូងរបស់ឋានសួគ៌ ដែលភាពពិតរបស់វាអ្នកចេះដឹងភាគច្រើនមិនទាន់បានយល់នៅឡើយទេ ហើយអាថ៌កំបាំងរបស់វាគឺមិនទាន់មានគំនិតដែលអាចសង្ឃឹមនឹងដោះស្រាយវា ទោះបីជាគាត់ឆ្លាតយ៉ាងណាក៏ដោយ។ វាគឺជាវត្ថុទីមួយក្នុងចំណោមវត្ថុដែលគេបានបង្កើតឡើងគ្រប់យ៉ាង ដែលប្រកាសពីភាពដ៏ល្អប្រពៃរបស់ព្រះ ជាអ្នកបង្កើតរបស់វាហើយក៏ជាវត្ថុទីមួយដែលទទួលស្គាល់នូវភាពរុងរឿងរបស់ទ្រង់ ព្រមទាំងជឿជាក់ទៅនឹងសច្ចធម៌របស់ព្រះអង្គ និងលំអោនខ្លួនចុះនៅក្នុងការសរសើរនៅចំពោះព្រះភក្ត្ររបស់ទ្រង់[១៦]”។

១. ចូរបំពេញចន្លោះទាំងឡាយក្នុងល្បះខាងក្រោម៖

ក. វិញ្ញាណក្ខន្ធគឺជា__________មួយរបស់ព្រះ។

ខ. វិញ្ញាណក្ខន្ធជា_______________ដែលភាពពិតរបស់វា___________ភាគច្រើនមិនទាន់បានយល់នៅឡើយទេ ហើយអាថ៌កំបាំងរបស់វាគឺមិនទាន់មានគំនិតដែលអាចសង្ឃឹមនឹង_____________។

គ. គឺជាវត្ថុទីមួយក្នុង________________________________________ដែលប្រកាស__________
____________________________________________________________។

ឃ. វិញ្ញាណក្ខន្ធជាវត្ថុទីមួយ_____________________________ភាពរុងរឿងរបស់ទ្រង់។

ង. វិញ្ញាណក្ខន្ធ_______________________សច្ចធម៌របស់ព្រះអង្គ។

ច. វិញ្ញាណក្ខន្ធ_________________________នៅក្នុងការសរសើរនៅចំពោះព្រះភក្ត្ររបស់ទ្រង់។

២. តើខាងក្រោមមួយណាគឺពិត?

______ ពាក្យថា “ដោះស្រាយ” មានន័យថារកឲ្យឃើញ ។
______ ក្នុងចំណោមវត្ថុដែលបានបង្កើតឡើងគ្រប់យ៉ាង វត្ថុដែលទទួលស្គាល់ព្រះមុនគេគឺខួរក្បាលមនុស្ស ។
______ ពាក្យថា “ឆ្លាត” មានន័យថាមុតស្រួច ។
______ អ្នករៀនចេះដឹងយល់ពីអាថ៌កំបាំងនៃវិញ្ញាណក្ខន្ធបាន ។
______ មានតែអ្នកទស្សនវិជ្ជាទាំងឡាយទេដែលអាចប្រកាសឧត្តមភាពរបស់ព្រះបាន។
______ វាមិនចាំបាច់ធ្វើការត្រិះរិះពិចារណាអំពីវិញ្ញាណក្ខន្ធទេពីព្រោះយើងមិនអាចយល់ពីវាបានឡើយ។

## មេរៀនទី ១២

ព្រះបាហាអ៊ុលឡាហ៍ប្រកាសថា៖

“អ្នកគឺដូចបក្សីដែលបានហោះឡើងពោរពេញដោយកម្លាំងនៃស្លាបដ៏រឹងមាំរបស់វា ហើយព្រមទាំងមានសេចក្តីទុកចិត្តគ្រប់គ្រាន់ដែលជាទីរីករាយ ដែលវាហោះកាត់តាមឋានសួគ៌ដ៏មហាធំធេងរហូតដល់វាក៏បានងាកមើលទៅកាន់ទឹកដីរបស់ផែនដីដែលនៅខាងក្រោមវាប្រកបដោយចំណង់យ៉ាងខ្លាំង ហើយវាក៏ត្រូវបានជម្រុញឲ្យស្កប់ចិត្តនូវសេចក្តីស្រេកឃ្លានរបស់វានិងត្រូវបានទាក់ជាប់នៅក្នុងសំណាញ់នៃសេចក្តីលោភលន់រហូតទាល់តែវាដឹងដោយខ្លួនឯង ថាគ្មានកម្លាំងអំណាចដើម្បីបន្តការហោះហើររបស់វាទៅកាន់ឋានសួគ៌ដែលវាបានមកឡើយ។ព្រោះតែគ្មានកម្លាំងក្នុងការ គេចខ្លួនឲ្យរួចពីបន្ទុកដ៏ធ្ងន់ដែលបាន

ដាក់ទៅលើស្លាបដែលខូចរបស់វានោះបក្សីនោះ ដែលជាបក្សីរបស់ឋានសួគ៌ឥឡូវនេះត្រូវបានបង្ខំចិត្ត ស្វែងរកទីកន្លែងមួយនៅលើពិភពធូលីនេះដើម្បីរស់នៅ។ ហេតុនេះហើយឱ! អ្នកបម្រើរបស់តថាគត អើយ!ចូរអ្នកកុំធ្វើឲ្យស្លាបទាំងពីររបស់អ្នកប្រឡាក់ជាមួយនឹងធូលីនៃភាពរឹងរូស និងសេចក្តីប្រាថ្នាឥត ប្រយោជន៍ឡើយហើយក៏ចូរអ្នកកុំធ្វើឲ្យពួកវាឈឺផ្សារក្នុងការ ដែលគេធ្វើឲ្យប្រឡាក់ជា មួយនឹងធូលីនៃ សេចក្តីប្រណែន និងសេចក្តីសម្អប់ដើម្បីកុំឲ្យគេរារាំងអ្នកពីការហោះហើរឡើងចូលទៅក្នុងឋានសួគ៌នៃ ចំណេះដឹងដ៏ល្អឥតខ្ចោះរបស់តថាគត[១៧]”។

១. ចូរបំពេញនូវចន្លោះដូចតទៅនេះ ៖

ក. បក្សីដែលព្រះបាហាអ៊ុលឡាហ៍សំដៅនៅក្នុងសម្រង់ពាក្យនេះគឺជា______________________ ។

ខ. បក្សីនេះគឺជាបក្សីនៃ__________________________________________________________

គ. ប្រសិនបើស្លាបទាំងពីររបស់វាត្រូវបានគេធ្វើប្រឡាក់ បក្សីត្រូវបានបង្ខំដើម្បីស្វែងរកជម្រករបស់វានៅក្នុង

______________________________________________________________________

______________________________________________________________________

២. ឥលូវចូរឆ្លើយសំណួរទាំងឡាយដូចខាងក្រោម៖

ក. តើ “ ស្លាបទាំងពីរ ” នៃវិញ្ញាណក្ខន្ធក្លាយជា “ ប្រឡាក់ ” យ៉ាងដូចម្តេច? _______________

______________________________________________________________________

______________________________________________________________________

ខ. តើបន្ទុកមួយចំនួនអ្វីខ្លះក្នុងចំណោមបន្ទុកទាំងឡាយដែលដូច “ ទឹកនិងដីនៃផែនដី ” មានទម្ងន់លើ ស្លាបទាំងពីរនៃវិញ្ញាណក្ខន្ធ?។ __________________________________________

______________________________________________________________________

______________________________________________________________________

គ. តើរឿងអ្វីខ្លះក្នុងចំណោមរឿងទាំងឡាយដែលអាចបង្អាក់យើងពីការហោះហើរចូលទៅក្នុងឋានសួគ៌នៃ ចំណេះដឹងដ៏ពិសិដ្ឋ? ______________________________________________

______________________________________________________________________

______________________________________________________________________

ឃ. តើហេតុអ្វីបានជាវិញ្ញាណក្ខន្ធ ផ្លាស់ប្តូរទីជម្រកឋានសួគ៌ដ៏ជាទីរីករាយរបស់វា មកកាន់ពិភពដែល ជាធូលីនេះ ? ______________________________________________

______________________________________________________________________

៣. ចូរសម្រេចចិត្តថាសេចក្តីថ្លែងការខាងក្រោមណាគឺពិតឬមិនពិត៖

______ ការជាប់ជំពាក់នឹងវត្ថុលោកិយបង្អាក់ភាពរីកចម្រើនស្មារតីរបស់យើង។

______ ការមិនស្ដាប់បង្គាប់និងបំណងប្រាថ្នាឥតប្រយោជន៍ទាញយើងពីការហោះហើរក្នុងឋានសួគ៌នៃចំណេះដឹងដ៏ពិសិដ្ឋ។

______ សេចក្ដីច្រណែននិងភាពសម្អប់គឺជាលក្ខណៈធម្មជាតិនៃមនុស្សជាតិ និងមិនដាក់បន្ទុកវិញ្ញាណក្ខន្ធនោះទេ។

______ យើងអាចសម្រាលខ្លួនយើងពីបន្ទុកទាំងឡាយដែលរារាំងយើងពីការហោះហើរតាមរយៈភាពដ៏ធំធេងនៃឋានសួគ៌ដោយកាត់ផ្ដាច់ខ្លួនយើងពីរឿងរ៉ាវទាំងឡាយនៃពិភពលោកនេះ។

______ កន្លែងស្នាក់នៅរបស់វិញ្ញាណក្ខន្ធគឺនៅក្នុងពិភពលោកនេះ។

## មេរៀនទី ១៣

ព្រះបាហាអ៊ុលឡាហ៍មានព្រះបន្ទូលថា៖

**"ដោយបានបង្កើតពិភពលោកនិងអ្វីៗដែលរស់នៅនិងមានចលនានៅទីនោះតារយៈព្រះរាជកិច្ចផ្ទាល់ដែលកើតមកពីឆន្ទៈពេញព្រះទ័យហើយប្រកបដោយអំណាចរបស់ទ្រង់ ដែលព្រះអង្គបានជ្រើសរើសឲ្យមានតែមនុស្សមួយគត់ដែលមានកិត្តិយសហើយនិងសមត្ថភាពក្នុងការស្គាល់ទ្រង់និងស្រឡាញ់ទ្រង់ សមត្ថភាពដែលតម្រូវឲ្យគេយល់ឃើញថាជាកម្លាំងជលវេគដែលបានបង្កើតហើយក៏ជាបំណងបឋមដែលជាដើមកំណើត ទាំងស្រុងរបស់មាបនកម្មផងដែរ...។យោងទៅតាមភាពពិតបំផុតនៃវត្ថុនីមួយៗនិងគ្រប់យ៉ាងដែលបានបង្កើតឡើងនោះព្រះអង្គបានបញ្ចាំងពន្លឺនៃព្រះនាមមួយរបស់ទ្រង់ ហើយព្រះអង្គបានបង្កើតវាឡើងមកឲ្យធ្វើជាអ្នកទទួលនូវភាពរុងរឿងនៃកេតនភ័ណ្ឌមួយក្នុងចំណោមកេតនភ័ណ្ឌទាំងឡាយរបស់ទ្រង់។ ទោះបីជាយ៉ាងណាក៏ដោយយោងទៅតាមភាពពិតរបស់មនុស្ស ព្រះអង្គបានបញ្ចាំងពន្លឺភ្លឺថ្លាប្រិមប្រិយនៃគ្រប់ព្រះនាម និងកេតនភ័ណ្ឌរបស់ទ្រង់ហើយបានបង្កើតវាឡើងមកធ្វើជាកញ្ចក់នៃព្រះកាយផ្ទាល់របស់ទ្រង់។គ្រប់វត្ថុដែលបានបង្កើតឡើងមកនេះមានតែមនុស្សមួយគត់ដែលត្រូវបានកំណត់ដើម្បីទទួលយកនូវការអនុគ្រោះដ៏ធំអស្ចារ្យហើយព្រមទាំងដើម្បីឲ្យទទួលយកនូវចិត្តសប្បុរសធម៌ដ៏បិតបេររបស់ព្រះអង្គ[១៨]"។**

១. ចូរបំពេញចន្លោះទាំងឡាយខាងក្រោម។

ក. ព្រះអង្គបានជ្រើសរើសឲ្យមានតែមនុស្សមួយគត់ដែលមានកិត្តិយសហើយនិងសមត្ថភាព__________ ____________________________________________________________________________________________។

ខ. យោងទៅតាមភាពពិតបំផុតនៃ_____________និង____________________ដែលបានបង្កើតឡើងនោះព្រះអង្គបានបញ្ចាំងពន្លឺនៃ________________________________ ហើយព្រះអង្គបានបង្កើតវាឡើងមកឲ្យធ្វើជាអ្នកទទួលនូវភាពរុងរឿង__________________________________________________ _______________។

គ. យោងទៅតាមភាពពិតរបស់មនុស្សព្រះអង្គបានបញ្ចាំងពន្លឺភ្លឺថ្លាប្រិមប្រិយនៃ____________________ ____________________________________ ហើយបានបង្កើតវាឡើងមកធ្វើជាកញ្ចក់នៃ__________

______________________________________________________________________។

២. ឥឡូវចូរឆ្លើយសំណួរទាំងឡាយខាងក្រោម។

ក. តើអ្នកអាចនិយាយពីកេតនភ័ណ្ឌមួយចំនួនរបស់ព្រះក្នុងចំណោមកេតនភ័ណ្ឌទាំងឡាយរបស់ទ្រង់?

______________________________________________________________________

ខ. តើកេតនភ័ណ្ឌមួយចំនួនរបស់ព្រះក្នុងចំណោមកេតនភ័ណ្ឌទាំងឡាយរបស់ទ្រង់អ្វីខ្លះដែលវិញ្ញាណក្ខន្ធមនុស្សអាចឆ្លុះបញ្ចាំង?______________________________________________

______________________________________________________________________

គ. តើកេតនភ័ណ្ឌទាំងនេះអាចត្រូវបានគេបញ្ចេញឱ្យឃើញរបៀបណា?

______________________________________________________________________

______________________________________________________________________

ឃ. តើការអនុគ្រោះពិសេសដែលមនុស្សត្រូវបានគេជ្រើសរើសយកនោះគឺដើម្បីអ្វី ?

______________________________________________________________________

៣. តើខាងក្រោមមួយណាគឺពិត?

______ មនុស្សជាតិគឺមិនមែនខុសគ្នាពីមាបនកម្មដទៃទៀតនោះទេ។

______ សមត្ថភាពដើម្បីស្គាល់ព្រះនិងស្រឡាញ់ទ្រង់គឺកម្លាំងជលផេត ហើយជាគោលបំណងចម្បងបិតនៅក្រោមមាបនកម្មទាំងមូល។

______ ភាពពិតនៃគ្រប់វត្ថុទាំងឡាយដែលបានបង្កើតគឺជាអ្នកទទួលយកកេតនភ័ណ្ឌមួយក្នុងចំណោមកេតនភ័ណ្ឌទាំងឡាយរបស់ព្រះ។

______ វិញ្ញាណក្ខន្ធមនុស្សជាតិអាចឆ្លុះបញ្ចាំងកេតនភ័ណ្ឌទាំងឡាយរបស់ព្រះបាន។

## មេរៀនទី ១៤

ព្រះបាហាអ៊ុលឡាហ៍ប្រាប់យើងថា៖

"កម្លាំងថាមពលទាំងនេះដែលតារាពេលថ្ងៃនៃប្រសិទ្ធិពរអាទិទេពនិងជាប្រភពនៃការណែនាំឋានសួគ៌បានប្រទានភាពពិតនៃមនុស្សគឺកប់នៅក្នុងខ្លួនគាត់ ដូចជាសូម្បីតែអណ្ដាតភ្លើងបានលាក់នៅក្នុងទៀននិងកាំរស្មីនៃពន្លឺគឺ មានសក្ដានុពលនៅក្នុងចង្កៀងដែរ។ ពន្លឺនៃកម្លាំងថាមពលទាំងនេះអាចត្រូវបានធ្វើឲ្យស្រអាប់ដោយសារតែសេចក្ដីលោភលន់នៃលោកិយ សូម្បីតែពន្លឺរបស់ព្រះអាទិត្យក៏អាចត្រូវបានគេធ្វើឲ្យបាំងមើលលែងឃើញនៅក្រោមធូលី និងកំទេចកំទីឥតប្រយោជន៍ដែលគ្របលើកញ្ចក់នោះបានដែរ។ មិនថាទៀនឬចង្កៀងទេមិនអាចធ្វើឲ្យមាន ពន្លឺតាមរយៈមិនមានការខំប្រឹងប្រែងជួយធ្វើឲ្យមានពន្លឺផ្ទាល់ខ្លួនរបស់ពួកវាបានឡើយ ហើយវាក៏មិនអាចមាន លទ្ធភាពដើម្បីធ្វើឲ្យកញ្ចក់ចៀសខ្លួនវាផុតពីរបស់កំទេចកំទីដែលឥតប្រយោជន៍បានដែរ។ វាពិតណាស់ហើយប្រាកដណាស់ដែលថាបើចង់ឲ្យចង្កៀងមានភ្លើងដរាបណាទាល់តែបង្កាត់វាបើមិនអុជវាទេវានឹងមិនមានពន្លឺឡើយ ហើយដរាបណាចង់ឲ្យកញ្ចក់ឆ្លុះបញ្ចាំង

ពន្លឺព្រះអាទិត្យបានលុះត្រាតែកំចាត់ចោលរបស់កំទេចកំទីឥតប្រយោជន៍ឲ្យចេញផុតពីមុខកញ្ចក់ឲ្យអស់ទើបវាអាចឆ្លុះបញ្ចាំងពន្លឺរបស់ព្រះអាទិត្យបាន បើមិនដូច្នេះទេវានឹងមិនអាចចាប់យកស្រមោលរបស់ព្រះអាទិត្យបានឡើយហើយវាក៏មិនអាចឆ្លុះបញ្ចាំងយកពន្លឺនិងភាពរុងរឿងរបស់វាបានដែរ[១៩]"។

១. តើពាក្យថា " កប់ " មានន័យដូចម្តេច ? ________________________________

២. តើសមត្ថភាពអ្វីខ្លះដែលកប់នៅក្នុងវិញ្ញាណក្ខន្ធរបស់មនុស្ស ? ____________________

________________________________________________________________

________________________________________________________________

៣. តើចង្កៀងមានសក្តានុពលអ្វីខ្លះ ? ____________________________________

________________________________________________________________

៤. តើសក្តានុពលអ្វីដែលកញ្ចក់មាន? ____________________________________

________________________________________________________________

៥. តើអ្នកត្រូវធ្វើអ្វីចំពោះចង្កៀងដើម្បីឲ្យវាអាចផ្តល់ពន្លឺបាន ? ______________________

________________________________________________________________

៦. តើអ្នកត្រូវធ្វើអ្វីចំពោះកញ្ចក់ដើម្បីឲ្យវាអាចឆ្លុះបញ្ចាំងពន្លឺបាន ?

________________________________________________________________

៧. តើចង្កៀងនិងកញ្ចក់អាចបញ្ចេញឲ្យឃើញនូវសក្តានុពលរបស់វាដោយខ្លួនឯងបានទេ ?____

៨. តើអ្នកអាចភ្ជាប់នូវឧទាហរណ៍ទាំងពីរនេះទៅនឹងលក្ខណៈនៃវិញ្ញាណក្ខន្ធរបស់មនុស្ស យ៉ាងដូចម្តេច ?

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

៩. តើនរណាអាចធ្វើឲ្យវិញ្ញាណក្ខន្ធរបស់មនុស្សបញ្ចេញឲ្យឃើញនូវសក្តានុពលរបស់វាបាន ?

________________________________________________________________

________________________________________________________________

## មេរៀនទី ១៥

ព្រះបាហាអ៊ុលឡាហ៍ថ្លែងថា៖

**"ទ្វារនៃចំណេះដឹងរបស់ព្រះអាទិទេពពីបុរាណ គឺបានបិទពីមនុស្សជាតិហើយនឹងបន្តជារៀងរហូត។ គ្មានការយល់ដឹងរបស់មនុស្សណាម្នាក់ អាចចូលដល់ព្រះរាជវាំងពិសិដ្ឋរបស់ទ្រង់ឡើយ ។ ទុកដូចជាសញ្ញានៃក្តីមេត្តា**

របស់ទ្រង់និងជាភស្តុតាងនៃសេចក្ដីមេត្តាករុណារបស់ទ្រង់ ព្រះអង្គបានផ្ដល់ដល់មនុស្សនូវគោរពពេលថ្ងៃនានានៃការណែនាំអាទិទេពរបស់ទ្រង់ ដែលជានិមិត្តសញ្ញានៃសាមគ្គីភាពពិសិដ្ឋរបស់ព្រះអង្គ ហើយបានបំពាក់នូវចំណេះដឹងនៃព្រះសាស្ដាពិសិដ្ឋទាំងឡាយនោះ ឲ្យដូចទៅនឹងចំណេះដឹងផ្ទាល់ព្រះកាយរបស់ទ្រង់។ នរណាដែលទទួលស្គាល់ព្រះបរមសាស្ដាគឺទទួលស្គាល់ព្រះអ៊ីចឹងដែរ។នរណាដែលស្ដាប់ទៅនឹងការកោះហៅរបស់ព្រះបរមសាស្ដាក៏ស្ដាប់ទៅនឹងព្រះសូរសៀងរបស់ព្រះដូចគ្នា ហើយនរណាដែលធ្វើជាកសិណសាក្សីទៅនឹងការពិតនៃការត្រាស់ដឹងរបស់ព្រះបរមសាស្ដាក៏ជាកសិណសាក្សីនៃការពិតរបស់ព្រះផ្ទាល់ដែរ។ នរណាដែលងាកចេញពីព្រះបរមសាស្ដាក៏ងាកចេញពីព្រះផងដែរ ហើយនរណាដែលមិនជឿព្រះបរមសាស្ដាក៏មិនជឿលើព្រះដូច្នោះដែរ ។ ព្រះបរមសាស្ដានីមួយៗ គឺជាមាគ៌ារបស់ព្រះដែលផ្សារភ្ជាប់ពិភពលោកនេះជាមួយអាណាចក្រខាងលើ និងសច្ចធម៌របស់ទ្រង់ចំពោះគ្រប់មនុស្សនៅក្នុងគ្រប់អាណាចក្រនៃលោកានិងឋានសួគ៌ ។ ព្រះបរមសាស្ដាគឺជាព្រះសាស្ដារបស់ព្រះក្នុងចំណោមមនុស្សជាភស្តុតាងទាំងឡាយនៃសច្ចធម៌របស់ព្រះអង្គ និងសញ្ញានៃភាពរុងរឿងរបស់ទ្រង់[២០]។

១. ជាមួយនឹងព្រះវចនៈខាងលើដែលដក់ជាប់ក្នុងចិត្តនោះ ចូរឆ្លើយសំណួរដូចតទៅ៖

ក. តើវាអាចទៅរួចទេ ដែលយើងស្គាល់ព្រះបានដោយផ្ទាល់នោះ? ____________________

____________________________________________

ខ. អញ្ចឹង តើយើងអាចស្គាល់ព្រះ បានតាមរបៀបណា ?____________________

____________________________________________

គ. តើអ្នកអាចប្រាប់ព្រះនាមខ្លះៗក្នុងចំណោមព្រះនាមទាំងឡាយនៃគោរពពេលថ្ងៃនៃការណែនាំអាទិទេពបានទេ? ____________________

____________________________________________

____________________________________________

____________________________________________

ឃ. អ្នកទាំងឡាយណាដែលបានស្ដាប់សម្លេងរបស់ព្រះសាស្ដា តើអ្នកទាំងនោះបានឮសូរសៀងរបស់នរណា ? ____________________

ង. នៅពេលណាដែលយើងមិនយកចិត្តទុកដាក់ នឹងការកោះហៅរបស់ព្រះសាស្ដា តើយើងកំពុងតែងាកចេញពីនរណា? ____________________

____________________________________________

២. ចូរបំពេញល្បះដូចតទៅនេះ ៖

ក. ទ្វារនៃចំណេះដឹងនៃព្រះអាទិទេពពីបុរាណមិនដែលធ្លាប់____________________
ហើយនឹងបន្តជារៀងរហូត។

ខ. គ្មានការយល់ដឹងរបស់មនុស្សណាម្នាក់ អាចចូលដល់____________________

____________________________________________________

គ. ព្រះបានបញ្ជូនព្រះសាស្ដាមកទុកដូចនិមិត្តរូបនៃ________________________របស់ព្រះ ហើយជាភស្តុតាងមួយនៃ ______________________________របស់ទ្រង់។

ឃ. ចំណេះដឹងនៃព្រះសាស្ដាដូចគ្នានឹង ______________________________________________________________________________________

ង. នរណាដែលបានទទួលស្គាល់ពួកគេគឺ ______________________________________________________________________________________

ច. នរណាដែលបានឮនូវការកោះហៅរបស់ពួកគេ ក៏ ______________________________________________________________________________________

ឆ. គ្រប់គ្នាក្នុងចំណោមពួកគេគឺជាមាគ៌ារបស់ព្រះដែល______________________________________________________________________________________

៣. តើខាងក្រោមមួយណាគឺពិត៖

______ យើងអាចរីកចម្រើនផ្នែកស្មារតីតាមរយៈភាពខិតខំប្រឹងប្រែងរបស់យើងតែមួយគត់។

______ ព្រះបានប្រទាននូវចិត្តគំនិតដល់យើង អ៊ីចឹងវាគ្រប់គ្រាន់សម្រាប់ភាពរីកចម្រើនរបស់យើង។

______ យើងនឹងរីកចម្រើនផ្នែកស្មារតីដោយការទទួលស្គាល់ព្រះបរមសាស្ដារបស់ព្រះ ហើយនឹងមិនចាំបាច់ខិតខំប្រឹងប្រែងបន្ថែមទៀតទេ។

______ យើងអាចរីកចម្រើនផ្នែកស្មារតីដោយការទទួលស្គាល់ព្រះបរមសាស្ដារបស់ព្រះនិងដោយការខិតខំប្រឹងប្រែងដើម្បីរស់នៅទៅតាមការបង្ហាត់បង្រៀនទាំងឡាយរបស់ទ្រង់។

______ យើងអាចស្គាល់ទ្រង់ដោយផ្ទាល់បាន។

______ មនុស្សជាតិអាចដូចជាព្រះ។

______ ព្រះត្រូវបានគេលើកតម្កើងឱ្យខ្ពស់ជាងការយល់ដឹងរបស់មនុស្ស។

______ នៅពេលណាយើងស្ដាប់ព្រះរាជបន្ទូលទាំងឡាយរបស់ព្រះបរមសាស្ដាមួយព្រះអង្គនោះយើងកំពុងស្ដាប់ព្រះសូរសៀងរបស់ព្រះអ៊ីចឹងដែរ។

## មេរៀនទី ១៦

ព្រះបាហាអ៊ុលឡាហ៍ប្រកាសថា៖

**"ព្យាការីនិងព្រះបរមសាស្ដាទាំងឡាយរបស់ព្រះ ត្រូវបានបញ្ជូនមកក្នុងគោលបំណងតែមួយគត់នៃការណែនាំមនុស្សជាតិឱ្យដើរតាមបរមមាគ៌ារបស់ព្រះ។ គោលបំណងឋិតនៅក្រោមការត្រាស់ដឹងរបស់ព្រះបរមសាស្ដាទាំងឡាយដែលបានអប់រំមនុស្សជាតិទាំងអស់នាពេលវេលានៃមរណភាពដែលឋិតក្នុងភាពពិសិដ្ឋ និង**

ភាពបរិសុទ្ធព្រមទាំងជាមួយនឹងការកាត់ផ្តាច់ចោលអ្វីៗទាំងស្រុងចំពោះពួកគេអាចឡើងទៅកាន់ព្រះបល្ល័ង្ក របស់ព្រះដែលជាព្រះដ៏ខ្ពង់ខ្ពស់បំផុត[២១]"។

នៅក្នុងអត្ថបទផ្សេងទៀតនោះ ទ្រង់មានព្រះបន្ទូលថា៖

"មនុស្សគឺជាវត្ថុស័ក្តិសិទ្ធិដ៏ខ្ពង់ខ្ពស់របស់ព្រះ ។ យ៉ាងណាក៏ដោយបើខ្វះការអប់រំដ៏ត្រឹមត្រូវបានធ្វើឱ្យគាត់ខកខានទទួលនូវអ្វីដែលខ្លួនត្រូវមាន។ តាមរយៈបន្ទូលដែលស្តែងចេញពីព្រះឱស្ឋរបស់ព្រះគាត់ត្រូវបានសូនទៅជាមនុស្សលោក ដោយមួយពាក្យបន្ថែមទៀតគាត់ត្រូវបានណែនាំឲ្យស្គាល់ប្រភពនៃការអប់រំរបស់គាត់ហើយដោយពាក្យមួយម៉ាត់ទៀតឋានៈ និងវាសនារបស់គាត់ត្រូវបានការពារ។ព្រះបាហាអ៊ុលឡាហ៍មានបន្ទូលថា៖ចូរគិតថាមនុស្សគឺជាអណ្តូងរ៉ែដែលមានត្បូងដ៏មានតម្លៃឥតគណនាមានតែការអប់រំគត់ដែលអាចធ្វើឲ្យវាបញ្ចេញនូវរតនសម្បត្តិរបស់វាហើយព្រមទាំងធ្វើឱ្យមនុស្សទទួលប្រយោជន៍ពីវាបាន។ ប្រសិនបើមនុស្សពិចារណាលើពាក្យទាំងនោះ ដែលព្រះគម្ពីរបានបញ្ចូនមកពីឋានសួគ៌នៃព្រះរាជឆន្ទៈដ៏ពិសិដ្ឋរបស់ព្រះដែលបានត្រាស់ដឹងគាត់នឹងទទួលស្គាល់យ៉ាងងាយ ដែលគោលបំណងរបស់ពួកគេ គឺគ្រប់មនុស្សទាំងអស់នឹងត្រូវចាត់ទុកជាវិញ្ញាណក្ខន្ធតែមួយ ដូចនេះហើយត្រាដែលមានពាក្យថា៖អាណាចក្រនឹងជារបស់ព្រះនឹងត្រូវបានបោះត្រាទៅលើបេះដូងគ្រប់ៗគ្នាហើយពន្លឺនៃសព្វសាធុការអាទិទេព ព្រះកិត្តិគុណ និងងមេត្តាករុណានឹងក្រសោបមនុស្សជាតិទាំងអស់[២២]"។

១. តើគោលបំណងអ្វី ដែលព្យាការីនិងព្រះបរមសាស្តាទាំងឡាយរបស់ព្រះត្រូវបានបញ្ចូនចុះមក?__________

________________________________________

________________________________________

២. គោលបំណងបិតនៅក្រោមការត្រាស់ដឹងរបស់ព្រះបរមសាស្តាទាំងឡាយគឺជាអ្វី?

________________________________________

________________________________________

៣. តើពាក្យ " វត្ថុស័ក្តិសិទ្ធិដ៏ខ្ពង់ខ្ពស់ " មានន័យដូចម្តេច ? ____________________

________________________________________

៤. តើអ្វីទៅជាផលវិបាកនៃការខ្វះខាតនៃការអប់រំត្រឹមត្រូវ?

________________________________________

________________________________________

៥. តើការអប់រំត្រឹមត្រូវអាចបណ្តាលមកពីអ្វី? __________________________

________________________________________

៦. តើប្រភពនៃការអប់រំរបស់យើងគឺអ្វី? ____________________________

________________________________________

៧. តើអ្វីគឺជាភ័ព្វសំណាងរបស់យើង? ______________________________

________________________________________

៨. តើរតនសម្បត្តិដែលការអប់រំបញ្ចេញឲ្យឃើញគឺអ្វីខ្លះ ?____________________

________________________________________

________________________________________

៩. តើយើងទទួលស្គាល់អ្វីយ៉ាងងាយនៅពេលយើងសមាធិលើសំណេរទាំងឡាយដ៏ពិសិដ្ឋរបស់ព្រះ?____

________________________________________

## មេរៀនទី ១៧

ព្រះបាហាអ៊ុលឡាហ៍ថ្លែងថាៈ

‶ ម៉្យាងវិញទៀត អ្នកបានសួរតថាគត អំពីស្ថានភាពរបស់វិញ្ញាណក្ខន្ធក្រោយពេលដែលវាបែកគ្នាពីរូបរាងកាយរបស់វាទៅ។ វាជាការពិតនោះចូរអ្នកដឹងថា បើវិញ្ញាណក្ខន្ធរបស់មនុស្សណាមួយ បានដើរតាមមាគ៌ារបស់ព្រះនោះ ពិតណាស់វាប្រាកដជានឹងត្រូវត្រឡប់មកវិញ និងជួបជុំគ្នាទៅកាន់ព្រះ ដែលជាព្រះប្រកបដោយភាពរុងរឿង។យោងទៅតាមគុណធម៌របស់ព្រះ! វិញ្ញាណក្ខន្ធនឹងបានទៅដល់ឋានៈមួយ ដែលជាឋានៈពុំអាចមានប៊ិចណាមួយអាចពិពណ៌នាបាន ឬក៏អណ្តាតណាមួយអាចរៀបរាប់បានឡើយ។ វិញ្ញាណក្ខន្ធណាដែលនៅមានជំនឿជឿជាក់ចំពោះបុព្វហេតុសាសនារបស់ព្រះហើយនៅតាំទ្រយ៉ាង រឹងមាំឥតរេរាក្នុងមាគ៌ារបស់ព្រះអង្គនោះក្រោយពីមរណភាពទៅវិញ្ញាណក្ខន្ធនោះ នឹងត្រូវបានគេប្រគល់ឲ្យនូវអំណាច ដែលគ្រប់ពិភពដែលជាពិភពរបស់ព្រះអាទិទេពបានបង្កើតឡើងហើយក៏ជាអំណាចដែលអាច ធ្វើជាប្រយោជន៍ដល់ខ្លួនគាត់បាន[២៣]‶។

១. ចូរបំពេញឃ្លាខាងក្រោមនេះដូចតទៅៈ

ក. បើវិញ្ញាណក្ខន្ធរបស់មនុស្សណាមួយបានដើរតាម មាគ៌ារបស់ព្រះនោះ វាប្រាកដជានឹងត្រូវបាន

________________________________________

________________________________________

ខ. វិញ្ញាណក្ខន្ធនឹងបានទៅដល់ឋានៈមួយដូចជា ____________________

________________________________________

គ. ____________ដែលនៅមាន__________ ចំពោះ __________

របស់__________ ហើយនិងនៅ____________ យ៉ាងរឹងមាំ _____

_______ ក្នុង ________________ ក្រោយពី ____________

ទៅវិញ្ញាណក្ខន្ធនឹងត្រូវបានគេប្រគល់ឲ្យនូវ____________ដែលគ្រប់ពិភព ជាពិភព

របស់ព្រះអាទិទេពបាន__________ហើយក៏ជា__________________

ដែលអាចជា________________ ខ្លួនគាត់បាន។ ______________

## មេរៀនទី ១៨

ព្រះបាហាអ៊ុលឡាហ៍មានបន្ទូលថា:

"សព្វសាធុការគឺកើតមានដល់វិញ្ញាណក្ខន្ធនៅពេលបែកចេញពីរាងកាយ គឺត្រូវបានសង្គ្រោះចេញពីការស្រមើស្រមៃឥតប្រយោជន៍នៃមនុស្សនៃពិភពលោកនេះ។ វិញ្ញាណក្ខន្ធបែបនេះក៏បានរស់នៅនិងធ្វើចលនាអនុលោមទៅតាមឆន្ទៈរបស់ព្រះដែលទ្រង់ជាអ្នកបង្កើតរបស់វាហើយចូលទៅដល់ឋានសួគ៌ដ៏ខ្ពស់បំផុត។អ្នកបម្រើនៃឋានសួគ៌ដែលជាអ្នកដែលគេបង្ហាំងនៅក្នុងវិមានដ៏ខ្ពស់និងថ្វែលក្រឡឹងជុំវិញវា ចំណែកឯព្យាការណ៍របស់ព្រះនិងអ្នកជម្រើសរបស់ព្រះអង្គ នឹងស្វែងរកភាពជាគូកនរបស់ខ្លួន។ ពេលនោះចិត្តវិញ្ញាណនឹងនិយាយសន្ទនាដោយសេរីជាមួយនឹងពួកគេហើយនិយាយរ៉ាយរ៉ាប់ដល់ពួកគេនូវអ្វីដែលវាត្រូវបានគេធ្វើឡើងដើម្បីឲ្យនៅឋិតថេរក្នុងមាគ៌ារបស់ព្រះដែលជាព្រះអាទិទេពគ្រប់ពិភពទាំងអស់[២៤]"។

"ព្រះអង្គនឹងលើកលែងទោសឲ្យអ្នកដែលមានបាបហើយក៏មិនដែលស្អប់អ្នកដែលមានសភាវខ្លួនទាបដែរព្រោះថាគ្មាននរណាម្នាក់បានដឹងនូវអ្វីដែលទីបញ្ចប់ខ្លួនផ្ទាល់របស់គាត់នឹងទៅជាយ៉ាងណានោះឡើយ។ បើទោះបីជាអ្នកដែលបានប្រព្រឹត្តអំពើបាបជាច្រើនដងមកហើយក៏ដោយ តែនៅពេលម៉ោងមរណភាពមកដល់គាត់ប្រែជាទទួលនូវនិស្សារណានៃការជឿជាក់នៅពេលនោះគាត់នឹងបានទទួលនូវកម្សួលដែលជាអមតៈហើយគាត់ក៏បានធ្វើការហោះហើររបស់គាត់ទៅដល់ទីប្រជុំគ្នានាឋានដ៏ខ្ពស់បាត់ទៅ!ចំណែកឯអ្នកជំនឿដែលមានចិត្តស្មោះច្រើនប៉ុណ្ណាក៏ដោយតែនៅពេលដែលការហោះឡើងនៃវិញ្ញាណក្ខន្ធរបស់គាត់មកដល់នៅពេលនោះគាត់ត្រូវបានគេធ្វើឲ្យផ្លាស់ប្តូរទៅជាមិនមានការជឿជាក់ទៅវិញ នៅពេលនោះគាត់ត្រូវធ្លាក់ចូលទៅក្នុងពន្លឺដ៏ទាបបំផុត[២៥]"

១. តើស្ថានភាពនៃវិញ្ញាណក្ខន្ធរបស់យើងនឹងទៅជាយ៉ាងណា នៅពេលដែលវាបែកគ្នាពីរាងកាយ ?

______________________________

២. តើការគិតស្រមើស្រមៃឥតប្រយោជន៍មានអ្វីខ្លះ ? ______________________________

______________________________

______________________________

______________________________

៣. តើវិញ្ញាណក្ខន្ធដែលបានសង្គ្រោះពីការគិតស្រមើស្រមៃឥតប្រយោជន៍រស់នៅនិងធ្វើចលនាបន្ទាប់ពីមរណភាពគឺឋិតក្នុងស្ថានភាពអ្វីខ្លះ?

៤. តើវិញ្ញាណក្ខន្ធនិងគូកននៅជាមួយនឹងនរណា ?______________________________

______________________________

៥. តើវិញ្ញាណក្ខន្ធទាំងនេះនឹងអាចនិយាយសន្ទនាជាមួយនឹងព្យាការីរបស់ព្រះបានដែរឬទេ ? __________

______________________________

៦. តើយើងនឹងដឹងជាមុននូវរបៀបនិងពេលវេលានៃជីវិតលោការបស់យើងនឹងដល់ទីបញ្ចប់ឬទេ?

______________________________

៧. តើយើងអាចធ្វើអ្វីបាននៅពេលនេះដើម្បីទទួលបានជីវិតដែលមិនចេះសាបសូន្យដែលត្រូវបានគេទុកសម្រាប់យើង ?

________________________________________________________________

## មេរៀនទី១៩

អង្គពិសិដ្ឋអាប់ឌុលបាហាពន្យល់ថា៖

"នៅពេលស្មារតីនៃមនុស្សជាតិរស់នៅជារៀងរហូតបន្ទាប់ពីការចាកចេញពីរូបរាងកាយដ៏សំខាន់នេះ ដូចវត្ថុមានជីវិតទាំងអស់ វាគឺមានសមត្ថភាពរីកចម្រើនដែលឥតសង្ស័យ អ៊ីចឹងហើយមនុស្សអាចសូត្រធម៌សម្រាប់វិញ្ញាណក្ខន្ធអ្នកដែលចែកឋានទៅដើម្បីឱ្យរីកចម្រើនលូតលាស់ ដើម្បីការលើកលែងទោសឬក៏ត្រូវបានធ្វើឱ្យអ្នកទទួលការពេញចិត្តពីមេត្តាធម៌ទាំងឡាយដ៏ពិសិដ្ឋ ទទួលពរសព្ទសាធុការនិងកិត្តិគុណរបស់ព្រះ។ នោះហើយគឺជាមូលហេតុដែលក្នុងធម៌ទាំងឡាយរបស់ព្រះបាហាអ៊ុលឡាហ៍ អំពីការអត់ឱននិងការអភ័យទោសរបស់ព្រះគឺត្រូវបានអង្វរករសម្រាប់អ្នកទាំងនោះដែលបានឡើងទៅកាន់បរលោក។ ម្យ៉ាងវិញទៀត ដូចមនុស្សគឺឋិតក្នុងសេចក្ដីត្រូវការពីព្រះក្នុងលោកិយនេះដូចគ្នានេះដែរ ពួកគេត្រូវការទ្រង់នៅបរលោកផងដែរ។ មាបនកម្មទាំងឡាយត្រូវការជានិច្ច ចំណែកឯព្រះគឺគឺឋិតនៅឯករាជ្យពីពួកគេទាំងស្រុង មិនថាឋិតនៅក្នុងពិភពនេះឬបរលោកនោះទេ[២៦]"។

ហេតុអ្វីយើងគួរសូត្រធម៌សម្រាប់វិញ្ញាណក្ខន្ធទាំងឡាយដែលចាកចេញ?

________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________________
________________________________________________________

## មេរៀនទី២០

អង្គពិសិដ្ឋអាប់ឌុលបាហានិពន្ធថា៖

"នៅពេលវិញ្ញាណក្ខន្ធមនុស្សបានចាកចេញពីគំនរសំរាមមិនឋិតថេរនេះ ហើយឡើងទៅកាន់ពិភពរបស់ព្រះដូច្នេះហើយរបាំងទាំងឡាយនឹងខ្ចាតចេញឆ្ងាយ រីឯតថភាពនឹងផ្ដល់នូវពន្លឺ ហើយវត្ថុគ្រប់យ៉ាងដែលមិនដឹងកាលពីមុននឹងត្រូវបានធ្វើគេធ្វើឱ្យច្បាស់ឡើង ចំណែកឯសច្ចធម៌ទាំងឡាយដែលកប់ត្រូវបានគេធ្វើឱ្យយល់។

"ចូរគិតពិចារណាពីរបៀបដែលជីវិតមួយឋិតក្នុងពិភពនៃផ្ទៃមាតាគឺត្រចៀកស្តាប់មិនឮហើយភ្នែកខ្វាក់ព្រមទាំងអណ្តាតនិយាយមិនកើតទៀតពីរបៀប ដែលគាត់គឺបានឈឺចុកចាប់គ្រប់សញ្ញាក្ខន្ធទាំងអស់។ ប៉ុន្តែនៅពេលពេលចាកចេញពីពិភពនៃភាពងងឹត គាត់ឆ្លងកាត់ទៅពិភពនៃពន្លឺនេះ បន្ទាប់មកភ្នែកទាំងគូរគាត់បានមើលឃើញត្រចៀករបស់គាត់បានស្តាប់ឮ អណ្តាតរបស់គាត់បាននិយាយស្តី។ ដូចគ្នានេះដែរនៅពេលដែលគាត់ប្រញាប់ប្រញាល់ចេញពីកន្លែងមរណភាពចូលទៅក្នុងអាណាចក្ររបស់ព្រះ អ៊ីចឹងហើយនោះគាត់នឹងត្រូវបានកើតក្នុងស្មារតី ភ្នែកនៃសញ្ញាក្ខន្ធរបស់គាត់នឹងបើក ត្រចៀកនៃវិញ្ញាណក្ខន្ធរបស់គាត់នឹងបានស្តាប់ហើយសច្ចធម៌ទាំងអស់ដែលគាត់គឺមិនដឹងកាលពីមុននឹងត្រូវបានធ្វើឱ្យច្បាស់និងស្រលះល្អឡើង[២៧]"។

១. ចូរបំពេញចន្លោះទាំងឡាយខាងក្រោម៖

ក. "នៅពេលវិញ្ញាណក្ខន្ធមនុស្សបានចាកចេញពីគំនរសំរាមមិនឋិតថេរនេះ ហើយ

_របាំងទាំងឡាយនឹង____________

_ រឹងតថភាព___________________

_ ហើយវត្ថុគ្រប់យ៉ាងដែលមិនដឹងកាលពីមុន_________________________________

_ចំណែកឯសច្ចធម៌ទាំងឡាយដែលកប់_____________________________________។

ខ. ក្នុងពិភពនៃផ្ទៃ_________យើងគឺមានត្រចៀក_____________ហើយភ្នែក____________ព្រមទាំងអណ្តាត__________________ ។

គ. នៅពេលពេលយើងចាកចេញពីពិភពនៃភាពងងឹតគាត់ឆ្លងកាត់ទៅពិភពនៃពន្លឺនេះ បន្ទាប់មកភ្នែកទាំងគូរគាត់_________________ត្រចៀករបស់គាត់___________អណ្តាតរបស់គាត់____________។

ឃ. ដូចគ្នានេះដែរនៅពេលដែលយើងប្រញាប់ប្រញាល់ចេញពីកន្លែងមរណភាពចូលទៅក្នុងអាណាចក្ររបស់ព្រះអ៊ីចឹងហើយនោះយើងនឹងត្រូវ______________ក្នុងស្មារតី។

ង. ហើយភ្នែកនៃ______________របស់យើងនឹងបើក ត្រចៀកនៃ________________របស់យើងនឹង______________ហើយ___________ទាំងអស់ដែលគាត់គឺមិនដឹងកាលពីមុននឹងត្រូវបានធ្វើឱ្យ____________និង________________។

២. ចូរសម្រេចចិត្តថាតើសេចក្តីថ្លែងការខាងក្រោមណាខ្លះគឺពិត៖

_____ នៅពេលណាយើងឋិតនៅក្នុងពិភពនៃផ្ទៃមាតា យើងយល់ពីពិភពនេះ។

_____ ស្ថានភាពរបស់យើងបន្ទាប់ពីមរណភាពគឺជាសេចក្តីពិតដែលលាក់បំបាំងចំពោះយើងក្នុងជីវិតនេះ។

_____ នភាបាទថ្មីទាំងស្រុង នឹងបើកមុនពេលយើងស្លាប់។

_____ នៅពេលយើងស្លាប់ យើងនឹងត្រឡប់ទៅពិភពនេះដើម្បីកើតម្តងទៀត។

## មេរៀនទី២១

ព្រះបាហាអ៊ុលឡាហ៍ថ្លែងថាៈ

"ហើយឥឡូវនេះទាក់ទងទៅនឹងសំណួររបស់អ្នកថាតើ វិញ្ញាណក្ខន្ធរបស់មនុស្សស្គាល់គ្នាដែរឬទេនៅពេលបែងចេញរបស់វាពីរូបរាងកាយនោះ។ ចូរអ្នកដឹងថាវិញ្ញាណក្ខន្ធនៃមនុស្សទាំងឡាយដ៏រុងរឿងរបស់ព្រះដែលបានចូលទៅនិងត្រូវបានគេបង្កើតឡើងនៅក្នុងអឌ្ឍចន្ទក្រហមដាំរបស់ព្រះនឹងរួមគ្នាព្រមទាំងទាក់ទងគ្នាយ៉ាងជិតស្និទ្ធពីម្នាក់ទៅម្នាក់ ហើយនឹងប្រាកដជាត្រូវបានរួមគ្នាយ៉ាងជិតស្និទ្ធក្នុងជីវិតរបស់ពួកគេក្នុងសេចក្តីប្រាថ្នារបស់គេក្នុងគោលបំណងរបស់គេ ហើយការខិតខំប្រឹងប្រែងទាំងឡាយដូចជាវិញ្ញាណក្ខន្ធតែមួយ។ពិតប្រាកដណាស់ពួកគេជាអ្នកដែលដឹងយ៉ាងច្បាស់អ្នកដែលមានការមើលឃើញយ៉ាងមុតមាំ ហើយនិងអ្នកដែលត្រូវបានគេប្រទានឱ្យជាមួយនឹងការស្វែងយល់។អ៊ីចឹងហើយនោះវាត្រូវបានគេដាក់បញ្ញត្តិដោយព្រះដែលជាព្រះប្រកបដោយញាណគ្រប់យ៉ាង ជាព្រះប្រកបដោយគតិបណ្ឌិត។

"មនុស្សទាំងឡាយដ៏រុងរឿង ដែលជាមនុស្សត្រូវបានគេបង្ខាំងនៃអឌ្ឍចន្ទរបស់ព្រះ ម្នាក់និងទាំងអស់គ្នាដឹងយ៉ាងច្បាស់នៃឋានៈភាពនិងស្ថានភាពពីម្នាក់ទៅម្នាក់ ហើយគឺត្រូវបានរួបរួមគ្នាក្នុងចំណងនៃភាពស្និទ្ធស្នាលនិងមិត្តភាព។ ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពមួយនេះត្រូវតែអាស្រ័យលើជំនឿរបស់ពួកគេ និងការប្រព្រឹត្តរបស់ពួកគេ។ពួកគេដែលមានកម្រិតនិងឋានៈដូចគ្នាគឺបានដឹងពីសមត្ថភាពអត្តចរិក សមិទ្ធផល និងគុណសម្បត្តិគួរឱ្យសរសើររវាងគ្នានឹងគ្នា។ ទោះបីជាយ៉ាងនេះក៏ដោយអ្នកដែលមានឋានៈទាប គឺគ្មានសមត្ថភាពនៃការយល់ឱ្យបានគ្រប់គ្រាន់ពីឋានៈភាពឬពីការប៉ាន់ស្មាននូវគុណសម្បត្តិ ពីអ្នកទាំងនោះដែលមានឋានៈខ្ពស់ជាងពួកគេបានទេ។ម្នាក់ៗនឹងទទួលចំណែករបស់គាត់ពីព្រះអាទិទេពរបស់គាត់។ ពរសព្ទសាធុការកើតមានដល់អ្នកដែលបានបែរមុខរបស់គាត់ឆ្ពោះទៅកាន់ព្រះ និងដើតាមមាគ៌ាដ៏រឹងមាំក្នុងក្តីស្រឡាញ់របស់ទ្រង់រហូតដល់វិញ្ញាណក្ខន្ធរបស់គាត់បានបំពាក់ស្លាបនៃការហោះហើររបស់ខ្លួន ឆ្ពោះទៅកាន់ព្រះដែលជាព្រះប្រកបដោយអធិបតេយ្យភាព ជាព្រះប្រកបដោយពលានុភាពបំផុត ជាព្រះលើកលែងទោសជារៀងរហូត ជាព្រះប្រកបដោយក្តីមេត្តាគ្រប់យ៉ាង[២៨]"។

១. នៅក្នុងបរលោក តើយើងនឹងទទួលស្គាល់មនុស្សទាំងឡាយដែលយើងបានស្គាល់ក្នុងពិភពនេះឬទេ?____
_______________________________________________

២. តើទំនាក់ទំនងរវាងវិញ្ញាណក្ខន្ធនៅពិភពបរលោកនឹងជិតស្និទ្ធគ្នាយ៉ាងណា?____________________
_______________________________________________

៣. តើភាពខុសគ្នានិងភាពផ្សេងគ្នាក្នុងចំណោមវិញ្ញាណក្ខន្ធទាំងឡាយក្នុងពិភពបរលោកនឹងពឹងទៅលើអ្វី? ____
_______________________________________________
_______________________________________________

៤. តើមនុស្សម្នាក់នឹងត្រូវបានគេដកហូតនូវកិត្តិគុណរបស់ព្រះឬ?______________________________
_______________________________________________

**មេរៀនទី២២**

ព្រះបាហាអ៊ុលឡាហ៍ក្រើនរំលឹកយើងថា:

**"ឱអ្នកបម្រើរបស់តថាគតអើយ!ចូរអ្នកកុំកើតទុក្ខប្រសិនបើជាវត្ថុទាំងឡាយក្នុងនៅក្នុងលោកានាយុគសម័យនេះផ្ទុយទៅនឹងបំណងប្រាថ្នារបស់អ្នកព្រោះតែត្រូវបានគេកំណត់និងត្រូវបានគេបញ្ចាញឲ្យឃើញដោយព្រះ នៅក្នុងសម័យទាំងនេះ ហើយនឹងនៅលើផែនដីនេះសម្រាប់សម័យ ដែលនាំមកនូវសេចក្ដីរីករាយនិងភាពសប្បាយក្រៃលែងនោះដែលបម្រុងទុកសម្រាប់អ្នក។ ពិភពលោកនឹងត្រូវបានបង្ហាញមកដល់ភ្នែករបស់អ្នកដោយភាពរុងរឿងយ៉ាងពិសិដ្ឋនិងស្មារតី។ អ្នកត្រូវបានកំណត់ដោយទ្រង់នៅក្នុងពិភពនេះនិងពិភពបរលោក ដើម្បីទទួលយកសារៈប្រយោជន៍របស់ពួកគេដើម្បីចែករំលែកសេចក្ដីរីករាយរបស់ពួកគេ និងដើម្បីទទួលយកចំណែកនៃការអនុគ្រោះដ៏បិតបេររបស់ពួកគេ។សម្រាប់ម្នាក់ៗនិងមនុស្សគ្រប់ៗគ្នា អ្នកនឹងទទួលបានដោយគ្មានការសង្ស័យ[២៩]"។**

១. ចូរសម្រេចថាសេចក្ដីថ្លែងការមួយណាគឺពិត៖

______ យើងត្រូវតែមានអារម្មណ៍ក្រៀមក្រំនៅពេលរឿងរ៉ាវគឺកើតឡើងមិនតាមវិធីដែលយើងចង់បាន។
______ អ្វីគ្រប់យ៉ាងមិនថាល្អឬអាក្រក់ ត្រូវបានប្រទានឱ្យដោយព្រះ ។
______ ថ្ងៃទាំងឡាយនៃភាពរីករាយដ៏សុខក្សេមក្សាន្តកំពុងរង់ចាំយើងទាំងអស់គ្នា ។
______ យើងប្រាកដថាចង់ឃើញពិភពទាំងឡាយដែលជាពិភពដ៏ពិសិដ្ឋនិងរុងរឿងផ្នែកស្មារតី ។
______ វាគឺជាវាសនារបស់យើងក្នុងការទទួលយកអត្ថប្រយោជន៍នៃពិភពទាំងនេះនៅក្នុងជីវិតនេះ និងជីវិតនៅបរលោក ។

២. តើហេតុអ្វីបានជាយើងមិនត្រូវក្រៀមក្រំនៅពេលដែលវត្ថុទាំងឡាយកើតឡើងផ្ទុយទៅនឹងបំណងប្រាថ្នារបស់យើងនោះ ?

______________________________

______________________________

៣. តើព្រះបាហាអ៊ុលឡាហ៍បានធ្វើការសន្យាចំពោះយើងនៅក្នុងសារនេះថាដូចម្ដេចខ្លះ?

______________________________

______________________________

## មេរៀនទី២៣

នៅក្នុងវគ្គសិក្សានេះអ្នកបានសិក្សានិងត្រិះរិះពិចារណាទៅលើអត្ថន័យពិតនៃជីវិតមនុស្ស។អ្នកក៏បានរៀនសូត្រនូវភាពអស្ចារ្យអំពីលក្ខណៈនៃវិញ្ញាណក្ខន្ធ គោលបំណងនៃជីវិតក្នុងពិភពនេះ ភាពចាំបាច់នៃការអភិវឌ្ឍលក្ខណៈគុណសម្បត្តិទាំងឡាយផ្នែកស្មារតីនិងការសន្យានៃជីវិតជាអនន្ត ដែលពោរពេញទៅដោយសេចក្ដីរីករាយនិងភាពរុងរឿង។ វគ្គទីពីរនៃសៀវភៅនេះ យើងបាននិយាយរួចហើយពីគោលបំណងភ្លោះមួយដើម្បីបន្តភាពរីកចម្រើនផ្នែកសតិបញ្ញានិងស្មារតីផ្ទាល់ខ្លួន ហើយនិងដើម្បីចូលរួមចំណែកដល់ការផ្លាស់ប្ដូរភាពល្អប្រសើរដល់សង្គម។ នេះជាឱកាសមួយដើម្បី

ត្រឡប់ទៅគោលគំនិតនោះដែលអ្នកគិតអំពីសារសំខាន់នៃការផ្តោតអារម្មណ៍យកចិត្តទុកដាក់ចំពោះទស្សនៈទាំងពីរនៃគោលបំណងនេះ ពឹងផ្អែកទៅលើការយល់ដឹងទាំងឡាយ ដែលអ្នកបានទទួលយកអំពីភាពរីកចម្រើននៃវិញ្ញាណក្ខន្ធ។ ការឆ្លុះបញ្ចាំងនានារបស់អ្នកអាចទទួលប្រយោជន៍ពីការពិភាក្សាមួយពីខ្លឹមសារខាងក្រោមនៅក្នុងក្រុមអ្នក៖

១. ការអភិវឌ្ឍលក្ខណៈសម្បត្តិផ្នែកស្មារតី
២. ការគោរពតាមច្បាប់ទាំងឡាយរបស់ព្រះ
៣. ការចូលរួមចំណែកដល់សុខុមាលភាពនៃអំបូរមនុស្ស
៤. ភាពរីកចម្រើនលើមាគ៌ានៃការបម្រើ

## REFERENCES


1. From a talk given on 10 November 1911, published in *Paris Talks: Addresses Given by ‘Abdu’l-Bahá in 1911* (Wilmette: Bahá’í Publishing, 2006, 2016 printing), no. 29.12–13, p. 109.

2. From a letter dated 1 April 1946 written on behalf of Shoghi Effendi, published in *Lights of Guidance: A Bahá’í Reference File* (New Delhi: Bahá’í Publishing Trust, 1988, 2010 printing), no. 1820, p. 537.

3. From a letter dated 28 July 2016 written on behalf of the Universal House of Justice.

4. ‘Abdu’l-Bahá, in *Some Answered Questions* (Wilmette: Bahá’í Publishing, 2014, 2016 printing), no. 66.3, pp. 352–53.

5. Ibid., no. 38.5, p. 220.

6. From a talk given by ‘Abdu’l-Bahá on 9 November 1911, published in *Paris Talks*, no. 28.16, p. 104.

7. From a letter dated 31 December 1937 written on behalf of Shoghi Effendi, published in *Lights of Guidance*, no. 680, p. 204.

8. *Gleanings from the Writings of Bahá’u’lláh* (Wilmette: Bahá’í Publishing Trust, 1983, 2017 printing), LXXXII, par. 8, p. 183.

9. ‘Abdu’l-Bahá, in *Some Answered Questions*, no. 61.1–2, p. 334.

10. *Gleanings from the Writings of Bahá’u’lláh*, LXXX, par. 2, p. 174.

11. Ibid., LXXXI, par. 1, p. 176.

12. Ibid., CLXV, par. 1–3, pp. 391–92.

13. Bahá’u’lláh, *The Hidden Words* (Wilmette: Bahá’í Publishing Trust, 2003, 2012 printing), Arabic no. 32, p. 11.

14. From a talk given on 6 July 1912, published in *The Promulgation of Universal Peace: Talks Delivered by ‘Abdu’l-Bahá during His Visit to the United States and Canada in 1912* (Wilmette: Bahá’í Publishing, 2012), pp. 315–16. (authorized translation)

15. *Gleanings from the Writings of Bahá’u’lláh*, V, par. 4, p. 8.

16. Ibid., LXXXII, par. 1, pp. 179–80.

17. Ibid., CLIII, par. 6, pp. 370–71.

18. Ibid., XXVII, par. 2, pp. 72–73.

19. Ibid., XXVII, par. 3, p. 73.

20. Ibid., XXI, par. 1, pp. 54–55.

21. Ibid., LXXXI, par. 1, p. 177.

22. Ibid., CXXII, par. 1, pp. 293–94.

23. Ibid., LXXXII, par. 7, p. 182.

24. Ibid., LXXXI, par. 1, pp. 176–77.

25. Ibid., CXXV, par. 3, pp. 300–1.

26. ‘Abdu’l-Bahá, in *Some Answered Questions*, no. 62.3, pp. 340–41.

27. *Selections from the Writings of ‘Abdu’l-Bahá* (Wilmette: Bahá’í Publishing, 2010, 2015 printing), no. 149.3–4, pp. 246–47.

28. *Gleanings from the Writings of Bahá’u’lláh*, LXXXVI, par. 1–2, pp. 192–93.

29. Ibid., CLIII, par. 9, p. 373.